ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 02-May-2013, 13:17
CMS/CFO: Sann Rada

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

# ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសង

**ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៣**

**ម៉ោង ០៩: ០៣នាទី**

**សវនាការលើកទី១៧១**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍ *(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ *(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង) *(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ឌុច ផារី

លោកស្រី សែ កុលវុឌ្ឍី

លោក រ៉ូជឺ ហ្វីលីព *(Mr. Roger Phillips)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក វ៉េង ហ៊ាត់

លោក ថារីក អាប់ឌុលឡាក់ *(Mr. Tarik ABDULHAK)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក វ៉ិចទ័រ កូប៉េ *(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោក វ៉ែន ពៅ

លោកស្រី ទី ស្រ៊ីនណា

លោក ឡោ ជុនធី

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោកស្រី ស្វួ សុទ្ធាវី

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក អាប់ឌុលឡាក់ ថារីក | អង់គ្លេស |
| លោក វ៉េង ហ៊ត់ | ខ្មែរ |
| លោក រ៉ិចឆ័រ កូប៉េ | អង់គ្លេស |
| លោក គង់ សំអុន | ខ្មែរ |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត | បារាំង |
| លោក រស់ ស៊ុយ (TCW-570) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី ៖ លោក រស់ ស៊ុយ** (TCW-570)

សួរដោយប្រធានអង្គជំនុំ ផ្តើមពី ....................ទំព័រ ៣
សួរដោយកញ្ញា អង់តា ហ្គីសសេ ផ្តើមពី....................ទំព័រ ៧
សួរដោយលោក គង់ សំអុន ផ្តើមពី ....................ទំព័រ ៣៦
សួរដោយលោក អាប់ឌុលឡាក់ ថារីក ផ្តើមពី ....................ទំព័រ ៤០
សួរដោយលោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត ផ្តើមពី ....................ទំព័រ ៦៦
សួរដោយលោក ពេជ អង្គ ផ្តើមពី ....................ទំព័រ ៧២
សួរដោយលោក រ៉ិចទ័រ កូប៉េ ផ្តើមពី....................ទំព័រ ៧៩

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០៣:១៨]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ នៅតាមកាលវិភាគបានគ្រោងទុក ហើយបានជម្រាបជូនភាគី និងសាធារណជនរួចហើយថា នៅថ្ងៃនេះអង្គជំនុំជម្រះនឹងធ្វើសវនាការស្ដាប់សក្ខីកម្មសាក្សី ដែលមានរហស្សនាម TCW-570។ ហើយនិងត្រូវសួរដេញដោលដោយក្រុមមេធាវីការពារក្ដីលោក ខៀវ សំផន មុនភាគីដទៃទៀតនៃរឿងក្ដី។ ដោយហេតុថាមេធាវីការពារក្ដីលោក ខៀវ សំផន ជាអ្នកស្នើសុំចំពោះសាក្សីរូបនេះ។ ដើម្បីឲ្យអង្គជំនុំជម្រះស្ដាប់សក្ខីកម្មរបស់គាត់។ ហើយនៅកិច្ចដំណើរការសវនាការនេះ គឺយើងរៀបចំនៅក្នុងការពិភាក្សាដេញដោលដូចពីម្សិលមិញ គឺមេធាវីការពារក្ដី គឺអនុវត្តនូវពេលវេលាវគ្គទី១ និងវគ្គទី៤នៃថ្ងៃនេះ ហើយចំណែកឯសហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី គឺមានឱកាសនៅក្នុងការសួរដេញដោលសាក្សីនៅវគ្គទី២ និងវគ្គទី៣ នៃសវនាការថ្ងៃនេះ។

[០៩:០៤:៥០]

លោកស្រី សែ កុលវុឌ្ឍី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះនិងអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ!

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការថ្ងៃនេះ គ្រប់ភាគីទាំងអស់នៃរឿងក្ដីនេះមានវត្តមាន។ សូមកត់សម្គាល់ ដោយឡែក លោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនដែលនៅពីខាងក្រោមបន្ទប់សវនាការនេះតាមសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដោយមូលហេតុបញ្ហាសុខភាព។ រីឯសាក្សីដែលត្រូវមកផ្ដល់សក្ខីកម្មនៅថ្ងៃនេះ គឺសាក្សីដែលមានរហស្សនាម TCW-570 ហើយគាត់មានវត្តមាននៅក្នុងបន្ទប់រង់ចាំ រង់ចាំការកោះហៅពីអង្គជំនុំជម្រះ។ សាក្សីបានបញ្ជាក់ថា តាមសមត្ថភាពដែលគាត់អាចដឹង គឺគាត់មិនមានជាប់ចំណងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីរ គឺលោក នួន ជា និងលោក ខៀវ សំផន ឬភាគីដើមបណ្ដឹងរដ្ឋប្បវេណីណាមួយដែលត្រូវបាន

ទទួលស្គាល់នៅក្នុងរឿងក្ដីនេះទេ។ គាត់បានធ្វើសម្បថនៅចំពោះមុខលោកតាដំបងដែករួចហើយកាលពីថ្ងៃអង្គារ ទី២៣ ខែមេសា ឆ្នាំ២០១៣។ សាក្សីរូបនេះមិនមានមេធាវីប្រឹក្សានោះទេ។ ហើយនៅថ្ងៃនេះផងដែរ ក៏មិនមានសាក្សីបម្រុងដែរ។ សូមអរគុណ។

[០៩:០៦:០៧]

**ប្រធានអង្គជំនុំ៖**

បាទអរគុណលោកស្រី សែ កុលវុឌ្ឍី។ មន្ត្រីរដ្ឋបាលតុលាការអញ្ជើញសាក្សី TCW-570 ចូលមកកាន់កន្លែងផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ!

សូមអញ្ជើញលោកស្រីមេធាវីអន្តរជាតិការពារក្ដីលោក ខៀវ សំផន!

**កញ្ញា អង់តា ហ្គីសសេះ**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោកប្រធាន លោក លោកស្រីចៅក្រម។ ជម្រាបសួរភាគីទាំងអស់។ ខ្ញុំគ្រាន់តែចង់ជម្រាបអង្គជំនុំជម្រះថា យើងបានពិភាក្សាគ្នាជាមួយមេធាវីការពារក្ដី នួន ជា ហើយយើងប្រាប់ជូនអំពីការបែងចែកពេលវេលារវាងក្រុមយើងទាំងពីរ។ ខាងមេធាវី នួន ជា បានប្រាប់ថា គាត់ត្រូវការពេលវេលាប្រហែលជា ២០ ទៅ ៣០នាទីទេ សម្រាប់ការសួរសំណួរសាក្សីនេះ។ ដូច្នេះគោលបំណងរបស់យើង គឺថាយើងកំណត់ត្រឹមតែថាប្រហែលជាចប់ត្រឹមព្រឹកនេះម៉ោងដប់មួយសាមសិបនាទី គឺសម្រាប់ក្រុមមេធាវីការពារក្ដីរបស់យើងខ្ញុំ។

*(សម្រាករយៈពេលខ្លី)*

[០៩:០៧:២៩]

**ប្រធានអង្គជំនុំ៖**

យ៉ាងម៉េចទៅសូមលើកឲ្យច្បាស់លាស់! ស្នើសុំយ៉ាងម៉េចឥឡូវនេះ វាមានការប្រែប្រួលរវាងថ្ងៃនេះ និងថ្ងៃម្សិលមិញ។ ម្សិលមិលអង្គជំនុំជម្រះបានរៀបចំបែបនេះ ហើយមានការតវ៉ា ហើយស្នើសុំផ្អុយ។ ឥឡូវនេះអង្គជំនុំជម្រះបណ្ដោយឲ្យទៅតាមអ្វីដែលមានបំណងលើកឡើងកាលពីម្សិលមិញ។ មេធាវីហាក់ដូចជាមានចេតនាលើកឡើងនូវសំណើសុំផ្អុយពីអ្វីដែលអង្គជំនុំជម្រះចាត់ចែង។ យើងដូចជាពិបាលយល់។ សូមលោកស្រីពន្យល់ ហើយមេធាវីការពារក្ដីលោក នួន ជា ផងដើម្បីពន្យល់យើងហើយនិងអង្គជំនុំជម្រះ និងសាធារណជនជ្រាបអំពីហេតុផលទាំងឡាយដែលនាំឲ្យមានការប្រែប្រួលទៅតាមការចិត្តចង់ដូច្នេះ។

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ខ្ញុំព្យាយាមថានិយាយឲ្យច្បាស់ ប៉ុន្តែទៅជាមានការភ័ន្តច្រឡំទៅវិញ។ ដូចម្សិលមិញហ្នឹង យើងៗប្រើពេលវេលារហូតដល់ -- ដូចរបៀបនៅថ្ងៃនេះអ៊ីចឹង គឺថាខាងក្រុមមេធាវី នួន ជា គឺគាត់ត្រូវការពេលវេលារសៀលហ្នឹងប្រហែលជាត្រឹមតែកន្លះម៉ោងទេ។ ដូច្នេះ ថ្ងៃនេះនៅសម្រាប់ព្រឹកនេះនោះ ក្រុមមេធាវី ខៀវ សំផន នោះគឺអាចបញ្ចប់ត្រឹមម៉ោងដប់មួយកន្លះ ដើម្បីឲ្យព្រះរាជអាជ្ញាអាចបន្តទៅម៉ោងដប់មួយកន្លះ ហើយនៅសល់ពេលវេលាកន្លះម៉ោង គឺសម្រាប់ពេលរសៀលនេះអាចឲ្យក្រុម នួន ជា គាត់សួរសំណួរបានហើយ។ ដូច្នេះ ខ្ញុំគិតថាអ្វីដែលខ្ញុំបញ្ជាក់ជូនអង្គជំនុំជម្រះនេះ គឺច្បាស់លាស់ហើយ។

[០៩:០៩:១៧]

**ប្រធានអង្គជំនុំ៖**

អរគុណ។ ហើយមេធាវី ក្រុមមេធាវីការពារក្តីលោក នួន ជា មានយោបល់អ្វីទេ លើបញ្ហាការបែងចែកពេលវេលាដូច្នេះ?

**លោក វ៉ិចទ័រ កូប៉េ៖**

ជម្រាបសួរលោកប្រធាន! ថ្ងៃនេះគឺមិនដូចពីម្សិលមិញទេ ក្រុមយើងខ្ញុំសូមតែពេល ប្រើពេលតែ ២០នាទីទេ ដូចមេធាវីការពារក្តីលោក ខៀវ សំផន បានលើកឡើងអ៊ីចឹងលោកប្រធាន។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញសាក្សីចូលមកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ!

*(សាក្សីចូលក្នុងបន្ទប់សវនាការ)*

[០៩:១០:៣០]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្តីលោកសាក្សី! តើលោកឈ្មោះអី?

**លោក រស់ ស៊ុយ៖**

**ឆ៖** បាទៗ សូមជម្រាបលោកប្រធាន! ខ្ញុំបាទឈ្មោះ រស់ ស៊ុយ។ មានទីលំនៅភូមិពាមប្រជុំ ឃុំព្រែកអំបិល ស្រុកស្អាង ខេត្តកណ្ដាលបាទ។

**ស៖** បាទ អរគុណលោក រស់ ស៊ុយ។ ក្រៅពីឈ្មោះ ស៊ុយ តើលោកមានប្រើប្រាស់ឈ្មោះអ្វីផ្សេងទៀតដែរឬទេ? ជាពិសេសនៅក្នុងសម័យធ្វើសង្គ្រាមឆ្នាំ១៩៧០-៧៥។

**ឆ៖** បាទ ជម្រាបលោកប្រធាន ខ្ញុំបាទអត់មានឈ្មោះអីក្រៅពីឈ្មោះ រស់ ស៊ុយ ហ្នឹងទេបាទ។

**ស៖** បាទ អរគុណ ហើយលោកមានអាយុប៉ុន្មាន?

**ឆ៖** សព្វថ្ងៃ៦០បាទ។

**ប្រធានអង្គជំនុំ៖**

លោក រស់ ស៊ុយ រង់ចាំក្បាលមីក្រូហ្វូនប្រតិបត្តិការដោយឲ្យសញ្ញាភ្លើងក្រហមដូច្នេះសិន សឹមលោកចាប់ផ្តើមនិយាយ នោះទើបសំឡេងរបស់លោកចូលទៅប្រព័ន្ធនៃការចែកចាយសំឡេងគ្រប់គ្នាបានស្តាប់ឮ ហើយជាពិសេសគឺខាងអង្គភាពបកប្រែភាសា ទៅជាភាសាអង់គ្លេស និងភាសាបារាំងគាត់អាចបកប្រែបានផង ហើយទី១។

[០៩:១១:៥៨]

ទី២ គឺខាងអ្នកបច្ចេកទេសសម្របសម្រួលនៅក្នុងការប្រើប្រាស់មីក្រូហ្វូននេះ ដើម្បីទុកពេលវេលាឲ្យមានការបកប្រែពេញលេញ បានល្អនោះ គឺមានការឃ្លាតគ្នាបន្តិច រវាងការសួរហើយនិងការឆ្លើយ។ អ៊ីចឹងហើយបានជាមានយូរបន្តិចទើបក្បាលមីក្រូហ្វូននេះប្រតិបត្តិការ។ ហើយលោកស្រីមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលក្បាលមីក្រូហ្វូន ដាក់ងាកឲ្យផុតពីគាត់បន្តិច ដើម្បីឲ្យគាត់មានលទ្ធភាពអាចមើលនូវភ្លើងក្រហមនៅក្បាលមីក្រូហ្វូនហ្នឹងបាន។

និយាយឆ្ងាយក៏មិនអីដែរ យើងនិយាយចម្ងាយនេះក៏ឮដែរ លោកមិនបាច់ងាកទៅអ៊ីចឹងទេ លោកនិយាយធម្មតាហ្នឹងក៏ឮដែរ ចម្ងាយកន្លះម៉ែត្រប៉ុណ្ណឹងក៏ឮដែរណា។

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** លោក រស់ ស៊ុយ តើសព្វថ្ងៃលោកប្រកបមុខរបររកស៊ីធ្វើអ្វី?

**ឆ៖** ជម្រាបលោកប្រធាន ខ្ញុំបាទសព្វថ្ងៃរបររកស៊ីធ្វើស្រែចម្ការទេបាទ។

[០៩:១៣:០៧]

**ស៖** បាទ អរគុណ។ តើលោកអាចប្រាប់នូវឈ្មោះឪពុកម្តាយបង្កើតដល់អង្គជំនុំជម្រះដែរឬទេ តើគាត់ឈ្មោះអី?

**ឆ៖** បាទ សូមជម្រាបលោកប្រធាន ខ្ញុំបាទឈ្មោះ រស់ ស៊ុយ។ ឪពុកម្តាយ, ឪពុកឈ្មោះ រស់

រស់ ព្រាម ម្ដាយឈ្មោះ ហ៊ីម ផ្គុក។

**ស៖** ចុះប្រពន្ធរបស់លោកគាត់ឈ្មោះអី? ហើយលោកមានកូនប៉ុន្មាននាក់?

**ឆ៖** បាទលោកប្រធាន ប្រពន្ធខ្ញុំបាទឈ្មោះ សុខ សិ ហើយខ្ញុំបាទមានកូនប្រាំមួយនាក់ ប្រុសបួននាក់ ស្រីពីរនាក់បាទ។

**ស៖** បាទ អរគុណ។ ហើយលោក រស់ ស៊ុយ តាមរបាយការណ៍របស់ក្រឡាបញ្ជីសវនាការរាយការណ៍អម្បាញ់មិញនេះ ថាតាមសមត្ថភាពដែលលោកអាចដឹង គឺលោកមិនមានចំណងញាតិលោហិត ឬក៏ញាតិពន្ធជាមួយនឹងបុគ្គលទាំងឡាយ ដែលត្រូវទទួលយកជាដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងក្ដីនេះទេ។ ហើយក៏មិនជាប់ញាតិលោហិត ឬក៏ញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូបដែរ គឺលោក នួន ជា និងលោក ខៀវ សំផន។ តើរបាយការណ៍នេះពិតដែរឬទេ?

[០៩:១៤:២៤]

**ឆ៖** សូមជម្រាបលោកប្រធាន របាយការណ៍ដែលខ្ញុំផ្ដល់ជូនកន្លងមកនេះ គឺមួយចំនួនវាជារឿងពិត តែមួយចំនួនទៀតគ្រាន់តែវាជារឿងពិតដែរ តែខ្ញុំបាទមិនអាចចាំពេលវេលាពិតប្រាកដបាន។

**ស៖** យើងចង់ដឹងថាតើលោកមានចំណងជាតិលោហិត ឬញាតិពន្ធជាមួយនឹងភាគីនៃរឿងក្ដីនេះដែរឬទេ? ទាំងខាងដើមបណ្ដឹងរដ្ឋប្បវេណី ទាំងខាងជនជាប់ចោទទាំងពីររូប គឺលោក នួន ជា និងលោក ខៀវ សំផន។ តើលោកមានចំណងញាតិលោហិត ឬក៏ញាតិពន្ធ, ញាតិពន្ធហ្នឹងបានន័យថាសាច់ថ្លៃ, ពាក់ព័ន្ធដែរឬទេ? ព្រោះក្រឡាបញ្ជីបានរាយការណ៍អម្បាញ់មិញថា លោកគ្មានចំណងញាតិលោហិត ឬក៏ញាតិពន្ធជាមួយនឹងភាគីនៃរឿងក្ដីនេះទេ?

**ឆ៖** បាទ សូមជម្រាបលោកប្រធាន ខ្ញុំបាទអត់មានជាប់សាច់សាលោហិតជាមួយនឹងដើមបណ្ដឹងរដ្ឋប្បវេណី ឬក៏លោក នួន ជា ឬក៏លោក ខៀវ សំផន នេះទេបាទ។

**ស៖** បាទ អរគុណ។ ហើយរបាយការណ៍ដដែលថា លោកបានធ្វើសម្បថនៅចំពោះមុខអ្នកតាដំបងដែកដែលនៅពីខាងកើតបន្ទប់សវនាការនេះរួចហើយ មុនពេលដែលលោកចូលមកកាន់កន្លែងផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះ។ តើពិតមែនដែរទេ?

**ឆ៖** បាទ សូមជម្រាបលោកប្រធាន ពិតមែនដែលខ្ញុំបានស្បថមែនហើយបាទ។

**ស៖** បាទអរគុណ។ ហើយអង្គជំនុំជម្រះសូមជម្រាបអំពីសិទ្ធិ និងករណីយកិច្ចក្នុងនាមលោកជាសាក្សី ក្នុងនាមជាសាក្សីនៅចំពោះមុខអង្គជំនុំជម្រះនេះ។ លោក រស់ ស៊ុយ គឺលោកមានសិទ្ធិក្នុងការ

បដិសេធឆ្លើយតបទៅនឹងសំណួរ ឬក៏សុំឲ្យលោកធ្វើអត្ថាធិប្បាយណាមួយ ឬច្រើនដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងខ្លួនឯង។ ហើយទន្ទឹមនឹងនេះ គឺលោកក្នុងនាមជាសាក្សីមានករណីយកិច្ចត្រូវឆ្លើយតបទៅនឹងសំណួរទាំងឡាយដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោក លើកលែងតែករណីសិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង។ ហើយក្នុងនាមជាសាក្សី លោកត្រូវតែឆ្លើយតែការណ៍ណាដែលពិត ដែលលោកបានឃើញ បានដឹង បានឮ បានចាំ បានធ្លាប់មានបទពិសោធន៍ជួបប្រទះ ឬក៏ខ្វះការធ្វើសង្កេតដោយផ្ទាល់នូវព្រឹត្តិហេតុ ហេតុការណ៍ទាំងឡាយដែលពាក់ព័ន្ធទៅនឹងសំណួរដែលភាគី ឬក៏ចៅក្រមនៃអង្គជំនុំជម្រះសួរលោក។ តើលោកយល់ទេអំពីសិទ្ធិ និងករណីយកិច្ចក្នុងនាមលោកជាសាក្សីនេះ?

[០៩:១៦:៥៥]

**ឆ៖** បាទ សូមជម្រាបលោកប្រធាន ខ្ញុំបាទអាចស្គាល់ ហើយអាចយល់បានលោក។

**ស៖** បាទអរគុណ។ ហើយលោក រស់ ស៊ុយ តើលោកមានដែលធ្លាប់ផ្តល់សក្ខីកម្មជាមួយអ្នកស៊ើបអង្កេតជាមួយអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតដែរឬទេកន្លងមក? ហើយប្រសិនបើមាន តើការធ្វើសម្ភាសន៍នោះប្រព្រឹត្តទៅនៅប៉ុន្មានលើក នៅកន្លែងណា ហើយធ្វើនៅពេលណា?

**ឆ៖** សូមជម្រាបលោកប្រធាន គឺខ្ញុំមិនអាចចាំថ្ងៃបានទេលោកប្រធាន ពីព្រោះដោយសារតែខ្ញុំមិនបានយកចិត្តទុកដាក់ពីរឿងថ្ងៃខែ កត់ត្រាទុកទេ ក៏ប៉ុន្តែគ្រាន់តែខ្ញុំធ្លាប់បានផ្តល់សក្ខីកម្មជាមួយនឹងក្រុមការងារដែលបានទៅចុះជាមួយនឹងខ្ញុំនៅឆ្នាំ២០០២ និងឆ្នាំ២០០៨ ខ្ញុំធ្លាប់បានជួបផ្តល់សក្ខីកម្មជូនគាត់ហើយបាទ។

**ស៖** ហើយមុនពេលចូលមកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការចំពោះមុខអង្គជំនុំជម្រះនេះ តើលោកបានពិនិត្យមើល ឬក៏បានអាន ឬក៏បានការស្តាប់ការអានពីបុគ្គលណាម្នាក់នៅសក្ខីកម្មដែលលោកបានផ្តល់ជូនទៅអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតកន្លងមកដែរឬទេ ដើម្បីរំឭកការចងចាំ?

[០៩:១៨:២៤]

**ឆ៖** សូមជម្រាបលោកប្រធាន ខ្ញុំបានពិនិត្យ ហើយនិងពិចារណារួចហើយបាទ។

**ស៖** ហើយតាមការចងចាំរបស់លោក ហើយនិងសមត្ថភាពដែលលោកអាចយល់បាន តើលោកពិនិត្យឃើញថា សក្ខីកម្មដែលលោកបានផ្តល់កន្លងមក ហើយនិងលោកបានអានហ្នឹង តើវាស្រប

សមស្របដូចគ្នាឬទេនូវអ្វីដែលលោកបានផ្តល់សក្ខីកម្មលើកមុន និងឯកសារដែលលោកបានពិនិត្យមើលមុននឹងចូលមកផ្តល់សក្ខីកម្មនៅពេលនេះ?

**ឆ៖** បាទ សូមជម្រាបលោកប្រធាន ខ្ញុំបានពិនិត្យរួចហើយបាទ។

**ស៖** វាសមស្របជាមួយនឹងអ្វីដែលលោកបានឆ្លើយពីមុនដែរឬទេ តាមការចងចាំរបស់លោកដែលលោកអាចចងចាំបាននោះ?

**ឆ៖** បាទ ជម្រាបលោកប្រធាន ស្របនឹងការផ្តល់ចម្លើយនោះហើយបាទ។

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ ជាបន្តនេះអង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក ខៀវ សំផន ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។ សូមអញ្ជើញ!

[០៩:១៩:៤៨]

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

ជម្រាបសួរលោកសាក្សី! ខ្ញុំឈ្មោះ អង់តា ហ្គីសសេ ខ្ញុំជាសហមេធាវីអន្តរជាតិការពារលោក ខៀវ សំផន ជាមួយនឹងលោក គង់ សំអុន។ យើងនឹងចាប់ផ្តើមដោយការសួរសំណួរទៅកាន់លោក។ ខ្ញុំសូមជម្រាបលោកថា យើងមានផ្នែកបកប្រែ។ ដូច្នេះ សូមឱ្យលោកមេត្តាឆ្លើយយឺតៗ មួយៗ ដើម្បីឱ្យអ្នកដែលមិននិយាយភាសាខ្មែរនុ៎ង អាចតាមនូវចម្លើយរបស់លោកបាន។

**ស៖** សំណួររបស់ខ្ញុំ គឺពាក់ព័ន្ធទៅនឹងការសម្ភាសដូចដែលលោកបានជម្រាបជូនអង្គជំនុំជម្រះ។ លោកបានឆ្លើយថា ត្រូវបានគេសម្ភាសពីរលើក គឺការិយាល័យសហចៅក្រមស៊ើបអង្កេតនោះ បានសម្ភាសលោកពីរលើក។ អ៊ីចឹង ខ្ញុំបានការបញ្ជាក់លោកចំពោះចំណុចនេះ។ លោកបានបញ្ជាក់ថា ម្តងនៅ២០០២ និងក្រោយមកនៅ២០០៨ ប៉ុន្តែនៅក្នុងសំណុំរឿងរបស់យើងនោះ គឺយើងមានកំណត់ហេតុស្តាប់ចម្លើយរបស់លោកតែមួយទេ។ ក៏ប៉ុន្តែលោកគឺបានសម្ភាសជាមួយនឹងមជ្ឈមណ្ឌលឯកសារកម្ពុជា។ តើលោកចាំទេថា មានបុគ្គលិកអង្គការមជ្ឈមណ្ឌលឯកសារកម្ពុជានោះ សម្ភាសលោក?

[០៩:២១:២៥]

**លោក រស់ ស៊ុយ៖**

**ឆ៖** បាទ សូមជម្រាបលោកមេធាវី គឺកន្លងមកមានការសម្ភាសមែន។ ប៉ុន្តែដូចអ្វីដែលខ្ញុំបាន

ជម្រាបអ៊ីចឹង ព្រោះថាគឺខ្ញុំបានជម្រាបជូនហយើថា ខាងស៊ើបអង្កេត មិនមែនជាកន្លែងស្រាវជ្រាវទេ ដែលបានទៅសម្ភាសជាមួយខ្ញុំនោះ ព្រោះបើសួរពីសម្ភាសជាមួយនឹងខាងស្រាវជ្រាវ ខ្ញុំនឹងជម្រាបជូនបាន។

**ស៖** នៅពេលដែលលោកឆ្លើយថា លោកបានសម្ភាសជាមួយនឹងអ្នកស្រាវជ្រាវ ហើយនិងអ្នកអង្កេត។ អ៊ីចឹងខ្ញុំអាចយល់បានថា គឺជាការសម្ភាសពីរដងបន្តបន្ទាប់គ្នា មិនមែននៅក្នុងពេលជាមួយគ្នាទេ។ តើចម្លើយរបស់លោកមានន័យ អ៊ីចឹងមែនទេ?

**ឆ៖** បាទៗ។

**ស៖** លោកបានបញ្ជាក់ថាអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតបានសម្ភាសលោកនៅឆ្នាំ២០០៨។ យើងមានកំណត់ហេតុស្តាប់ចម្លើយនេះ គឺនៅថ្ងៃទី១៤ ខែមីនា ឆ្នាំ២០០៨។ ដូច្នេះនៅពេលដែលខ្ញុំនិយាយអំពីថ្ងៃទី១៤ ខែមីនា ឆ្នាំ២០០៨នេះ ធ្វើឲ្យលោកនឹកឃើញធ្លាប់បានសម្ភាសជាមួយនឹងអ្នកស៊ើបអង្កេតនៅថ្ងៃនុ៎ងដែរឬទេ?

[០៩:២៣:០៥]

**ឆ៖** បាទ សូមជម្រាបលោកប្រធានមេធាវី ខ្ញុំបានសម្ភាសមែន បាទ។

**ស៖** ចុះចំពោះការសម្ភាសជាមួយនឹងអ្នកស្រាវជ្រាវមជ្ឈមណ្ឌលឯកសារកម្ពុជា លោកចាំថាសម្ភាសជាមួយមជ្ឈមណ្ឌលហ្នឹងមុន ឬក៏ក្រោយពេលសម្ភាសជាមួយនឹងការិយាល័យសហចៅក្រមស៊ើបអង្កេត?

**ឆ៖** បាទ កាលពី -- ខ្ញុំសូមជម្រាបដែរថា គឺសម្ភាសខាងស្រាវជ្រាវហ្នឹងមុន បាទ។

**ស៖** ដូច្នេះ គឺថាមានការសម្ភាសពីរ ដាច់ដោយឡែកពីគ្នា ហើយនៅកាលបរិច្ឆេទពីរផ្សេងគ្នាជាមួយនឹងអ្នកស្រាវជ្រាវនុ៎ង គឺមានន័យថា លោកសម្ភាសពីរដងជាមួយអ្នកស្រាវជ្រាវនៃមជ្ឈមណ្ឌលឯកសារកម្ពុជា តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ សម្ភាសអ៊ីចឹងមែន បាទ។

**ស៖** នៅពេលសម្ភាសលើកទី១ ជាមួយអ្នកស្រាវជ្រាវនៃមជ្ឈមណ្ឌលឯកសារកម្ពុជា តើអ្នកសម្ភាសលោកហ្នឹង ជាអ្នកស្រាវជ្រាវជនជាតិខ្មែរ ឬក៏ពួកបស្ចិមប្រទេស?

[០៩:២៤:៣៥]

**ឆ៖** សូមជម្រាបថា កាលពីសម្ភាសលើកទីមួយហ្នឹង គឺមានតែខ្មែរទេ ដែលគាត់ស្រាវជ្រាវពី

ប្រវត្តិអ្នកដែលសល់ពីជំនាន់នោះ គឺសុទ្ធតែខ្មែរសុទ្ធទេ ដែលទៅសម្ភាសជាមួយខ្ញុំបាទ។

**ស៖** សូមអរគុណ។ ចុះនៅពេលសម្ភាសលើកទីពីរ ជាមួយអ្នកស្រាវជ្រាវនោះ តើមានអ្នកសម្ភាសផ្សេងទៀត ជាជនបរទេសដែរឬទេ? ហើយលោកចាំទេថាបើសិនជាមានជនបរទេស តើជនបរទេសរូបនោះឈ្មោះអ្វីដែរ?

**ឆ៖** សូមជម្រាប ខ្ញុំមិនអាចចាំបានទេ ពីព្រោះខ្ញុំជាកសិករមិនអាចគិតថាពីរឿងហ្នឹងវាមកដល់ថ្ងៃនេះដល់ប៉ុណ្ណឹងទេបាទ។

**ស៖** មិនជាបញ្ហាអ្វីទេ។ ខ្ញុំព្យាយាមរំឭកការចាំ ចងចាំរបស់លោក តើលោកនៅពេលដែលខ្ញុំនិយាយថា ស្ទីវ ហេដឌ័រ តើធ្វើឲ្យលោកនឹកឃើញអ្វីមួយទេ?

**ឆ៖** សូមជម្រាបដែរថា អ្វីដែលខ្ញុំនៅចងចាំ គឺសូមជម្រាបថាមិនអាចចាំបានទាំងអស់ទេ ពីព្រោះជីវភាពខ្ញុំជាកសិករ គឺមិនសូវចាប់អារម្មណ៍ពីបញ្ហាការស្រាវជ្រាវពីបញ្ហាការងារដែលអ្វីដែលកន្លងហួសទៅហើយនោះ គឺខ្ញុំមិនសូវយកចិត្តទុកដាក់ទេ។ សូមជម្រាបលោកប្រធានអ៊ីចឹង។

[០៩:២៦:២៦]

**ស៖** មិនជាបញ្ហាអ្វីទេលោកសាក្សី។ យើងនឹងត្រឡប់មកនិយាយអំពីចំណុចនេះវិញ។ យើងមានប្រតិចារឹកនៃកិច្ចសម្ភាសន៍ទាំងពីរនុ៎ង ពីព្រោះថាកិច្ចសម្ភាសន៍នុ៎ងត្រូវបានធ្វើជាការកំណត់ត្រាថតសំឡេងត្រឹមត្រូវ។ ប្រហែលជាខ្ញុំសួរទៅប្រហែលមិនច្បាស់។ ខ្ញុំចង់ដឹងថាតើលោកមានចាំទេនៅពេលនុ៎ងថា ការសម្ភាសរបស់លោកនុ៎ង ត្រូវបានគេថតជាសំឡេង?

**ឆ៖** សូមជម្រាបថា ខ្ញុំដឹងថាគេថតសំឡេងហើយ ក៏ប៉ុន្តែគ្រាន់តែខ្ញុំមិនសូវយកចិត្តទុកដាក់រឿងថាអស់លោកថត ហើយនិងសម្ភាសទេ។

**ស៖** សូមអរគុណលោកសាក្សី។ ឥឡូវនេះ ខ្ញុំចង់និយាយអំពីខ្សែជីវិតផ្ទាល់ខ្លួនរបស់លោកបន្តិច លោកបានបញ្ជាក់ថា លោកជាកសិករ។ ខ្ញុំចង់ដឹងថា តើលោកមានធ្លាប់បានរៀនសរសេរ និងរៀនអានទេ?

**ឆ៖** បាទ ខ្ញុំធ្លាប់បានរៀនសរសេរ និងរៀនអាន។ បើនិយាយពីដើមមុនឆ្នាំ៧០ ខ្ញុំធ្លាប់បានរៀនដល់ថ្នាក់ទី៧ដែរបាទ។ អាចសរសេរបាន ហើយអាចមើលរួចខ្លះ។

[០៩:២៨:៣៦]

**ស៖** តើលោកចូលបដិវត្តន៍នៅពេលណា? ហើយចូលដោយសារមូលហេតុអ្វី?

**ឆ៖** ខ្ញុំសូមជម្រាបលោកថា ខ្ញុំចូលរួមក្នុងចលនាតស៊ូរបស់ខ្មែរយើងនេះនៅចុងឆ្នាំ៧០ ក្រោយមកខ្ញុំបានចេញចូលមកលេងផ្ទះ។ កាលពីមុនខ្ញុំនៅធ្វើកងទ័ពជាមួយវៀតណាម បន្ទាប់មកក៏ខ្ញុំចេញពីវៀតណាមមកទៅចូលជាមួយនឹងអង្គការខ្មែរ គឺថ្ងៃ១៥ ខែមេសា ឆ្នាំ១៩៧៣។

**ស៖** នៅពេលដែលលោកបាននិយាយថា លោកបានចូលរួមក្នុងចលនាតស៊ូនោះ គឺមានន័យថាក្នុងកងទ័ពផ្សេង ក្រៅពីកងទ័ពខ្មែរក្រហមមែនទេ នៅពេលដែលលោកថាចូលនៅចុងឆ្នាំ៧០នោះ? លោកចូលជាមួយកងទ័ពអ្វីដែរ?

**ឆ៖** នៅកងទ័ពវៀតណាម។ ពេលនោះកងទ័ពវៀតណាមមកជួយរំដោះកម្ពុជាយើង។

**ស៖** លោកបានន័យថា លោក -- លោកបានឆ្លើយថាលោកចូលខ្មែរក្រហមនៅឆ្នាំ៧៣។ អ៊ីចឹងខ្ញុំចង់ដឹងថាហេតុអីបានជាលោកចេញពីកងទ័ពខ្មែរក្រហមមកចូលជាមួយនឹង -- ចេញពីកងទ័ពវៀតណាមមកចូលជាមួយកងទ័ពខ្មែរក្រហម?

**ឆ៖** នេះសូមជ្រាបដែរថា ដោយវាមានមូលហេតុខ្លះ ដោយយល់ឃើញថាមានខ្មែរហើយនិងខ្មែរទេដែលអាចរកសន្តិភាព ហើយខ្មែរនិងខ្មែរទេដែលអាចយល់គ្នា ពីព្រោះកងទ័ពវៀតណាម ពេលដែលវ៉ៃម្តងៗគាត់ចេះតែដកចោលខ្មែរ គាត់ឲ្យខ្មែរនៅមួយក្រុម គាត់នៅមួយក្រុម ដល់តែពេលសមរភូមិតឹងតែងគាត់ដកចោលខ្មែរ។ អានេះហើយជាមូលហេតុដែលខ្ញុំត្រូវចាកចេញពីកងទ័ពវៀតណាម ដើម្បីទៅរស់នៅ ឬក៏ទៅចូលរួមជាមួយនឹងកងទ័ពខ្មែរវិញ។

[០៩:៣១:១៤]

**ស៖** តើមានមូលហេតុអ្វីផ្សេងទៀតទេ ក្រៅពីមូលហេតុដែលលោកទើបតែឆ្លើយអម្បាញ់មិញនេះ?

**ឆ៖** សូមជម្រាបថាអត់មានមូលហេតុអីក្រៅពីហ្នឹងទេបាទ។

**ស៖** ខ្ញុំសូមបង្ហាញនូវសម្រង់មួយជូនលោក គឺកំណត់ហេតុស្តាប់ចម្លើយរបស់លោកជាមួយនឹងមជ្ឈមណ្ឌលឯកសារកម្ពុជានៅថ្ងៃទី១៩ ខែសីហា ឆ្នាំ២០០៣។ ឯកសារនេះគឺមានលេខ 19.58 សូមទោសគឺ 19.158, ERN ជាភាសាបារាំង 00899429, ERN ជាភាសាខ្មែរ 00008258, ERN ជាភាសាអង់គ្លេស 00710492។ នេះគឺជាកិច្ចសម្ភាសន៍លើកទី១ របស់លោកជាមួយនឹងមជ្ឈមណ្ឌលឯកសារកម្ពុជា។ នៅក្នុងឯកសារនោះ--

**ប្រធានអង្គជំនុំ៖**

ផ្អាកបន្តិចសិនលោកស្រីមេធាវី!

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

លោកមេធាវី -- លោកស្រីមេធាវី អង់តា ហ្គីសសេ ខ្ញុំចង់បានការបញ្ជាក់ឲ្យបានច្បាស់។ លោកស្រីបានយោងទៅលើឯកសារមួយដែលជាឯកសារឧបសម្ព័ន្ធនៃដីកាបញ្ជូនរឿងឲ្យស៊ើបសួរ។ ដូច្នេះខ្ញុំចង់ដឹងថាតើឯកសារនេះមានដាក់ឲ្យពិភាក្សាដេញដោលហើយឬនៅ? ហើយឯកសារនេះមាននៅក្នុងបញ្ជីរបស់ភាគីឬទេ? ឬក៏ហើយមានដាក់នៅក្នុង*អាំងទែរហ្វាស* ប្រចាំថ្ងៃសម្រាប់ការសួរសំណួរនៅថ្ងៃនេះទេ? ហើយតើភាគីបានដឹងអំពីឯកសារនេះដែរឬទេ?

**កញ្ញា អង់តា ហ្គីសសេ៖**

លោកចៅក្រម គឺយើងបានដាក់នៅក្នុង*អាំងទែរហ្វាស*រួចហើយ។ នេះគឺជាចម្លើយមុនៗរបស់សាក្សី ដែលគឺថាការសម្ភាសនោះមានពីរជាមួយនឹងមជ្ឈមណ្ឌលឯកសារកម្ពុជា។ ដូច្នេះ នេះជាចម្លើយមុនៗរបស់សាក្សី ហើយយើងបានផ្តល់ជូនទៅដល់ភាគីរួចទៅហើយ ហើយដាក់នៅក្នុង*អាំងទែរហ្វាស*រួចទៅហើយ។

[០៩:៣៤:១០]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ដូច្នេះ តើឯកសារនេះមានដាក់នៅក្នុងបញ្ជីនៃឯកសារ ដែលនឹងដាក់ឲ្យពិភាក្សាដេញដោលឬទេ? ហើយអង្គជំនុំជម្រះបានសម្រេចទៅលើឯកសារនេះរួចហើយឬនៅ? ឬក៏ឯកសារនេះជាឯកសារថ្មី? ដូច្នេះយោងថាវិធានផ្ទៃក្នុងនោះ ថាតើភាគីឯកភាពចំពោះការប្រើប្រាស់ឯកសារនេះដែរឬទេ?

**កញ្ញា អង់តា ហ្គីសសេ៖**

លោកចៅក្រម ខ្ញុំមិនដឹងថាតើឯកសារនេះមាននៅក្នុងបញ្ជីហើយឬនៅទេ ប៉ុន្តែឯកសារនេះគឺជាចម្លើយមុនៗរបស់សាក្សី ដូច្នេះខ្ញុំគិតថាមិនមានការលំបាកអ្វីទេ។ ប៉ុន្តែប្រសិនបើមានការលំបាកនោះខ្ញុំទុកវេទិកានេះឲ្យភាគីដើម្បីបញ្ចេញមតិយោបល់លើការប្រើប្រាស់ឯកសារនេះ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។ ជាការពិតណាស់ ខ្ញុំយល់ស្របជាមួយនឹងឯកសារហ្នឹង គឺថាឯកសារហ្នឹងដាក់នៅលើ *អ៊ីនធើហ្វេស* ដោយមេធាវីការពារក្តី ក៏ដូចជាក្រុមព្រះរាជអាជ្ញាដែរ ប៉ុន្តែខ្ញុំអត់ទាន់បានមើលទៅតាម*ណោតរើក*ទេនៅថ្ងៃនេះ។ ហើយខ្ញុំដឹងថា ឥឡូវនេះឯកសារនេះស្ថិតនៅក្រោមបញ្ជីតាមវិធានទី៨០របស់យើង។ ដូច្នេះខ្ញុំគិតថា វាមិនមែនជាកំហុសតែខាងមេធាវីទេ ព្រោះយើងបានដាក់ដោយយើងផងដែរ ហើយឯកសារនេះគឺយើងបានរៀបចំ ហើយដាក់នឹងនៅប្រហែលជា២សប្តាហ៍មុននេះ។ ដូច្នេះនេះគឺជាព័ត៌មានដែលខ្ញុំចង់ជូនទៅដល់អង្គជំនុំជម្រះ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមអរគុណ។ សូមអញ្ជើញលោកស្រីសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

សូមអរគុណលោកប្រធាន។ ប្រសិនបើឯកសារនេះមាននៅក្នុងបញ្ជីហើយ ខ្ញុំគិតថាមិនមានការលំបាកអ្វីទេ ក៏ប៉ុន្តែដើម្បីឲ្យយុត្តិធម៌នោះ គឺថាខ្ញុំសូមឲ្យអង្គជំនុំជម្រះអនុវត្តដូចៗគ្នាចំពោះឯកសារទាំងអស់ ក៏ប៉ុន្តែឯកសារមាននៅក្នុងឯកសាររបស់សហព្រះរាជអាជ្ញារួចទៅហើយ។ ខ្ញុំសង្ឃឹមបែបនេះទៅចុះ។

[០៩:៣៦:៣០]

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ខាងក្រុមខ្ញុំបានប្រាប់ខ្ញុំថា ឯកសារនេះគឺពិតជាមាននៅក្នុងបញ្ជីរបស់សហព្រះរាជអាជ្ញាមែន ហើយសូមអភ័យទោសផងដែលខ្ញុំមិនបានផ្តល់ព័ត៌មាននេះជាមុននោះ។ ដូច្នេះ លោកប្រធាន តើលោកប្រធានអនុញ្ញាតឲ្យខ្ញុំបន្តសួរសំណួរពាក់ព័ន្ធនឹងឯកសារនេះដែរឬទេ?

**ប្រធានអង្គជំនុំ៖**

អនុញ្ញាត សូមអញ្ជើញ!

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** លោកសាក្សី! ជាធម្មតា តើការដកស្រង់ត្រូវតែបញ្ជាក់នៅលើអេក្រង់ទូរទស្សន៍ ខ្ញុំបានបញ្ជាក់ជូននូវលេខ ERN រួចមកហើយ។ នេះជាចម្លើយដែលលោកបានផ្តល់ជូនមជ្ឈមណ្ឌលកម្ពុជា -- ឯកសារកម្ពុជានៅឆ្នាំ២០០៣ “ខ្ញុំចូលកងទ័ពវៀតណាម ដែលវ៉ៃនៅតាមទន្លេបាសាក់”។

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន តើខ្ញុំអាចទទួលបានការអនុញ្ញាតពីលោកប្រធាន ដើម្បីដាក់បញ្ចាំងឯកសារនេះនៅលើអេក្រង់កុំព្យូទ័រដើម្បីឲ្យសាក្សីគាត់ពិនិត្យមើលបានដែរឬទេលោក?

**ប្រធានអង្គជំនុំ៖**

ដាក់ដូចធ្លាប់អនុវត្តកន្លង ហើយដើម្បីបង្ហាញទៅ ប្រសិនបើសាក្សីឆ្លើយថាមិនដែលបានឃើញឯកសារហ្នឹងទេ គឺអាចដកយកវិញ។ អានេះធ្លាប់បានភាគីដឹងហើយ។ អ៊ីចឹងមុននឹងដាក់លើអេក្រង់កុំព្យូទ័រ សូមលោកស្រីបង្ហាញឯកសារនេះចំពោះសាក្សីនេះជាមុនសិន ដើម្បីឲ្យសាក្សីពិនិត្យឯកសារនោះជាមុនសិន ដើម្បីថាតើគាត់បានស្គាល់នុ៎ងដែរឬទេ? ហើយបើមិនធ្លាប់ទេ តម្រូវឲ្យដកចេញវិញ ហើយមិនអនុញ្ញាតឲ្យបង្ហាញឯកសារនៅលើអេក្រង់កុំព្យូទ័រទេ។

[០៩:៣៨:៥២]

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន នេះគឺថាដើម្បីសម្រួលការងារទេ គឺថាឯកសារនេះគឺជាការប្រតិចារឹកចេញពីខ្សែអាត់។ ដូច្នេះ ខ្ញុំមិនដឹងថា សាក្សីគឺថាគាត់ប្រាកដជាមិនដែលឃើញឯកសារនេះហើយ។ ដូច្នេះខ្ញុំគ្រាន់តែយកខ្លឹមសារនេះមកសួរគាត់ ដើម្បីឲ្យគាត់នឹកឃើញឡើងវិញនូវការសម្ភាសរបស់គាត់។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** លោកសាក្សី អម្បាញ់មិញនេះលោកបានឆ្លើយថា មានគេថតសំឡេងរបស់លោកនៅពេលដែលលោកសម្ភាសជាមួយនឹងមជ្ឈមណ្ឌលឯកសារកម្ពុជា។ ដូច្នេះសំណួររបស់ខ្ញុំនោះ គឺខ្ញុំចង់ដឹងថា តើលោកធ្លាប់ឃើញប្រតិចារឹកនៃខ្សែអាត់សម្ភាសរបស់លោកនេះទេ?

**លោក រស់ ស៊ុយ៖**

**ឆ៖** ខ្ញុំ ចំណុចខ្លះខ្ញុំមិនអាចចងចាំបានទេ ពីព្រោះដោយសារ ដូចខ្ញុំបានជម្រាបជូនអ៊ីចឹងថា ខ្ញុំរវល់តែគិតពីរឿងជីវភាពផ្ទាល់ខ្លួនក្នុងគ្រួសារបាទ។ ដូច្នេះចំណុចខ្លះ គឺខ្ញុំអាចបានសម្ភាសមែន តែខ្ញុំមិនអាចចងចាំបានទេ បាទ។

**ស៖** ខ្ញុំអាចសន្និដ្ឋានបានថា លោកមិនដែលឃើញប្រតិចារឹកនៃឯកសារនេះទេ។ ដូច្នេះ ខ្ញុំចង់ដឹងថា សូមទោស គឺថានៅពេលខ្ញុំ -- ខ្ញុំនឹងអានខ្លឹមសារ ហើយខ្ញុំនឹងសួរលោក។ យើងដឹងហើយថា លោកមិនអាចចងចាំនូវព័ត៌មានលម្អិតទាំងអស់នោះទេ យើងគ្រាន់តែបង្ហាញនេះ គឺថាដើម្បីឲ្យលោកនឹក

ឃើញឡើងវិញ។ នេះគឺជាចម្លើយរបស់លោកនៅឆ្នាំ២០០៣ ជាមួយនឹងមជ្ឈមណ្ឌលឯកសារកម្ពុជា។ លោកបានឆ្លើយទៅនឹងអ្នកស្រាវជ្រាវដែលបានសួរលោកថា លោកឆ្លើយថា “ក្រោយពីខ្ញុំទៅវាយជាមួយនឹងវៀតណាមនៅតាមជួរដងទន្លេបាសាក់នោះ ដល់តែគេធ្វើបាបខ្លាំងពេក ក៏ខ្ញុំសម្រេចរត់ចោលវៀត-ណាមមក”។ ដូច្នេះ ឥឡូវនេះ ខ្ញុំចង់សួរបញ្ជាក់លោកឲ្យច្បាស់ថា លោកមាននឹកឃើញឡើងវិញហើយឬនៅ អំពីថាមូលហេតុអ្វីបានជាលោករត់ចោលកងទ័ពវៀតណាម? ហើយមកចូលរួមជាមួយនឹងកងទ័ពខ្មែរក្រហម?

[០៩:៤១:២៣]

**ឆ៖** បាទ សូមជម្រាបថា ចំណុចខ្លះខ្ញុំនៅចង់ចាំបាន ត្រង់ចំណុចមួយថា ដល់ ដូចខ្ញុំបានជម្រាបជូនពីខាងដើម ដែលខ្ញុំថាសម្រេចចិត្តនឹងចាកចេញពីកងទ័ពវៀតណាមហើយ ដោយសារតែគេធ្វើបាប ដូចខ្ញុំបានជម្រាបជូនខាងលើអ៊ីចឹង។ ដូច្នេះ គឺខ្ញុំគ្រាន់តែខ្ញុំមិនបានជម្រាបជូនលម្អិត តែគ្រាន់តែខ្លឹមសារសំខាន់ គឺត្រង់ថា អ្វីដែលខ្ញុំចង់ចេញ គឺខ្ញុំនិយាយខ្លីប៉ុណ្ណឹងទេ បាទ។

**ស៖** សូមអរគុណលោក រស់ ស៊ុយ។ ឥឡូវនេះ ខ្ញុំនិយាយអំពីចំណុចផ្សេងទៀត។ លោកបានបញ្ជាក់ថា នៅឆ្នាំ១៩៧៣ លោកបានចូលរួមក្នុងចលនាខ្មែរក្រហម។ តើនៅឆ្នាំ១៩៧៣ ទៅដល់ខែមេសា ឆ្នាំ១៩៧៥ លោកមានតួនាទីអ្វីនៅក្នុងកងទ័ពខ្មែរក្រហម?

**ឆ៖** សូមជម្រាបលោកមេធាវី កាលពីថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៧៣ ខ្ញុំក្រោយពីចេញពីកងទ័ពវៀតណាមទៅ ខ្ញុំសម្រេចចិត្តទៅស្រាវជ្រាវរកកងទ័ពខ្មែរ ក្រោយ -- ហើយកាលដែលខ្ញុំចេញទៅ គឺអត់មានគោលដៅថានៅត្រង់ណាទេ។ ក្រោយពីទៅជួបក្នុងភូមិមួយ គេហៅថា ភូមិអង្គស្វាយចេក ដល់ជួបអង្គភាពមួយនៅកន្លែងហ្នឹង ដល់ក្រោយមកខ្ញុំក៏សាកសួរទៅ ខ្ញុំក៏ចូលនៅជាមួយគាត់។ ហើយក្នុងបំណងទីមួយ គឺទៅធ្វើកងទ័ពទេ។ ហើយដល់ក្រោយមកទៀត ក្រោយពីបានទៅជាមួយគ្នាហ្នឹងទៅ យូរៗទៅត្រូវបានគេចែក -- នេះខ្ញុំសូមនិយាយឲ្យខ្លីមកវិញថា គេត្រូវបានចាត់ឲ្យខ្ញុំទៅខាងអង្គភាពខាងសេដ្ឋកិច្ច។ នៅពេលនោះ ខ្ញុំមានឋានៈមួយជាមេក្រុម។ តែមេក្រុមហ្នឹង គឺកម្លាំងមានអត់ទៀង ដោយសារអី? ដោយសារថា នេះ ខ្ញុំនិយាយពីឆ្នាំ៧៣ រហូតទៅដល់ឆ្នាំ៧៥ ពេលដែលខ្ញុំនៅក្នុងអង្គភាពសេដ្ឋកិច្ច។

[០៩:៤៣:៣៧]

គឺចំណុចមួយ គឺពេលដែលខ្ញុំទៅនៅកន្លែងហ្នឹង គឺក្នុងឋានៈខ្ញុំជាមេក្រុម។ ហើយមេក្រុមនោះមានកម្លាំងអត់ទៀងទេ ជួនពេលខ្លះឡើងទៅដល់៥០នាក់ ហើយកម្លាំងហ្នឹង សួរថាបានមកពីណាកម្លាំង

ហ្នឹង? កម្លាំងហ្នឹង បានមកពីក្រោយពីដែលគេជម្រុះ ឬក៏គេឲ្យព្រះសង្ឃសឹក ហើយដើម្បីចូលធ្វើកងទ័ពនោះ គឺបានពីកម្លាំងហ្នឹង។ ដល់កម្លាំងហ្នឹងមក គេបញ្ជូនមកកន្លែងហ្នឹងមក គឺមកលត់ដំរៀនសូត្រការងារ ហើយគ្មានការគំរាមកំហែងទេ កម្លាំងទាំងអស់ហ្នឹង គឺពន្យល់អប់រំហើយ ដល់ថ្ងៃណាមួយដែលបានច្រើន មានច្រើនអីចឹង គេត្រូវបញ្ជូនទៅសមរភូមិមួយសា។ ដូច្នេះ កម្លាំងកន្លែងខ្ញុំហ្នឹង គឺមិនទៀង ជួនពេលខ្លះមកនៅ១០នាក់វិញក៏មាន ពីរដណ្តប់នាក់វិញក៏មាន។

**ស៖** លោកសាក្សីសូមភ័យទោស។ ខ្ញុំសូមអភ័យទោសដែលកាត់ផ្តាច់លោក។ សូមអរគុណចំពោះចម្លើយដ៏លម្អិតរបស់លោក។ ខ្ញុំព្យាយាមសួរឲ្យបានខ្លីៗ ហើយសូមលោកឲ្យឆ្លើយឲ្យបានខ្លីៗដែរ ពីព្រោះថាយើងមានពេលវេលាកំណត់។ ដូច្នេះសូមឲ្យលោកឆ្លើយខ្លីៗ ឲ្យបានច្បាស់ ហើយប្រសិនបើខ្ញុំត្រូវការព័ត៌មានលម្អិតបន្ថែមនោះ ខ្ញុំនឹងសួរលោកបន្ថែម។ ហើយសូមអរគុណដែលលោកឆ្លើយយ៉ាងលម្អិតអម្បាញ់មិញនេះ។ សំណួររបស់ខ្ញុំគឺថាចាប់ពីខែមេសា ឆ្នាំ១៩៧៥ ក្រោយពេលខ្មែរក្រហមទទួលបានជ័យជម្នះរួចហើយនោះ តើគេបញ្ជូនលោកទៅណាដែរ? ហើយលោកកាន់តំណែងអ្វីដែរនៅពេលនោះ? សូមអភ័យទោស! ខ្ញុំសូមការបញ្ជាក់អំពីលោក។ អម្បាញ់មិញនេះ គឺលោកនិយាយអំពីផ្នែកសេដ្ឋកិច្ចនៅក្នុងជួរកងទ័ពខ្មែរក្រហម។ ដូច្នេះ ខ្ញុំចង់ដឹងថាផ្នែកសេដ្ឋកិច្ចនេះមានន័យយ៉ាងម៉េច? បានន័យថាលោកធ្វើអ្វីដែរនៅក្នុងផ្នែកនុ៎ង?

[០៩:៤៥:៤៦]

**ឆ៖** សូមជម្រាបលោកមេធាវីថា លោកចង់សួរខ្ញុំកាលពីមិនទាន់ចូលភ្នំពេញ ឬក៏នៅចូលភ្នំពេញហើយបាទ?**ស៖** គឺពេលមុនចូលភ្នំពេញ។ អម្បាញ់មិញនេះលោកបានឆ្លើយខ្លួនឯងថា លោកធ្វើការនៅក្នុងផ្នែកសេដ្ឋកិច្ច។ ចំពោះយើងៗអត់យល់ទេ មិនដឹងថាតើផ្នែកហ្នឹងមានន័យថាម៉េច? ដូច្នេះ ខ្ញុំចង់ដឹងថាលោកធ្វើអ្វីនៅក្នុងផ្នែកសេដ្ឋកិច្ចនោះ?

**ឆ៖** សូមជម្រាបជូនថា ក្រោយពីពេលគេបានចាត់ខ្ញុំឲ្យទៅទទួលខាងសេដ្ឋកិច្ចហ្នឹង មិនមែនខ្ញុំជាប្រធានធំទេ គ្រាន់តែជាផ្នែកតូចមួយ ហើយទទួលខាងផ្គត់ផ្គង់កងទ័ពហ្នឹង គឺមិនមានផ្គត់ផ្គង់ដាច់តែនៅតែលើខ្ញុំអ្នកគ្រប់គ្រងទេ គឺនៅមានមេបន្តៗទៅទៀត ក៏ប៉ុន្តែក្នុងឋានៈ ហើយតួនាទីខ្ញុំ គឺជាអ្នកប្រមូលស្បៀងៗដើម្បីបញ្ជូនទៅសមរភូមិ។ នេះសូមជម្រាបជូនប៉ុណ្ណឹង។

**ស៖** បាទ សូមអរគុណចំពោះការឆ្លើយបញ្ជាក់នេះ។ ឥឡូវនេះ ខ្ញុំចូលទៅនិយាយអំពីរយៈពេលចាប់ពីខែមេសា ឆ្នាំ១៩៧៥ គឺមានន័យថាក្រោយពីខ្មែរក្រហមទទួលបានជ័យជម្នះហើយនោះ លោកកាន់

មុខងារអ្វី? ហើយលោកធ្វើការនៅឯណា?

**ឆ៖** បាទ សូមអរគុណ។ បញ្ហានេះខ្ញុំសូមបំភ្លឺជូនថា ក្រោយពីបែកភ្នំពេញហើយ នៅថ្ងៃ១៧ មេសា ហ្នឹងគឺអង្គភាពសេដ្ឋកិច្ចខ្ញុំបាទនេះ គឺត្រូវបានគេឲ្យចូលទៅក្នុងក្រុងភ្នំពេញដោយរៀបជាអង្គភាព គឺក្នុងឋានៈខ្ញុំជាប្រធានកងហា។ ក្រោយពីចូលទៅដល់ភ្នំពេញហើយ គឺអង្គភាពខ្ញុំនេះគឺពីដើមឡើយមាន មន្ទីរ៣១១។ ដល់អ៊ីចឹង៣១១នេះ ត្រូវបានចូលទៅនៅក្នុងភ្នំពេញ មិនមានតែនៅផ្តុំគ្នាទេ។ គឺតែដោយ ឡែកតែចំណែកខាងពួកខាងខ្ញុំគឺត្រូវបានគេឲ្យទៅនៅមុខឃ្លាំងកំពង់ទឹកកក គឺខាងកើតផ្សារថ្មី។ នេះសូម ជម្រាបជូនប៉ុណ្ណឹង។

[០៩:៤៨:៣៦]

**ស៖** តើនៅក្នុងឃ្លាំងនុ៎ង លោកធ្វើការអ្វីដែរ?

**ឆ៖** ខ្ញុំសូមជម្រាបជូនថា កាលពីខ្ញុំទៅនៅដល់ខាងកើតផ្សារថ្មីហ្នឹង គឺអត់ដឹងថាអង្គភាពខ្ញុំហ្នឹង គេឲ្យធ្វើអីទេ។

**ស៖** តើលោកធ្វើការនៅឃ្លាំងកំពង់ទឹកកកហ្នឹងអស់រយៈពេលប៉ុន្មានដែរ?

**ឆ៖** ខ្ញុំសូមរៀបរាប់ទៅតាមលំដាប់លំដោយបាទ។ ក្រោយពីខ្ញុំទៅនៅខាងកើតផ្សារថ្មីហ្នឹង គឺ កាលដើមឡើយអត់ដឹងថា អង្គភាពខ្ញុំ គេឲ្យទទួលការងារអីទេ។ ដល់បន្ទាប់មកបានគេដឹងថា គេឲ្យ ទទួលខាងឃ្លាំងៗ។ ដូច្នេះក្នុងអង្គភាពដែលកាលពីទៅជុំគ្នាហ្នឹង គឺមានពីរអនុសេនាធំ។ ដល់ពេលទៅ នៅហ្នឹងទៅ ត្រូវបានខាងលើៗរៀបចំឲ្យទទួលឃ្លាំង ហើយពេលនោះ ខ្ញុំនៅជាប្រធានកងហានៅឡើយ តែក្រោយមកទៀត ត្រូវបានគេជ្រើសរើសក្នុងអង្គភាពទាំងមូលហ្នឹង គឺរៀបចំមួយកងហាទៀត ដើម្បី ទៅគ្រប់គ្រងអង្គភាពបញ្ជីឃ្លាំងមូលហ្នឹង ទាំងអ្នកយាមឃ្លាំង ទាំងអ្នកធ្វើបញ្ជីគឺចំនួនមួយកងហាទៀត។ នៅពេលនោះឋានៈខ្ញុំមកនៅជាបញ្ជាការសម្រាប់រៀបចំកម្លាំងគ្រប់គ្រងសម្ភារៈក្នុងឃ្លាំងវិញ។ បាទនេះ ខ្ញុំសូមជម្រាបជូនប៉ុណ្ណឹង។

[០៩:៥០:៣៣]

**ស៖** សូមអរគុណ ដូច្នេះខ្ញុំយល់ច្បាស់ហើយថាអង្គភាពរបស់លោកហ្នឹង គឺទទួលបន្ទុកចាត់ចែង ឃ្លាំង។ ខ្ញុំ សំណួរខ្ញុំ ខ្ញុំចង់ថាលោកធ្វើការនៅក្នុងឃ្លាំងហ្នឹងអស់រយៈពេលប៉ុន្មានដែរ នៅខាងកើតផ្សារថ្មី ហ្នឹង?

[០៩:៥០:៥៣]

**ឆ៖** សូមជម្រាប ខ្ញុំធ្វើការនៅឃ្លាំងកំពង់ទឹកកកនេះ គឺតាំងពីឆ្នាំ៧៥មកទាល់គ្នានឹងឆ្នាំ៧៦ ទើបបានគេផ្លាស់ខ្ញុំទៅនៅគីឡូលេខ៦វិញ នៅក្នុងចុងឆ្នាំ៧៦។

**សៈ** ហើយនៅគីឡូម៉ែត្រលេខ៦ ហ្នឹងក៏ជាឃ្លាំងដែរមែនទេ?

**ឆ៖** បាទ ជាឃ្លាំងដែរ ជាសាខារបស់ឃ្លាំងទាំងមូល មានឃ្លាំងគីឡូលេខ៦ ឃ្លាំងជ្រោយចង្វា និងឃ្លាំងកំពង់ទឹកកក។

**សៈ** នៅពេលដែលលោកនិយាយថា សាខាឃ្លាំងអ៊ីចឹងមានន័យថា ឃ្លាំងទាំងអស់ហ្នឹងគឺមាន បួន តាមអ្វីដែលលោករៀបរាប់អម្បាញ់មិញនេះ?

**ឆ៖** សូមជម្រាបដែរថា ឃ្លាំងមាត់ទន្លេហ្នឹងមានឃ្លាំងកំពង់ទឹកកករហូតទៅដល់វត្តភ្នំ។ ហើយមួយកន្លែងទៀតឃ្លាំងនៅជ្រោយចង្វា ហើយមួយកន្លែងទៀតឃ្លាំងនៅគីឡូលេខ៦ មានតែប៉ុណ្ណឹងទេបាទ។

[០៩:៥២:៤២]

**សៈ** លោកបានថា នៅឆ្នាំ៧៦ លោកបានទៅគីឡូម៉ែត្រលេខ៦។ តើលោករស់នៅនៅឃ្លាំងនុ៎ង រហូតទៅដល់ខែមករា ឆ្នាំ១៩៧៩ មែនទេ?

**ឆ៖** បាទ ខ្ញុំក្រោយពីបែកភ្នំពេញទៅ បានខ្ញុំចេញឃ្លាំងហ្នឹងបាទ។

**សៈ** ចុះនៅគីឡូម៉ែត្រលេខ៩ តើមានឃ្លាំងទេ?

**ឆ៖** គីឡូម៉ែត្រលេខ៩នេះ ខ្ញុំសូមជម្រាបថា ខ្ញុំអត់បានដឹងទេ ពីព្រោះក្រៅពីអង្គភាពឃ្លាំង គ្រប់គ្រង គឺខ្ញុំដឹងតែត្រឹមអង្គភាពឃ្លាំងគ្រប់គ្រងទេបាទ។

**សៈ** ដូច្នេះមានន័យថានៅចន្លោះឆ្នាំ៧៥ ទៅដល់ឆ្នាំ៧៩ គឺលោកធ្វើការនៅឃ្លាំងតែពីរទេ។ មែនទេ?

**ឆ៖** បាទ។

[០៩:៥៤:១២]

**សៈ** ខ្ញុំនឹងត្រឡប់មកនិយាយអំពីការងាររបស់លោកនៅក្នុងឃ្លាំងទាំងពីរនេះ ក៏ប៉ុន្តែជាបឋមខ្ញុំ សូមពិនិត្យមើលជាមួយលោកសិនថា នៅខែមេសា ៧៥ ហើយនិងមករា ៧៩ ថាតើលោកដឹងអ្វីខ្លះអំពី អង្គភាពបក្សកុម្មុយនីស្តកម្ពុជា ហើយនិងមេដឹកនាំកម្ពុជាប្រជាធិបតេយ្យ? ដូច្នេះសំណួរទី១ របស់ខ្ញុំនោះ ខ្ញុំចង់ដឹងថា លោកដឹងថាគណៈអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជាហ្នឹងជាអ្វីដែរ?

**ឆ៖** សូមជម្រាបលោកមេធាវី សំណួររបស់លោកខ្ញុំសូមជម្រាបជូនថា គណៈអចិន្ត្រៃយ៍ដែលលោកចង់សួរខ្ញុំនេះ គឺខ្ញុំមិនអាចដឹងជ្រៅទៅបានទេ ពីព្រោះជាការងាររបស់ខាងលើៗ ខ្ញុំមិនអាចដឹងរឿងច្រើនទេបាទ។

**ស៖** ដូចគ្នាដែរ ចុះគណៈមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា លោកដឹងទេ?

**ឆ៖** សូមជម្រាបថាកាលពេលនោះ គណៈមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជាហ្នឹង គឺខ្ញុំអត់បានដឹងទេ គ្រាន់តែបានដឹងត្រឹមមកភ្ញាក់ផ្អើលថ្ងៃប្រកាស ប៉ុល ពត ជានាយករដ្ឋមន្ត្រីទី១ហ្នឹងមក ត្រឹមដឹងត្រឹមប៉ុណ្ណឹងបាទ។

**ស៖** សូមអរគុណលោកសាក្សី។ ចុះលោកស្គាល់មន្ទីរក-១, ក-៣ ដែរឬទេ?

**ឆ៖** អត់ ខ្ញុំអត់ដែលស្គាល់ទេមន្ទីរហ្នឹង ហើយក៏មិនធ្លាប់ឮសួរដែរបាទ។

**ស៖** តើលោកស្គាល់មន្ទីរ៨៧០ ដែរទេ?

**ឆ៖** ខ្ញុំមិនដែលស្គាល់ទេ គ្រាន់តែបានឮសួរថាឈ្មោះ៨៧០ គ្រាន់តែបានឮសួរតែប៉ុណ្ណឹង មិនដែលស្គាល់។

[០៩:៥៧:០៥]

**ស៖** តើលោកដឹងទេថា អ្នកណាជាប្រធានមន្ទីរ៨៧០?

**ឆ៖** ពេលនុ៎ង ខ្ញុំមិនបានដឹងទេបាទ។

**ស៖** ចុះលោកដឹងទេថា មន្ទីរ៨៧០ហ្នឹងមានមុខងារអ្វីដែរ?

**ឆ៖** អត់ ខ្ញុំអត់បានដឹងទេបាទ។

**ស៖** នៅចន្លោះឆ្នាំ៧៥ និងឆ្នាំ៧៩ តើលោកធ្លាប់ធ្វើការជាមួយមន្ទីរសន្តិសុខស-២១ ដែរឬទេ?

**ឆ៖** ខ្ញុំមិនដែលធ្វើការជាមួយមន្ទីរសន្តិសុខស-២១ទេ ហើយមិនត្រឹមតែមិនធ្លាប់ហើយ ក៏មិនដែលស្គាល់មន្ទីរស-២១ ហ្នឹងទៀត។

**ស៖** តើនៅចន្លោះឆ្នាំ៧៥ ដល់៧៩ហ្នឹង លោកធ្លាប់ធ្វើការនៅគណៈពាណិជ្ជកម្មទេ?

**ឆ៖** មិនដែលទេ ខ្ញុំមិនដែលធ្លាប់នៅជាមួយខាងក្រសួងពាណិជ្ជកម្មហ្នឹង។

**ស៖** ចុះលោកធ្លាប់ធ្វើការជាមួយគណៈឧស្សាហកម្មទេ?

**ឆ៖** ចំពោះបញ្ហាខាងឧស្សាហកម្មនេះ ខ្ញុំបានតែត្រឹមធ្លាប់ទៅដឹកសម្ភារៈចេញពីរោងចក្រ នេះបានត្រឹមទទួលបានការងារដែលខ្ញុំបានការងារដែលខ្ញុំធ្វើ មិនមែនត្រឹមទៅដឹកអីវ៉ាន់ចេញពីរោងចក្រយក

មកដាក់ឃ្លាំងប៉ុណ្ណឹងបាទ។

**ស៖** សូមអរគុណ។ ខ្ញុំនឹងត្រឡប់មកនិយាយអំពីការងារប្រចាំថ្ងៃរបស់លោកនៅក្នុងឃ្លាំង ប៉ុន្តែជាបឋមនោះ ខ្ញុំចង់សួរសំណួរលោកមួយចំនួនពាក់ព័ន្ធទៅនឹងឥស្សរជនរបស់កម្ពុជាប្រជាធិបតេយ្យ គឺអ្នកដែលធ្វើការងារនៅក្នុងរបបហ្នឹង ចង់ដឹងថាតើលោកស្គាល់អ្នកណាខ្លះ? ចុះលោកស្គាល់ឈ្មោះ សរ គឹមល្មុត ដែរឬទេ?

**ឆ៖** ខ្ញុំអត់ដែលស្គាល់គាត់ទេបាទ។

[១០:០០:០៨]

**ស៖** លោកបានឆ្លើយថា លោកដឹងថា ប៉ុល ពត ជាលេខាបក្សកុម្មុយនីស្តកម្ពុជា។ តើលោកធ្លាប់ធ្វើការដោយផ្ទាល់ជាមួយ ប៉ុល ពត ដែរឬទេ?

**ឆ៖** ខ្ញុំអត់ដែលបានធ្វើការជាមួយគាត់ ឬក៏និយាយ ឬក៏ជួបជាមួយគាត់ អត់ទេ បាទ។

**ស៖** តើលោកស្គាល់ឈ្មោះ ប៉ង់ ដែរឬទេ?

**ឆ៖** គ្រាន់តែសួរថាឈ្មោះ តែមិនដែលស្គាល់មុខទេ បាទ។

**ស៖** នៅពេលដែលលោកឆ្លើយអម្បាញ់មិញនេះ គឺលោកឆ្លើយថាស្គាល់តែឈ្មោះទេ។ មែនទេ?

**ឆ៖** ខ្ញុំស្គាល់តែឈ្មោះទេបាទ ឮតែឈ្មោះទេ អត់ដែលស្គាល់។

**ស៖** អ៊ីចឹងតើលោកដឹងទេ ថាគាត់មានមុខងារអ្វីដែរ?

**ឆ៖** ខ្ញុំអត់ដឹងថា គាត់ធ្វើអីទេ ឮតែឈ្មោះ បាទ។

**ស៖** ចុះលោកស្គាល់ឈ្មោះ ខឿន ដែរឬទេ?

**ឆ៖** អត់ស្គាល់ដែរ ឈ្មោះ ខឿន ក៏អត់ស្គាល់។

[១០:០១:០៦]

**ស៖** គេប្រាប់ខ្ញុំថា ប្រហែលជាខ្ញុំអានឈ្មោះ មិនត្រឹមត្រូវ ប៉ុន្តែចំពោះអ្នកបកប្រែ គឺថាសរសេរ ដេ-អូ-អ៊ី-អ៊ុយ-អិន។ គឺត្រូវហើយ ខឿន។ (អ្នកបកប្រែអម្បាញ់មិញអានថា ខឿន) ប្រហែលជាអាចមានអ្នកណាជួយបានសម្រាប់ឈ្មោះនេះ គឺឈ្មោះ ខឿន។ លោកសាក្សី លោកស្គាល់ទេ?

**ឆ៖** ខ្ញុំអត់ស្គាល់ទេ ឈ្មោះ ខឿន បាទ។

**ស៖** តើលោកធ្លាប់ជួបគាត់ទេ? សូម្បីថាពីចម្ងាយក៏ដោយ ដោយថាលោកមិនធ្លាប់បាននិយាយទេ តែធ្លាប់ឃើញគាត់ពីចម្ងាយទេ?

**ឆ៖** សូមជម្រាបថា ដូចខ្ញុំបានផ្តល់សក្ខីកម្មហូរហែតាមរយៈសម្អាសហូរហែមកហើយ ខ្ញុំថា ពេលខ្លះឃើញអ្នកដែលចេញចូលទៅមើលឃ្លាំង តែខ្ញុំមិនបានស្គាល់ទេ ហើយក៏មិនបានចាប់អារម្មណ៍ ព្រោះដោយសារអី? ដោយសារតែការងារនៅធ្វើកន្លែងណា គឺដឹងតែធ្វើកន្លែងហ្នឹង។ អត់មានទៅឃើញ អ្នកភូមិមកហើយ រត់ទៅមើល ឬរត់ទៅទទួលនោះទេ បាទ។

[១០:០៣:៤៧]

**ស៖** ខ្ញុំនឹងត្រឡប់មកនិយាយអំពីចំណុចនេះនៅពេលក្រោយ។ ឥឡូវនេះខ្ញុំចង់ដឹងថា នៅឃ្លាំងនុ៎ង អ្នកណាជាមេផ្ទាល់របស់លោក?

**ឆ៖** សូមជម្រាបថា នៅឃ្លាំងកំពង់ទឹកកក ឃ្លាំងជ្រោយចង្វា និងឃ្លាំងគីឡូលេខ៦ហ្នឹង គឺមានឈ្មោះលោក រឿង ជាមេផ្ទាល់។ តែបន្ទាប់គាត់ហ្នឹង មានមេពីរបីនាក់តទៅទៀត។

**ស៖** តើលោកស្គាល់ឈ្មោះ តេង ទេ?

**ឆ៖** សូមជម្រាបឈ្មោះ តេង ខ្ញុំស្គាល់ បាទ។

**ស៖** ចុះ តេង ហ្នឹង គាត់ជាអ្នកណាដែរ?

**ឆ៖** តេង ហ្នឹង គាត់បន្ទាប់ពីលោក រឿង មក ឈ្មោះ តេង ហ្នឹង បាទ។

**ស៖** តើលោកស្គាល់ឈ្មោះ វន វ៉េត ដែរឬទេ?

**ឆ៖** សូមជម្រាបថា ខ្ញុំបានតែត្រឹមឮឈ្មោះទេ ឲ្យស្គាល់មុខ ខ្ញុំអត់ដែលស្គាល់ទេបាទ។

**ស៖** តើលោកធ្លាប់ធ្វើការជាមួយ វន វ៉េត ឬគឺមួយមន្ទីររបស់ វន វ៉េន ដែរទេ ក្នុងក្របខ័ណ្ឌការងាររបស់លោកនៅឃ្លាំងនុ៎ង?

**ឆ៖** សូមជម្រាបថា ខ្ញុំអត់ដែលមានទំនាក់ទំនង ឬក៏ធ្វើការអីជាមួយទេ។ ខ្ញុំអត់ដែលបានជួប ហើយមិនដែលធ្វើការជាមួយទេ។

[១០:០៦:២០]

**ស៖** ចុះ វ៉ាន់ រិទ្ធ លោកធ្លាប់ស្គាល់ឈ្មោះនេះទេ?

**ឆ៖** លោក វ៉ាន់ រិទ្ធ ខ្ញុំស្គាល់គាត់ច្បាស់។

**ស៖** តើនៅចន្លោះឆ្នាំ៧៥ ដល់ឆ្នាំ៧៩ វ៉ាន់ រិទ្ធ មានតួនាទីអ្វីដែរ?

**ឆ៖** នៅក្នុងចន្លោះឆ្នាំ៧៥ ដល់ឆ្នាំ៧៩ នេះមិនបានចូលរួមការរៀបចំ ឬក៏ការតែងតាំងអ្វីទេ ក៏ប៉ុន្តែគ្រាន់តែឮតាមរយៈក្រុមការងារដែលនៅជាមួយគ្នាហ្នឹងថា គាត់ទទួលខាងពាណិជ្ជកម្ម។ ខ្ញុំបានត្រឹម

តែដឹងត្រឹមប៉ុណ្ណឹងបាទ។

**ស៖** ចុះលោកធ្លាប់ការដោយផ្ទាល់ជាមួយនឹង វ៉ាន់ រិទ្ធ ហ្នឹងទេ?

**ឆ៖** ខ្ញុំអត់ដែលធ្លាប់ធ្វើការហ្នឹងជាមួយគាត់ទេបាទ។

**ស៖** ចុះឈ្មោះ កុយ ធួន លោកធ្លាប់ស្គាល់ឈ្មោះនេះទេ?

**ឆ៖** សូមជម្រាបលោកមេធាវីថា ខ្ញុំស្គាល់តែឈ្មោះទេ តែមុខក៏អត់ដែលឃើញ។

**ស៖** សូមអរគុណចំពោះការឆ្លើយបញ្ជាក់នេះ។ លោកបាននិយាយអំពីឈ្មោះ រឿង ដែលជាប្រធានឃ្លាំងរដ្ឋ។ ចុះលោកដឹងថាអ្នកណាដែលនៅពីលើ រឿង ហ្នឹងទេ គឺមានន័យថារចនាសម្ព័ន្ធថ្នាក់លើនៃឃ្លាំងរដ្ឋនេះ?

[១០:០៨:២៩]

**ឆ៖** សូមជម្រាបលោកមេធាវី គឺខ្ញុំអត់ដឹង ហើយអត់ស្គាល់ថាអ្នកដែលនៅពីលើគាត់ហ្នឹងគឺជាអ្នកណាដែរ ខ្ញុំអត់បានដឹងទេបាទ។

**ស៖** តើលោកដឹងថារចនាសម្ព័ន្ធដែលនៅពីលើឃ្លាំងដែរឬទេ?

**ឆ៖** សូមជម្រាប គ្រាន់តែបានដឹងថា នៅពេលដែលចែកចាយសម្ភារៈទៅតាមភូមិភាគ ទៅតាមតំបន់ហ្នឹង គឺគ្រាន់តែដឹងឃើញឯកសារហ្នឹង គឺ១ ចេញពីក-២៥ ដែលកំណត់ថាត្រូវឲ្យអីវ៉ាន់ទៅភូមិភាគណាប៉ុនណាៗ គឺខ្ញុំគ្រាន់តែឃើញជាក្រដាស ឃើញនៅឯកសារហ្នឹងគឺលិខិតអនុញ្ញាតឲ្យចែកចាយទៅខាងណាប៉ុន្មានៗ ខ្ញុំគ្រាន់តែដឹងប៉ុណ្ណឹង។ ឃើញលិខិតចេញតែប៉ុណ្ណឹងទេ អត់ដឹងថាអ្នកដែលនៅពីលើឃ្លាំងផ្ទាល់ អង្គភាពក្រសួងឃ្លាំងគឺអ្នកណាអ្នកចាត់ចែងផ្ទាល់ដៃហ្នឹង គឺខ្ញុំអត់ស្គាល់ទេបាទ។

**ស៖** ចុះលោកទទួលបញ្ជាពីណានៅក្នុងក្របខ័ណ្ឌនៃការងាររបស់លោកនោះ?

**ឆ៖** ខ្ញុំសូមជម្រាបលោកមេធាវីដែរថា ក្រោយពីទទួលបញ្ជានេះ គឺទទួលបញ្ជាពីលោក រឿង ដោយលោក រឿង នាំយកឯកសារដូចជាកំណត់សម្ភារៈប្រគល់ទៅភូមិភាគណាប៉ុនណាៗ ចេញពីកង២៥មក ដល់ពេលលោក រឿង យកមកប្រគល់ឯកសារហ្នឹងយកមកខាងខ្ញុំក្រុមការងារពិនិត្យបញ្ជីឃ្លាំងហ្នឹង កំណត់ថាត្រូវដាក់អីវ៉ាន់ទៅឲ្យភូមិភាគប៉ុនណាៗ គឺខ្ញុំទទួលតាមបញ្ជាធ្វើ តាមឯកសារដែលគាត់មានកំណត់មកហ្នឹងបាទ។

[១០:១០:៥៣]

**ស៖** តើលោកស្គាល់ឈ្មោះ ឈុន ដែរឬទេ?

**ឆ៖** សូមបញ្ជាក់សំណួរម្តងទៀតបាទ។

**ស៖** តើលោកស្គាល់ឈ្មោះ ជួន, ឈ្មោះ ជួន លោកស្គាល់ទេ?

**ឆ៖** សូមជម្រាបឈ្មោះ ជួន ខ្ញុំស្គាល់។

**ស៖** តើ ជួន នេះជាអ្នកណា? ហើយគាត់មានមុខងារអ្វីដែរ?

**ឆ៖** លោក ជួន គាត់មានឋានៈក្នុងអង្គភាពឃ្លាំងហ្នឹង គឺគាត់មានទី១ គឺមានលោក រឿង ជាប្រធាន, លោក តេង ជាអនុ, លោក ជួន ជាសមាជិក។ នេះមានបីនាក់ហ្នឹងឃ្លាំង។

[១០:១២:២១]

**ស៖** ម្នាក់អម្បាញ់មិញលោកនិយាយហ្នឹង តេង អម្បាញ់មិញ? ខ្ញុំស្តាប់ដូចជាមិនសូវច្បាស់។

**ឆ៖** លោក តេង ដែលលោកសួរខ្ញុំថាជាអ្នកណាហ្នឹង ខ្ញុំបានជម្រាបហើយថាខ្ញុំស្គាល់គាត់ហ្នឹងជាអនុរបស់លោក រឿង ហើយលោក ជួន ហ្នឹងគាត់ជាសមាជិកបន្ទាប់ពីលោក តេង។ ក្នុងថ្នាក់ដឹកនាំមានបីនាក់ហ្នឹង។

**ស៖** សូមអរគុណចំពោះការឆ្លើយបញ្ជាក់នេះ។ ចុះលោកស្គាល់មន្ទីរក-៧ ទេ? អម្បាញ់មិញលោកនិយាយអំពី ក-២៥ ឥឡូវខ្ញុំសួរវិញ ថាតើលោកស្គាល់ ក-៧ទេ?

**ឆ៖** ខ្ញុំអត់ដែលស្គាល់ទេបាទ។

**ស៖** សំណួរបន្ថែម ក្រៅពីការងាររបស់លោកនៅឃ្លាំង តើលោកមានការទទួលខុសត្រូវផ្សេងក្រៅពីការនៅឃ្លាំងទេ?

**ឆ៖** សូមជម្រាបលោកប្រធាន ខ្ញុំអត់មានតួនាទីអីក្រៅពីការងារនៅក្នុងអង្គភាពឃ្លាំងទេបាទ?

**ស៖** នៅឃ្លាំង តើមុខងាររបស់លោកបានតែត្រឹមដាក់ -- បានតែត្រឹមលើកដាក់ដឹកទំនិញសម្រាប់ដឹកទៅតាមភូមិភាគ ឬក៏មានសម្មភាពអ្វីផ្សេង?

[១០:១៤:២៦]

**ឆ៖** សូមជម្រាបលោកមេធាវី គឺចំពោះការងារសម្រាប់ផ្ទាល់ខ្លួនខ្ញុំ គឺតាំងពីខ្ញុំទៅនៅក្នុងអង្គភាពឃ្លាំងមក គឺកាលពីនៅឃ្លាំងកំពង់ទឹកកក គឺទៅដឹកសម្ភារៈចេញពីរោងចក្រ យកមកទុកក្នុងឃ្លាំង។ ហើយទៅនៅគីឡូលេខ៦ គឺមានតួនាទីមួយ គឺគ្រាន់តែត្រឹមទទួលបញ្ជាពីថ្នាក់លើៗហ្នឹងថាត្រូវរៀប ផ្តល់សម្ភារៈ ឬក៏បើកអង្ករទៅក្រសួងនេះ ក្រសួងនោះ ឬក៏អង្គភាពនេះ អង្គភាពនោះ ឬក៏ទទួលសម្ភារៈពីភូមិភាគយកមកទុកក្នុងឃ្លាំង ហើយត្រូវបញ្ចេញសម្ភារៈពីឃ្លាំងទៅកំពង់សោម ឬក៏ទៅចែកចាយតាម

អង្គភាពអី គឺខ្ញុំមានតួនាទីតែប៉ុណ្ណឹង ហើយចប់តួនាទីហ្នឹង។ រាល់ថ្ងៃសរុបរបាយការណ៍ប្រចាំខែ គឺក្នុងសម្ភារៈចេញទៅខាងណាប៉ុន្មានៗ ជូនទៅមន្ទីរលោក វឿង គ្រប់គ្រងហ្នឹងបាទ។ មានតែប៉ុណ្ណឹងទេ។

**ស៖** សូមអរគុណ។ ខ្ញុំចង់បានការឆ្លើយបញ្ជាក់មួយអំពីលោកពាក់ព័ន្ធទៅនឹងសម្ភារៈ ឬក៏ផលិតផលដែលស្តុកនៅក្នុងឃ្លាំងរបស់លោក។ លោកនិយាយអំពីអង្ករ តើមានផលិតផលផ្សេងទៀតទេ?

**ឆ៖** ក្នុងឃ្លាំង ខ្ញុំសូមជម្រាបដែលថា បើនៅឃ្លាំងកំពង់ទឹកកក មានសម្ភារៈ ដែលត្រូវដឹកមកពីក្រៅប្រទេស មានតាំងពីចបកាប់ មានតាំងពីញញួរ មានតាំងពីក្រណាត់ ដែកថែប ខ្មៅខ្សែង...។ល។ នេះសម្រាប់នៅក្នុងឃ្លាំងកំពង់ទឹកកក។ បើនៅក្នុងឃ្លាំងគីឡូលេខ៦ មានសម្ភារៈមកពីភូមិភាគ ពីតំបន់ គឺមានស្រូវ មានអង្ករ មានកៅស៊ូ មានអំបិល មានស៊ីម៉ង់ត៍។ នេះគឺមានប៉ុណ្ណឹងដែលនៅសម្រាប់ផ្ទុកនៅក្នុងឃ្លាំង។

[១០:១៧:០៩]

**ស៖** តើសម្ភារៈ ឬក៏ផលិតផលទាំងអស់ហ្នឹង ទុកសម្រាប់ឲ្យអ្នកណាគេដែរ?

**ឆ៖** នេះដូចខ្ញុំបានជម្រាបជូនលោកមេធាវីហើយថា ក្រោយពីមានការដឹកចូល គឺក៏មានការចែកចាយទៅវិញដែរ។ ហើយចែកចាយហ្នឹងចេញពីណា? ចេញពីកង២៥មក តែមានឯកសារមកថា ត្រូវផ្តល់ទៅឲ្យស៊ីម៉ង់ត៍ ឬក៏សម្ភារៈអ្វីមួយឲ្យទៅតំបន់ណាប៉ុនណា ឲ្យទៅភូមិភាគណាប៉ុនណា ឬក៏ផលិតផលចេញពីរោងចក្រឲ្យទៅភូមិភាគណាចំនួនប៉ុន្មាន ស្បែកជើងប៉ុន្មាន ក្រណាត់ប៉ុន្មាន អីប៉ុន្មានហ្នឹង គឺទៅតាមការកំណត់ចេញពីក-២៥បាទ។ តាមរយៈមកលោក វឿង មកបានគាត់បន្តមកក្រុមការងារខ្ញុំដែលអ្នកនៅសម្រាប់លើកដាក់ផ្តល់ឲ្យខាងគ្រប់ផ្នែក។ ប៉ុណ្ណឹងបាទ។

**ស៖** ចុះការស្នើសុំពីភូមិភាគហ្នឹងធ្វើមកយ៉ាងម៉េចដែរ? ជាទម្រង់យ៉ាងម៉េចពីការស្នើសុំពីភូមិភាគមក?

**ឆ៖** សូមជម្រាបជូនដែលថា ការងារទាំងអស់នេះខ្ញុំអត់ដឹងទេ គ្រាន់តែឃើញឯកសារចេញពីក-២៥ តាមរយៈលោក វឿង បញ្ជាមកថា "នែ៎ យកឯកសារហ្នឹង យកស្ថិតិ ប៊ុងដែលចេញមកហ្នឹង គឺត្រូវផ្តល់ជូនទៅតំបន់នេះប៉ុណ្ណេះ។ សម្ភារៈមានមុខនេះប៉ុណ្ណេះ មុខនេះប៉ុណ្ណេះ គឺខ្ញុំត្រឹមបានដឹងតែត្រឹមលើកហើយនិងដាក់ប្រគល់ជូនទៅគ្រប់ក្រសួងមន្ទីរ ឬក៏អង្គភាពប៉ុណ្ណឹងទេ ហើយនិងធ្វើរបាយការណ៍តែប៉ុណ្ណឹងទេ។ ខ្ញុំដឹងត្រឹមរឿងប៉ុណ្ណឹង"។

[១០:១៩:៣៧]

**ស៖** ខ្ញុំគិតថាប្រហែលជាមានបញ្ហាបកប្រែបន្តិច។ ខ្ញុំយល់អំពីរបៀបលោកធ្វើការ ហើយនិងរបៀបដែលលោកទទួលបញ្ជាពី រឿង ដែលរឿងទទួលឯកសារពីក-២៥មក អ៊ីចឹងមែនទេអ្វីដែលលោកឆ្លើយអម្បាញ់មិញនេះ?

**ឆ៖** បាទៗ ពិតប្រាកដមែនហើយ។

**ស៖** តើលោកដឹងទេថា សម្ភារៈដែលទទួលបានហើយ យកទៅដល់មូលដ្ឋាននោះ យ៉ាងម៉េច? លោកបាននិយាយអម្បាញ់មិញ មានផលិតផលមកពីបរទេស។ ដូច្នេះលោកដឹងទេថា តើផលិតផលណាមកពីប្រទេសណា?

**ឆ៖** សូមជម្រាបដែលថា ខ្ញុំអត់ក្តាប់បានទេ ថាមកពីប្រទេសណាៗ ទេ គ្រាន់តែដឹងថា បើមកពីក្រៅប្រទេស គឺត្រូវឲ្យកម្លាំងទៅលើកដាក់ពីទូរទេះភ្លើង ពីវ៉ារទេះភ្លើង លើកដាក់ឡានយកមកទុកក្នុងឃ្លាំង។ ហើយពេលមកដល់ឃ្លាំងត្រូវចែកចាយទៅហ្នឹង គឺខ្ញុំគ្រាន់ដឹងប៉ុណ្ណឹងទេ។ តែត្រង់ថា មកពីប្រទេសណាៗ គឺខ្ញុំអត់បានដឹងទេ បាទ។

[១០:២១:០៩]

**ស៖** លោកបាននិយាយអំពីសម្ភារៈមកពីប្រទេស។ ចុះមានសម្ភារៈខ្មែរនៅក្នុងឃ្លាំងលោកហ្នឹងមានសម្ភារៈសម្រាប់ដឹកចេញទៅបរទេសវិញទេ?

**ឆ៖** សម្រាប់នៅក្នុងឃ្លាំងហ្នឹង ដែលត្រូវមានសម្ភារៈចេញហ្នឹង គឺមានតែកៅស៊ូ ហើយនិងអង្ករ។ នេះដឹកតាមរយៈរទេះភ្លើង។ គឺមានតែប៉ុណ្ណឹងទេ ដែលត្រូវចេញទៅក្រៅវិញ មានតែប៉ុណ្ណឹងមុខទេ បាទ ដែលខ្ញុំនៅក្នុងឃ្លាំងដឹង។

**ស៖** នៅក្នុងឃ្លាំងដែលមានអង្ករ។ តើអង្ករទាំងអស់នោះទុកសម្រាប់តែនាំចេញទេ ឬក៏ទុកសម្រាប់ការផ្គត់ផ្គង់នៅក្នុងប្រទេសកម្ពុជាដែរ?

**ឆ៖** សូមជម្រាបលោកមេធាវីដែលថា អង្ករ ហើយនិងស្រូវ ដែលទីមួយ ដឹកចេញមកពីតំបន់ឬក៏តាមភូមិភាគ។ ជំនាន់ហ្នឹងគេថាដឹកស្រូវជូនរដ្ឋ តែខ្ញុំមិនដឹងថាដឹកស្រូវជូនរដ្ឋហ្នឹងយ៉ាងណាទេ។ គ្រាន់តែខ្ញុំអ្នកនៅកាន់បញ្ជីឃ្លាំង គឺខ្ញុំត្រឹមតែដឹងថា ស្រូវដឹកយកមកចូលឃ្លាំង។ ខ្ញុំនឹងស៊ីញ៉េទទួលហើយនិងគេស៊ីញ៉េប្រគល់តែប៉ុណ្ណឹង។ តែដល់ពេលថា អ្ហ៎! ត្រូវនាំចេញទៅក្រៅ ដូចជាអង្ករ ដូចជាកៅស៊ូ ក្រែប មានកៅស៊ូកក កៅស៊ូដុំអីហ្នឹង គឺត្រូវចេញទៅក្រៅហ្នឹង គឺប៉ុន្មានដុំៗ សូម្បីតែចេញទៅខាង

ណា ក៏ខ្ញុំក្តាប់អត់បាន។ ដឹងថាចេញទៅក្រៅ ដឹងថាស៊ីញេប្រគល់តាមរយៈរទេះភ្លើងតែប៉ុណ្ណឹង។ ហើយស្រូវ -- អង្ករ ក៏អ៊ីចឹងដែរ គឺលើកដាក់ទូរទេះភ្លើងហើយ គ្រប់អង្គភាពទាំងអស់ជាកម្មករមកលើកដាក់ហ្នឹង គឺគ្រប់កម្មករទាំងអស់ គឺមានប្រធានមួយ។ អ្ហ៎! ខាងកម្មករហ្នឹងប្រធានមួយមកស៊ីញេទទួលខុសត្រូវ ខាងរទេះភ្លើងមួយ មានប្រធានមកទទួលខុសត្រូវ។ គឺក្នុងទូមួយៗហ្នឹង ហើយមានខាងបញ្ជីឃ្លាំងខាងពួកខ្ញុំហ្នឹងម្នាក់ស៊ីញេទទួលដឹងឮថា មួយទូហ្នឹងដាក់ប៉ុន្មាន ហើយចំនួនប៉ុន្មានប៉ាវ។ គឺខាងខ្ញុំទទួលខុសត្រូវបានតែត្រឹមប៉ុណ្ណឹង តែត្រង់ថាយកទៅប្រទេសណា យកទៅខាងណា គឺខ្ញុំអត់បានដឹងទេសម្រាប់ចេញទៅក្រៅ បាទ។

[១០:២៣:៥៦]

**ស៖** ក្នុងក្របខ័ណ្ឌនៃការងាររបស់លោក។ តើលោកធ្លាប់រៀបចំស្រូវអង្ករសម្រាប់បញ្ជូនទៅភូមិភាគដែរឬទេ?

**ឆ៖** សូមជម្រាបដែរថា សម្រាប់ស្រូវអង្ករនេះ គឺអត់មានបញ្ជូនទៅភូមិភាគវិញទេ មានតែតាមភូមិភាគដឹកបញ្ចូលមកភ្នំពេញ។ ឯស្រូវ ហើយនិង អង្ករ ពេលស្រូវមកដល់ គឺខាងខ្ញុំមានតួនាទីមួយកិន។ តម្រូវចាំមើលថ្ងៃណា ខាងលើថា អ្ហ៎! ត្រូវបញ្ជូនអង្ករទៅខាងណាប៉ុន្មានៗ គឺខ្ញុំត្រឹមដឹងតែប៉ុណ្ណឹង។ តែអង្ករហើយនិងស្រូវ គឺអត់មានបញ្ជូនទៅភូមិភាគវិញទេ។ មានតែចែកចាយទៅតាមក្រសួង មានការងារនៅក្នុងក្រុងភ្នំពេញហ្នឹងប៉ុណ្ណឹងទេ ដែលត្រូវអង្ករនាំចេញទៅ។ ភូមិភាគអត់មានទេ មានតែត្រឹមនៅក្នុងទីក្រុងភ្នំពេញប៉ុណ្ណឹងទេ ក្រសួង មន្ទីរ ខាងកងទ័ព ឬក៏ខាងឧស្សាហ៍កម្ម កសិកម្ម អ៊ីពាណិជ្ជកម្ម ដែលត្រូវមកបើកយកទៅហូប គឺមានតែត្រឹមប៉ុណ្ណឹងទេ។ តែអារឿងចេញទៅក្រៅភូមិភាគវិញ គឺអត់មានទេ។

[១០:២៥:០៥]

**ស៖** ឥឡូវនេះ ខ្ញុំព្យាយាមរំឭកការចងចាំរបស់លោក ពីព្រោះបើ លោកបាននិយាយអំពីបញ្ហាស្រូវអង្ករនេះនៅពេលដែលលោកសម្ភាសជាមួយនឹងមជ្ឈមណ្ឌលឯកសារកម្ពុជា គឺកិច្ចសម្ភាសន៍នៅឆ្នាំ ២០០៣ ដែលយើងបាននិយាយអម្បាញ់មិញនេះ។ ដូច្នេះខ្ញុំចង់ពិនិត្យមើលជាមួយលោកនូវចម្លើយរបស់លោក គឺឯកសារ IS19.158។ ERN ជាភាសាបារាំង 00899462, ERN ជាភាសាខ្មែរ 0000 គឺមានន័យថា 00008293 ហើយបន្តរហូតទៅដល់ 94, អង់គ្លេស 00710451។ អ្នកស្រាវជ្រាវបានសួរសំណួរលោក គឺដំបូងលោកនិយាយអំពីការនាំចេញនាំចូលស្រូវអង្ករ។ ជាភាសាបារាំងនុ៎ងគឺចាប់ផ្តើម

តាំងពីអាទំព័រខាងមុខមួយទៀតនោះ គឺ 00899961។ សំណួរដែលគេសួរលោកនោះគឺថា "ទំនិញស្រូវភាគច្រើននោះ គឺថានាំចេញ ឬក៏ទុកនៅក្នុងប្រទេស?" ហើយលោកបានឆ្លើយថា "គេនាំចេញស្រូវតិចជាងគេចែកចាយទេ"។ ហើយបន្តទៅទំព័រខាងមុខទៀត ដែលខ្ញុំបានផ្តល់លេខ ERN ហើយ គេសួរសំណួរលោកថា "គេនាំចេញតិចទេអីចឹង? ទៅក្រៅតិចជាង?" លោកឆ្លើយថា "ទៅក្រៅនុំងតិចជាងនៅក្នុងស្រុកទេ"។ ដូច្នេះលោកសាក្សី លោកនឹកឃើញអំពីហេតុការណ៍ដែលកើតឡើងពាក់ព័ន្ធទៅនឹងការចែកចាយស្រូវនៅក្នុងឃ្លាំងរបស់លោកដែរឬទេ ពេលនេះ?

[១០:២៧:៤៤]

**ឆ៖** សូមជម្រាបលោកមេធាវីដែរថា ពេលដែលខ្ញុំផ្តល់សក្ខីកម្មជូនក្រុមការងារនៅពេលនោះ ប្រហែលជាគាត់ស្តាប់ខ្ញុំអត់បានទេ។ ពីព្រោះខ្ញុំសូមបញ្ជាក់ជូនដែរ ថ្ងៃនេះដែលខ្ញុំមកជម្រាបជូននេះ គឺខ្ញុំនិយាយការពិត។ ប្រហែលជាគាត់ស្តាប់អត់បានទេ គឺឥតមានចេញទេ ស្រូវ គឺមានចេញតែអង្ករ។ តែដល់គាត់ស្តាប់ខ្ញុំមិនបាន គឺខ្ញុំចង់និយាយមួយថា អាចចេញទៅក្រៅហ្នឹង គឺវាតិចជាង គឺនៅក្នុងស្រុកទេ។ តិចហ្នឹង ខ្ញុំចង់និយាយថាអង្ករហ្នឹងគឺដែលចែកចាយនៅក្នុងស្រុកហ្នឹង គឺវាច្រើនជាងចេញទៅក្រៅ។ នេះក្រែងលោកស្តាប់អត់បាន។ ដូច្នេះ ខ្ញុំសូមបញ្ជាក់ជូនដែរថា ការនាំស្រូវចេញនេះ គឺខ្ញុំសន្មតិថាវាតិចដោយខ្ញុំប្រៀបធៀន ពីព្រោះស្រូវហ្នឹងគឺភាគច្រើនកិនជាអង្ករហើយបាននាំចេញ។ ហើយនាំចេញហ្នឹងមានអង្ករ១៥ភាគរយ និងអង្ករ៣៥ភាគរយ។ បើតាមខ្ញុំដឹង អង្ករចេញមានតែពីរមុខហ្នឹងដែលត្រូវនាំចេញ។ សូមជម្រាបជូនប៉ុណ្ណឹង។

[១០:២៨:១៤]

**ស៖** ខ្ញុំយល់ហើយ គឺថាលោកឆ្លើយថា គឺថាមាន ពិតជាមានអង្ករសម្រាប់ប្រជាជន សម្រាប់តម្រូវការក្នុងស្រុក។ មែនទេតាមចម្លើយរបស់លោកហ្នឹងគឺថាអង្ករនៅក្នុងឃ្លាំងហ្នឹងលោកហ្នឹងក៏មានទុកសម្រាប់តម្រូវការប្រជាជនក្នុងស្រុកដែរ។ អីចឹងមែនទេ?

**ឆ៖** នេះ ខ្ញុំសូមជម្រាបជូនលោកមេធាវីដែរថា កន្លងមក គឺសម្រាប់ជូនទៅប្រជាពលរដ្ឋដែលនៅតាមភូមិភាគ នៅតាមតំបន់ឥតមានទេ។ មានតែនៅក្នុងស្រុកហ្នឹង បានន័យថាគឺនៅក្នុងក្រសួងនៅក្នុងអង្គភាព ហើយនិងនាំចេញ។ តែដោយសារប្រទេសយើង វាជួបបញ្ហាទើបចប់ពីសង្គ្រាម ដូច្នេះការផលិតស្រូវ ផលិតអីហ្នឹង គឺវាបានតិច។ ដូច្នេះការនាំចេញហ្នឹងក៏វាបានតិច។ នេះសូមជម្រាបប៉ុណ្ណឹង។

**ស៖** នៅពេលដែលផលិតស្រូវបាន ស្រូវអង្ករបានតិចហ្នឹង គឺថាការនាំចេញក៏តិចទៅតាមហ្នឹងដែរ មែនទេការឆ្លើយរបស់លោកអម្បាញ់មិញនេះ?

**ឆ៖** ប្រាកដមែនហើយលោកមេធាវី។

[១០:៣០:៥៤]

**ស៖** ឥឡូវនេះខ្ញុំមកនិយាយអំពីលោក ខៀវ សំផន វិញម្តង។ តើនៅចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ លោកស្គាល់លោក ខៀវ សំផន ដែរឬទេ?

**ឆ៖** សូមជម្រាបលោកមេធាវី គឺខ្ញុំបាទស្គាល់គាត់ តែការស្គាល់ហ្នឹងគឺមិនបានជិតស្និទ្ធទេ ត្រឹមបានមួយស្គាល់មុខ។ ហ្នឹងសូមជម្រាបជូនប៉ុណ្ណឹង។

**ស៖** ខ្ញុំនឹងត្រឡប់មកនិយាយនៅពេលដែលលោកឃើញគាត់។ ប៉ុន្តែជាបឋមនោះខ្ញុំចង់ដឹងថា តើលោកដឹងថាតើគាត់កាន់មុខតំណែងអ្វីនៅក្នុងកម្ពុជាប្រជាធិបតេយ្យ?

**ឆ៖** សូមជម្រាបជូនលោកដែលថា កាលពីឆ្នាំ៧០ រហូតដល់ឆ្នាំ៧៣ រហូតទៅដល់ឆ្នាំ៧៥ ខ្ញុំត្រឹមបានមិនដែលបានឃើញគាត់ទេ តែគ្រាន់តែដឹងថា ក្រោយពីសម្តេចលោកបានប្រកាសឲ្យប្រជាពលរដ្ឋងើបឡើងដើម្បីតស៊ូរំដោះជាតិ។ ដូច្នេះគឺក្នុងចលនាពេលនោះ គឺត្រឹមមួយដឹងថាលោក ខៀវ សំផន, លោក ហ៊ូ យន់ ហើយនិងលោក ហ៊ូ នឹម សម្រាប់ជាអ្នកដឹកនាំ។ តែក្រោយមកទៀត មកដល់ឆ្នាំ៧៥ រហូតដល់គេប្រកាសនាយករដ្ឋមន្ត្រីទី១ គឺទើបបានខ្ញុំដឹងលោក ខៀវ សំផន មិនមែនជាអ្នកដឹកនាំធំទេបាទ។

[១០:៣៣:០៦]

**ស៖** តើលោកដឹងថា គាត់មិនមែនមេដឹកនាំធំហ្នឹងយ៉ាងម៉េចទៅ? លោកចង់មានន័យថាម៉េចត្រង់ចំណុចនេះ?

**ឆ៖** ពីព្រោះចំណុចមួយ ប្រជាពលរដ្ឋ ឬក៏កងទ័ពអ្នកណាក៏គេអាចថា យល់ថាគាត់ជាមេដឹកនាំធំដែរបីនាក់ហ្នឹង។ តែដល់មកពេលប្រកាសនាយករដ្ឋមន្ត្រីនេះ ទើបបានខ្ញុំដឹងថាគាត់មិនមែនជាមេធំជាងគេទេ។ នេះខ្ញុំសូមជម្រាបជូនអ៊ីចឹង។

**ស៖** តើមានព័ត៌មានអ្វីផ្សេងទៀតដែលធ្វើឲ្យលោកដឹងថា គាត់មិនមែនជាមេដឹកនាំធំជាងគេ ដូចដែលលោកបានឆ្លើយអម្បាញ់មិញនេះទេ?

**ឆ៖** ចំណុចនេះ គឺក្រោយពីខ្ញុំដឹងមក គឺក៏មិនមែនដឹងទៅតាមរយៈការចូលរួមប្រជុំ ការចូលរួម

ពិភាក្សា ឬក៏ការងារអ្វីមួយ គឺចាំបាច់ជាមួយថ្នាក់ដឹកនាំធំៗទេ ប៉ុន្តែគ្រាន់តែថាក្នុងអង្គភាពមួយតែងតែមានការជួបជុំគ្នា និយាយគ្នាពីនេះពីនោះទៅ គ្រាន់តែពិភាក្សាគ្នាមួយអាចដឹងថា លោក ខៀវ សំផន មិនមែនជាប្រធានធំជាងគេ គ្រាន់តែដឹងប៉ុណ្ណឹង។ តែក្នុងឋានៈគាត់ប៉ុនណាគឺខ្ញុំអត់ទាន់ដឹង គ្រាន់តែបានម៉ាតែប៉ុណ្ណឹងទេ។

**ស៖** ខ្ញុំសួរលោកឡើងវិញ គឺថានៅចន្លោះឆ្នាំ៧៥ដល់ឆ្នាំ៧៩ តើលោកធ្លាប់ឃើញគាត់ដែរឬទេ?

**ឆ៖** ខ្ញុំសូមជម្រាបដែលថា ខ្ញុំធ្លាប់ឃើញ។ តែគ្រាន់ថាពេលវេលាដែលខ្ញុំធ្លាប់ឃើញហ្នឹង គឺខ្ញុំអត់ចាំថ្ងៃទេ ពីព្រោះពេលនោះ គឺសូម្បីតែថ្ងៃសៅរ៍ ថ្ងៃអាទិត្យ ថ្ងៃពុធ ថ្ងៃព្រហស្បតិ៍ ក៏អត់មានអ្នកណាមួយចាំយកចិត្តទុកដាក់ថាថ្ងៃសៅរ៍ ថ្ងៃពុធ ថ្ងៃព្រហស្បតិ៍អីណាអត់ដឹងទេ។ ព្រោះការងារពេលនោះខ្លាចខុសសម្បើមណាស់។

[១០:៣៥:៤៧]

**ស៖** តើលោកថាឃើញហ្នឹង ឃើញគាត់នៅកន្លែងណាដែរ?

**ឆ៖** សូមជម្រាបដែលថា ពេលដែលឃើញហ្នឹង គឺនៅពេលដែលគាត់ហៅទៅរៀនសូត្រ។ ហ្នឹងខ្ញុំឃើញហើយ។

**ស៖** ខ្ញុំនឹងត្រឡប់មកនិយាយអំពីចំណុចនេះវិញ។ អ៊ីចឹងតើលោកមានធ្លាប់ឃើញគាត់នៅពេលណាមួយផ្សេងក្រៅពេលរៀនសូត្រហ្នឹងទេ?

**ឆ៖** អត់ដែលឃើញៗទេលោក។

**ស៖** ខ្ញុំចង់រំឭកការចងចាំរបស់លោក ដោយប្រើនូវចម្លើយរបស់លោកនៅចំពោះមុខអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេត។ អម្បាញ់មិញនេះ លោកបាននិយាយអំពីមនុស្សមកមើលការងារនៅឃ្លាំងរបស់លោក។ តើលោកចាំទេថាលោក ខៀវ សំផន ធ្លាប់មកពិនិត្យមើល ឬក៏ធ្វើទស្សនកិច្ចនៅឃ្លាំងរបស់លោកទេ?

**ឆ៖** សូមជម្រាបជូនដែលថា កន្លងមកគាត់ធ្លាប់ ធ្លាប់ឃើញមក ក៏ប៉ុន្តែគ្រាន់ថា ខ្ញុំមិនបានមកជិតគាត់ គ្រាន់តែដឹងថាគាត់មកមើលតែប៉ុណ្ណឹងទេ។

[១០:៣៧:៣២]

**ស៖** ឥឡូវនេះខ្ញុំសូមរំឭកការចងចាំរបស់លោក ពាក់ព័ន្ធទៅនឹងកាលៈទេសៈនៃការមកពិនិត្យមើលនេះ។ នៅក្នុងចម្លើយរបស់លោកនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត ខ្ញុំប្រគល់កំណត់ហេតុ

ស្ដាប់ចម្លើយសាក្សីមួយច្បាប់ គឺលេខ E3/469។

**ប្រធានអង្គជំនុំ៖**

លោកមេធាវីដល់ពេលសម្រាកហើយ។ បាទអង្គជំនុំជម្រះប្រកាសសម្រាក២០នាទី ចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងដប់មួយ សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។ មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្ដល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលសម្រាក ហើយនិងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្ដល់សក្ខីកម្មនេះវិញនៅវេលាម៉ោងដប់មួយ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:៣៩ នាទី ដល់ម៉ោង ១១:០០ នាទី)*

[១១:០១:០៦]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្ដល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដីលោក ខៀវ សំផន ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

សូមអញ្ជើញ!

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** លោកសាក្សី មុនពេលចូលទៅនិយាយអំពីកំណត់ហេតុស្ដាប់ចម្លើយនោះ។ ខ្ញុំចង់ត្រឡប់មកនិយាយអំពីចំណុចមួយ មុនពេលឈប់សម្រាកអម្បាញ់មិញនេះ គឺយើងនិយាយអំពីឈ្មោះ ឌឿន។ ហើយលោកបាននិយាយថា លោកមិនចាំឃើញ ឌឿន នេះ ឬក៏អត់ទេនៅសម័យនោះ។ ដូច្នេះខ្ញុំសូមអានផ្នែកមួយនៃប្រតិចារឹកនៃកិច្ចសម្ភាសន៍របស់លោកជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា គឺកិច្ចសម្ភាសន៍លើកទីពីរ ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០៤។ ឯកសារនេះ មានលេខ E190.1.67។ ERN ជាភាសាបារាំង

00753015, ERN ជាភាសាខ្មែរ 00020063, ជាភាសាអង់គ្លេស 00703027។ លោកបានឆ្លើយជាមួយអ្នកស្រាវជ្រាវ គេសួរលោកថា៖ “តើលោកដឹងថា អ្នកណាជាប្រធាន ក-២៥ ដែរឬទេ?” លោកបានឆ្លើយ៖ “ខ្ញុំដឹងថា ប៉ង់ ជាប្រធានមន្ទីរ ហើយខ្ញុំស្គាល់ឈ្មោះ ខឿន។ ខឿន មកឃ្លាំងជាញឹកញាប់ដើម្បីមកត្រួតពិនិត្យ។ ក៏ប៉ុន្តែខ្ញុំអាចសន្និដ្ឋានបានថា ខឿន ប្រហែលជាប្រធានឃ្លាំងហើយ”។ សំណួររបស់ខ្ញុំគឺថា តើលោកនឹកឃើញថា ខឿន ធ្លាប់ទៅពិនិត្យឃ្លាំងញឹកញាប់ដែរឬទេ? ឥឡូវនេះ ក្រោយពីខ្ញុំអានឯកសារនេះហើយនោះ។

[១១:០៣:៤៨]

**លោក រស់ ស៊ុយ៖**

**ឆ៖** សូមជម្រាបលោកមេធាវីដែលថា កាលនោះ ខ្ញុំសូមជម្រាបលោកមេធាវីដែលថា ការចងចាំរបស់ខ្ញុំមិនអាចបានអស់ទេ ដោយសារខ្ញុំអត់មានការចាប់អារម្មណ៍ពីរឿងបញ្ហាការងារដែលពាក់ព័ន្ធបានមកដល់ថ្ងៃនេះផង។ ហើយម្យ៉ាងទៀត គឺគ្រាន់តែដឹងថា ឈ្មោះណាមកៗអី គឺមិនដែលបានទៅជួបផ្ទាល់ទេ ហើយនិងឃើញមុខទេ គ្រាន់តែក្រោយពីចប់ទៅវិញ គេក៏និយាយគ្នាតៗថា នេះឈ្មោះៗប៉ុណ្ណឹងទេ។ តែក្រោយមកទៀត ក្រោយពីហេតុការណ៍ហ្នឹង វាចេះកើតឡើងបន្តៗមក គឺនេះគ្រាន់តែជាសន្និដ្ឋានទេ សម្រាប់ខ្ញុំយល់ថា ប៉ង់ ជាប្រធានមន្ទីរនេះ គឺគ្រាន់តែជាការសន្និដ្ឋានទេ។ ហើយឯសម្រាប់ ខឿន ដែលចូលមកនេះ ក៏គ្រាន់តែជាការសន្និដ្ឋានដែរ ព្រោះអត់ឃើញការរៀបចំឯណាទេ ព្រោះខ្ញុំសន្និដ្ឋានមួយថា បើអ្នកមិនពាក់ព័ន្ធនឹងការងារឃ្លាំងទេ ប្រហែលជាមិនចូលមកពិនិត្យទេ។ នេះគ្រាន់តែជាការសន្និដ្ឋានទេ។ សូមជម្រាបប៉ុណ្ណឹង។

[១១:០៥:០៥]

**ស៖** ដូច្នេះ គឺមានន័យថា លោកមិនដែលបានឃើញ ខឿន ទេ មែនទេ?

**ឆ៖** បាទ អត់ដែលឃើញទេ ប៉ង់ ក៏មិនដែលឃើញ ខឿន ក៏មិនដែលឃើញដែរ។

**ស៖** លោកសាក្សី អម្បាញ់មិញនេះចម្លើយចុងក្រោយរបស់លោកដូចជាមិនសូវច្បាស់ទេ ដូច្នេះខ្ញុំសូមរៀបចំសំណួរឡើងវិញដើម្បីឲ្យបានច្បាស់។ ដូច្នេះមានន័យថា បើតាមចម្លើយរបស់លោកនោះគឺថា លោកមិនដែលធ្លាប់ឃើញ ខឿន នៅឃ្លាំងទេមែនទេ? គឺថាផ្ទាល់ខ្លួនលោកនោះគឺថាលោកមិនដែលឃើញគាត់នៅឃ្លាំងទេ?

**ឆ៖** ខ្ញុំអត់ដែលឃើញគាត់ទេ ក៏ប៉ុន្តែដូចខ្ញុំបានជម្រាបខាងដើមអីចឹងថា រាល់អ្នកដែលចេញចូល

មកពិនិត្យមើលឃ្លាំងគឺខ្ញុំអត់ស្គាល់ តែអ្នកធំតែងតែមកញឹកញាប់ ក៏ប៉ុន្តែខ្ញុំអត់ស្គាល់។ តែឈ្មោះ ឌឿន ហើយនិងឈ្មោះ ប៉ង់ នេះគ្រាន់តែជាការសន្និដ្ឋានទេ បើគ្មានការងារអីពាក់ព័ន្ធជាមួយនឹងឃ្លាំង ប្រហែលជាមិនមកទេ អានេះគ្រាន់តែជាការសន្និដ្ឋានទេ។

[១១:០៦:៣៦]

**ស៖** លោកបានលើកឡើងអំពីទស្សនកិច្ចរបស់លោក ខៀវ សំផន នៅឃ្លាំង ក៏ប៉ុន្តែលោកថាលោកអត់ចាំ កាលបរិច្ឆេទទេ។ នៅក្នុងចម្លើយរបស់លោកដែលមានលេខ E3/469 ដែលលោកមាននៅក្នុងដៃហើយ ERN ជាភាសាខ្មែរ គឺថាលោកឃើញនៅខាងឆ្វេងដៃខាងលើមានលេខ ERN លេខខ្មែរគឺ 00172052, ERN ជាភាសាបារាំង 00524390, ERN ជាភាសាអង់គ្លេស 00205103 (សូមទោស) 5113 លោកបាននិយាយអំពីទស្សនកិច្ចរបស់ ខៀវ សំផន នៅឃ្លាំង។ លោកថា "ខ្ញុំដឹងថាលោក ខៀវ សំផន គាត់ភ្ញាក់ផ្អើលនៅពេលដឹងថាកម្មាភិបាលអត់បានហូបចុកគ្រប់គ្រាន់ គឺហូបតែបបរ មិនបានហូបបាយ"។ សំណួររបស់ខ្ញុំ ហេតុអីបានជាលោកដឹងថា លោក ខៀវ សំផន នោះភ្ញាក់ផ្អើល គឺថានៅពេលណាដែលលោកចង់សំដៅថាកម្មាភិបាលហ្នឹងហូបចុកមិនគ្រប់គ្រាន់ ហូបតែបបរនោះ?

**ឆ៖** សូមជម្រាបលោកមេធាវីដែរថា ចំណុចដែលខ្ញុំចាំមិនភ្លេចត្រង់ចំណុចដែលខ្ញុំបានបញ្ជាក់ថា លោក ខៀវ សំផន នឹងអាចភ្ញាក់ផ្អើលនេះគឺចំណុចមួយខ្ញុំចង់និយាយសំដៅទៅលើចំណុចមួយ។ អង្គភាពឃ្លាំងក្រោយពីគាត់បានតែងតែហៅក្រុមដឹកនាំថ្នាក់ក្រោមៗហ្នឹងទៅរៀនសូត្រអំពីការគ្រប់គ្រងឃ្លាំង ថែទាំសម្ភារៈ ហើយនិងទុកដាក់សម្ភារៈកុំឲ្យខូច កុំឲ្យខាត នេះការណែនាំនៅពេលដែលគាត់ហៅទៅរៀន។ តែខ្ញុំសន្និដ្ឋានក្រោយពីរៀនសូត្រហើយ ក្រុមនីមួយៗគឺមានការពិភាក្សា ដល់អ៊ីចឹងការសំណេះសំណាលគ្នាក្រៅហ្នឹងគឺសន្និដ្ឋានទេ ហើយអត់មានយល់ថាគាត់មានការភ្ញាក់ផ្អើលពីរឿងអីមួយទេ គឺគ្រាន់តែយល់សន្និដ្ឋានថា គាត់ច្បាស់ជាភ្ញាក់ផ្អើលហើយ ពីព្រោះគាត់ហៅឲ្យទៅរៀនសូត្រ គាត់ណែនាំឲ្យពីការគ្រប់គ្រងឃ្លាំង ថែទាំសម្ភារៈ។ ហើយអង្គភាពឃ្លាំងទាំងមូលទៀតមិនដែលហូបបបរទេ។ គ្រាន់តែការហូបបាយហ្នឹងគឺវាអត់គ្រប់គ្រាន់។ ហេតុដូច្នេះ ក្រុមដែលខ្ញុំរៀនសូត្រជាមួយនឹងគាត់ហ្នឹងគ្រាន់តែវិភាគគ្នាទៅថា ហាក់ដូចជាគាត់ភ្ញាក់ផ្អើលណាស់ ក្រោយពីដឹងថាកន្លែងផ្សេងហូបបបរនោះ។ នេះសូមបញ្ជាក់ខ្លីប៉ុណ្ណឹង ថាអាចគាត់ភ្ញាក់ផ្អើលពីរឿងថា ក្រោយពីឃើញកន្លែងផ្សេងៗហ្នឹង ហូបបបរនេះគ្រាន់តែការសន្និដ្ឋានរបស់ខ្ញុំទេ ហើយខ្ញុំចាំអត់ភ្លេចសម្ដីខ្ញុំដែលខ្ញុំបានផ្ដល់សក្ខីកម្មរួចមកហើយនោះបាទ។

[១១:០៩:៥៨]

**ស៖** ដើម្បីរំឭកការចងចាំរបស់លោក ខ្ញុំសូមអាននូវចម្លើយរបស់លោក គឺកិច្ចសម្ភាសន៍របស់លោកជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា កិច្ចសម្ភាសន៍លើកទី២ ERN ជាភាសាបារាំង 00 --

**អ្នកបកប្រែ៖**

លោកប្រធាន សូមឲ្យមេធាវីអានលេខ ERN ម្តងទៀត។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ERN ជាភាសាបារាំង 00753020, ERN ជាភាសាខ្មែរ 00020067, ERN ជាភាសាអង់គ្លេស 00703031។ លោកបាននិយាយអំពីរបបអាហារជាមួយ ស្ទីវ ហេដឌ័រ ដែលជាអ្នកសួរលោកគឺរបបអាហារនៅក្នុងឃ្លាំងរបស់លោក។ នេះជាចម្លើយរបស់លោក ស្ទីវ មានសួរលោកថា "របបអាហារគ្រប់គ្រាន់ដែរឬទេ?" លោកថា "គ្រប់គ្រាន់ ឬក៏មិនគ្រប់គ្រាន់នោះគឺមានបាយ ក៏ប៉ុន្តែមិនដែលហូបបបរទេ គឺថាគេដាក់ គេចែកជាបួនចំណែក គឺម្នាក់មួយដុំៗតាមទៅតាមរបបដែលចែក។ ចំពោះបបរនោះ គឺថាពួកយើងមិនដែលហូបទេ យើងហូបបាយ"។ សំណួររបស់ខ្ញុំនោះ គឺចង់ដឹងប្រសិនបើលោកថាលោក កន្លែងលោកគឺមិនដែលហូបបបរទេ។ ចុះម៉េចក៏លោកឆ្លើយថាលោក ខៀវ សំផន ភ្ញាក់ផ្អើលនៅពេលដឹកថាកម្មករិបាលហូបបបរ?

[១១:១១:៥៨]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! សូមអញ្ជើញសហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណ ខ្ញុំសូមបដិសេធនឹងសំណួរនេះ ពីព្រោះគាត់កំពុងតែសុំឲ្យសាក្សីធ្វើការសន្និដ្ឋានអ្វីដែលគាត់អាចនឹកឃើញ ហើយនិងគាត់សង្ស័យនូវអ្វីដែលមាននៅក្នុងចិត្តរបស់លោក ខៀវ សំផន។ ដូច្នេះ នេះគឺជាអ្វីមួយដែលគិតថាមិនសមស្រប ពីព្រោះថាគាត់អត់បានពិភាក្សាជាមួយលោក ខៀវ សំផន អំពីរឿងហ្នឹងទេ គាត់គ្រាន់តែចង់ឲ្យគាត់គិតអំពីថាអ្វីដែលលោក ខៀវ សំផន គិតដូច្នេះ។ វាគឺជាសំណួរមួយដែលមានលក្ខណៈឧបមានវិធី។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** លោកសាក្សី តើខ្លឹមសារដែលខ្ញុំអានអម្បាញ់មិញនេះ ពាក់ព័ន្ធទៅនឹងរបបអាហារនៅ

ឃ្លាំងរដ្ឋហ្នឹង គឺត្រឹមត្រូវដែរឬទេ? វាដូចទៅនឹងអ្វីដែលលោកបានឆ្លើយទៅនឹងអ្នកដែលសម្ភាសលោកនៅថ្ងៃនោះដែរឬទេ?

**លោក រស់ ស៊ុយ៖**

**ឆ៖** នេះវាជារឿងមួយត្រឹមត្រូវណាស់។ ខ្ញុំសូមជម្រាបលោកមេធាវីដែរថា ចំណុចនេះគឺអ៊ីចឹងបានថា បើលោករំឭក គឺខ្ញុំមានការចងចាំត្រង់ចំណុចមួយថា បាយគឺមិនដែលហូបគ្រប់ ក៏ប៉ុន្តែគ្រាន់មិនដែលហូបបបរ។ ហើយបាយហ្នឹង គឺគេចំហុយ។ ចំហុយហើយ ក្នុងឡាំងស៊ីងមួយហ្នឹង គឺគេពុំជាប្ចូន។ ដូច្នេះការហូបហ្នឹងវាអត់គ្រប់គ្រាន់ តែវា១ថាវាគ្រាន់បើជាងហូបបបរតែប៉ុណ្ណឹងទេ។ ខ្ញុំសូមជម្រាបជូនប៉ុណ្ណឹង។

[១១:១៣:៤២]

**ស៖** ខ្ញុំចូលទៅប្រធានបទផ្សេងមួយទៀត ពីព្រោះពេលវេលាកាន់តែខិតហើយ។ ខ្ញុំមានចំណុចមួយទៀតចង់ឱ្យរំឭកការចងចាំរបស់លោក។ គឺជាអ្វីដែលលោកបានកត់សម្គាល់ឃើញ នៅពេលដែល ខៀវ សំផន ចុះមកពិនិត្យនៅឃ្លាំង។ គឺកិច្ចសម្ភាសន៍ដដែលជាមួយនឹងមជ្ឈមណ្ឌលឯកសារកម្ពុជា, ជាភាសាបារាំង 00755316, ជាខ្មែរ 00020063, ជាភាសាអង់គ្លេស 00703028។ នេះជាចម្លើយរបស់លោកពាក់ព័ន្ធទៅនឹងអ្វីដែលលោកកត់សម្គាល់ឃើញពាក់ព័ន្ធនឹងលោក ខៀវ សំផន។ លោកឆ្លើយថា “ខ្ញុំដឹងថាការងាររបស់ ខៀវ សំផន នេះគ្រាន់តែជាការងារបន្ទាប់បន្សំទេ។ គឺថាការងារគាត់ហ្នឹង ជាការងារសង្គមកិច្ច។ នៅក្នុងសង្គមកុម្មុយនីស្ត ប្រធានគណៈប្រធានរដ្ឋ គឺថាមិនធ្វើការចាំបាច់ខានមិនបាននោះទេ គឺបញ្ហាទាំងអស់ចេញមកពីបក្ស។ ដល់អ៊ីចឹងគាត់ប្រជុំការងារអី សូម្បីតែស្បែកជើង សូម្បីតែឡានគាត់ហ្នឹង គឺអត់មានហ៊ឺហាអីដូចគេទេ។ អាហ្នឹងខ្ញុំមើលឃើញជាក់ស្តែងដែលពេលដែលគាត់ដើរមើលឃ្លាំងមើលអីហ្នឹង គឺឡានកញ្ចាស់ ហើយស្បែកជើងហ្នឹងក៏កញ្ចាស់ទៅទៀត។ គាត់ដើរមើលគេធ្វើការអីហ្នឹង គឺថាគ្មានអីហ៊ឺហាអីដូចគេទេ”។ សំណួររបស់ខ្ញុំ គឺខ្ញុំសួរថាតើលោកចាំអំពីចម្លើយរបស់លោកនេះទេ គឺថាលោកបានឆ្លើយបែបនេះនៅក្នុងកំណត់ហេតុនោះ?

[១១:១៦:០០]

**ឆ៖** សូមជម្រាបលោកមេធាវី--

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក អាប់ឌុលឡាក់ ចារីក៖**

លោកប្រធាន ខ្ញុំសូមជំទាស់សំណួរហ្នឹងពីព្រោះវាមានការបញ្ជាក់បីបួនចូលទៅក្នុងរឿងតែមួយ។ ដូច្នេះវាមានការច្រឡំណាស់ ពីព្រោះកាលមុនខាងសាក្សីហ្នឹងនិយាយថា គាត់អត់បានដឹងទេ អត់មានចំណេះដឹងអំពីរចនាសម្ព័ន្ធរដ្ឋាភិបាលរបស់បក្សកុម្មុយនីស្តកម្ពុជាទេ។ ឥឡូវហ្នឹង ខាងមេធាវីហ្នឹងសុំឲ្យសាក្សីនេះបង្ហាញអំពីយោបល់របស់គាត់។ ហេតុដូច្នេះខ្ញុំគិតថា បើសិនជាគាត់ចង់សួរពីបញ្ហានេះ គឺគាត់អាចសួរបញ្ជាក់ម្តងមួយៗទៅលើអង្គហេតុនីមួយៗ ជាជាងការសួរបញ្ចូលគ្នាទាំងអស់តែម្តង ដោយនូវអង្គហេតុទាំងអស់ហ្នឹង ដែលនាំទៅដល់គាត់ឆ្លើយសំណួរហ្នឹងដោយសារការស្មានៗបាទ។

[១១:១៦:៥១]

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធានខ្ញុំសូមឆ្លើយតបដោយខ្លី ខ្ញុំមិនលូកឡំគ្នាទេ ខ្ញុំគ្រាន់តែដកស្រង់នូវចម្លើយទាំងស្រុងរបស់សាក្សី ខ្ញុំអត់បានកាត់តចម្លើយទេ។ នេះគឺគាត់ឆ្លើយ គឺគាត់ឆ្លើយយោងទៅតាមការដឹងឮរបស់គាត់។ ដូច្នេះខ្ញុំគ្រាន់តែចង់ឲ្យគាត់បញ្ជាក់ថា គាត់ពិតជាបានឆ្លើយហ្នឹងទេ ហើយបន្ទាប់មកអង្គជំនុំជម្រះជាអ្នកវាយតម្លៃទៅ។ ក៏ប៉ុន្តែទោះជាយ៉ាងណាខ្ញុំគ្រាន់តែអាននូវចម្លើយរបស់គាត់ អត់មានការកាត់អីកែច្នៃចម្លើយទេ គឺចម្លើយទាំងស្រុងរបស់សាក្សីតែម្តង។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ដូច្នេះខ្ញុំសូមបញ្ជាក់សំណួររបស់ខ្ញុំឡើងវិញ។ តើការរៀបរាប់អំពី ខៀវ សំផន នៅពេលដែលគាត់មកដើរមើលឃ្លាំងនោះ វាដូចទៅនឹងអ្វីដែលលោកបានឃើញនៅសម័យនោះដែរឬទេ?

[១១:១៧:៤៩]

**លោក រស់ ស៊ុយ៖**

**ឆ៖** សូមជម្រាបលោកមេធាវី គឺចំណុចនេះប្រាកដដូចខ្ញុំបានជម្រាបជូនហើយ ពេលដែលខ្ញុំបានផ្តល់សក្ខីកម្មនោះ គឺដូចពាក្យហ្នឹងមែន។

**ស៖** ចំណុចចុងក្រោយដែលខ្ញុំចង់ពិភាក្សាជាមួយលោក។ លោកបានលើកឡើងវគ្គសិក្សាអប់រំជាមួយលោក ខៀវ សំផន តើលោកដឹងទេថាប្រធានបទនៅក្នុងវគ្គអប់រំរៀនសូត្រហ្នឹងគេនិយាយអំពីអ្វីដែរ?

**ឆ៖** ខ្ញុំអត់យល់អំពីប្រធានបទ ហើយនិងគោលបំណងនៃការគាត់ហៅទៅរៀនហ្នឹងទេ។ ប៉ុន្តែគ្រាន់តែចាំនូវពាក្យខ្លះ ការណែនាំខ្លះ ឲ្យថែទាំនិងគ្រប់គ្រងសម្ភារៈ គឺខ្ញុំចាំបានតែត្រឹមប៉ុណ្ណឹង ហើយមិនដែលឃើញគាត់និយាយអីក្រៅពីការគ្រប់គ្រង ហើយនិងថែទាំហ្នឹងទេបាទ។

**ស៖** ប្រសិនបើខ្ញុំយល់មិនច្រឡំទេ គឺថាការរៀនសូត្រដែលបង្រៀនដោយលោក ខៀវ សំផន នោះគឺនិយាយអំពីមធ្យោបាយបច្ចេកទេសក្នុងការរៀបចំចាត់ចែង គ្រប់គ្រងឃ្លាំង។ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ ប្រាកដអ៊ីចឹងមែន។

[១១:១៩:២៩]

**ស៖** តើលោក ខៀវ សំផន គាត់មានដែលបង្រៀនអំពីវគ្គអប់រំនយោបាយនៅពេលណាមួយទេ?

**ឆ៖** ពាក់ព័ន្ធនឹងបញ្ហារឿងនយោបាយ ក្រៅពីការគ្រប់គ្រងថែទាំនេះ គឺខ្ញុំអត់ដែលជួបទេ ជួបតែរឿងហៅថា និយាយពីទស្សនៈសភាពការណ៍បច្ចុប្បន្ន យើងត្រូវជាអ្នកទទួលផងដែលកសិករ ប្រជាពលរដ្ឋគាត់ខំធ្វើបានមកហើយ យើងថែទាំ បើយើងមិនទទួលខុសត្រូវ គឺកម្លាំងញើសឈាមរបស់ប្រជាពលរដ្ឋហ្នឹង គឺវាបាត់បង់ គឺខ្ញុំទទួលបានការអប់រំពីគាត់តែប៉ុណ្ណឹងទេបាទ។

**ស៖** សូមអរគុណ។ នេះជាចំណុចចុងក្រោយដែលខ្ញុំចង់ចោទសួរលោក។ នៅក្នុងកិច្ចសម្ភាសន៍របស់លោកទាំងពីរលើកជាមួយនឹងឯកសារកម្ពុជា ក៏ដូចជាជាមួយនឹងការិយាល័យសហចៅក្រមស៊ើបអង្កេត លោកបាននិយាយអំពីចម្លើយសារភាពរបស់ កុយ ធួន។ ដូច្នេះ ចេញពីចម្លើយផ្សេងៗគ្នារបស់លោកនេះ គឺថាលោកបានស្តាប់ចម្លើយរបស់ កុយ ធួន គឺថាគេចាក់ខ្សែអាត់ៗចម្លើយសារភាពឲ្យលោកស្តាប់។ នៅក្នុងកំណត់ហេតុចំពោះមុខសហចៅក្រមស៊ើបអង្កេត, ERN ជាភាសាបារាំង 00524389, ជាភាសាខ្មែរ 00172050 ហើយបន្តទៅដល់ទំព័របន្ទាប់ខាងមុខ។ ជាភាសាអង់គ្លេស 00205112។ លោកបានឆ្លើយថា ខ្ញុំសូមដកស្រង់ “នៅពេលដែលគេកំពុងចាក់ខ្សែអាត់នោះមានលោក ខៀវ សំផន ដែរ។ គាត់មានវត្តមាននៅទីនោះដែរ”។ បន្ទាប់មកទៀតលោកឆ្លើយថា “នៅពេលដែលគេសួរលោកថា តើ នួន ជា និងខៀវ សំផន ហ្នឹងឲ្យគេស្តាប់ចម្លើយសារភាពហ្នឹងប៉ុន្មានដងរបស់កុយ ធួន នោះ?” លោកបានឆ្លើយថា “មានតែ នួន ជា អ្នកចាក់ឲ្យស្តាប់នោះ ហើយខ្ញុំស្តាប់បានតែម្តងទេ”។

[១១:២២:២១]

ពាក់ព័ន្ធនឹងចំណុចនេះហាក់ដូចជាមានភាពផ្ទុយគ្នាបន្តិច។ គឺថានៅពេលដែលយើងស្តាប់ខ្សែអាត់នៃចម្លើយរបស់លោក ដែលបានផ្តល់ជូនសហចៅក្រមស៊ើបអង្កេតនោះ គឺឯកសារខ្សែអាត់លេខ

D94/16R។ ក្នុងចម្លើយនោះគឺលោកបានឆ្លើយនៅចំពោះមុខអ្នកស៊ើបអង្កេតនៃសហចៅក្រមស៊ើបអង្កេតថា នៅពេលចាក់ខ្សែអាត់នោះ ខៀវ សំផន មិនមានវត្តមាននៅទីនោះទេ។ ដូច្នេះនៅទីនេះ នៅចំពោះមុខអង្គជំនុំជម្រះនោះ តើលោកចាំអំពីកិច្ចប្រជុំនោះ ហើយនិងការចាក់ឱ្យស្ដាប់នូវចម្លើយសារភាពរបស់ កុយ ធួន ហើយលោករក្សាចម្លើយនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត ដូចមាននៅក្នុងខ្សែអាត់នោះ គឺថានៅនាទី គឺម៉ោង ០១:០៩:៣៧ ហើយនិងទៅដល់ម៉ោង ០៩:០៩:៥២។ គេសួរថា "ខៀវ សំផន មានចូលរួមចាក់ដែរ?" លោកឆ្លើយថា "អត់ទេ"។ ដូច្នេះតើលោកអាចបញ្ជាក់ជូនអង្គជំនុំជម្រះបានទេថា លោកចាំទេថាពេលនោះលោក ខៀវ សំផន មានវត្តមាន ឬអត់នៅក្នុងប្រជុំដែលគេចាក់នូវចម្លើយសារភាពរបស់លោក កុយ ធួន?

**ឆ៖** ខ្ញុំជម្រាបដែលថា បើតាមការចងចាំខ្ញុំមិនភ្លេច ខ្ញុំថាមិនមានទេ។ ក្រែងលោថាច្រឡំថាមាន មានហ្នឹងក៏ខ្ញុំមិនដឹងដែរ។ តែខ្ញុំគ្រាន់តែចាំពាក្យខ្ញុំថា "មិនមាន"ទេ វត្តមានលោក ខៀវ សំផន អត់មានទេ។

[១១:២៤:៤៤]

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណចំពោះពេលវេលាដែលលោកបានឆ្លើយទៅនឹងសំណួររបស់ខ្ញុំ។ ឥឡូវនេះ ខ្ញុំសូមប្រគល់វេទិកាហ្នឹងជូនលោក គង់ សំអុន ដើម្បីសួរសំណួរបន្ត។ សូមអរគុណលោកប្រធាន។

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ សូមគោរពអង្គសវនាការ។

**សួរដោយលោក គង់ សំអុន៖**

**ស៖** ជម្រាបសួរលោក រស់ ស៊ុយ។ ខ្ញុំឈ្មោះ គង់ សំអុន ជាមេធាវីរបស់លោក ខៀវ សំផន ហើយបន្តទៅនេះ ខ្ញុំមានសំណួរបន្តិចបន្តួចបន្ថែមពីសហការីរបស់ខ្ញុំ ទាក់ទងទៅនឹងចម្លើយរបស់លោក។ មុននេះលោកបានបញ្ជាក់ជូនអង្គជំនុំជម្រះអំពីមន្ទីរក-២៥ ដែលថាលោកបានទទួលសំណើបញ្ជាពីក-២៥ មកតាមរយៈរបស់លោកឈ្មោះ រឿង ដើម្បីឱ្យចែកចាយសម្ភារៈនៅក្នុងឃ្លាំង។ លោកអាចបញ្ជាក់បានទេថា តើវាជាមន្ទីរអ្វីដែរ ក-២៥ នោះ?

**លោក រស់ ស៊ុយ៖**

**ឆ៖** ខ្ញុំសូមជម្រាបជូនលោកមេធាវី បញ្ហាសំណួរលោកដែលបានលើកសួរមកខ្ញុំនេះ គឺខ្ញុំសូម

ជម្រាបដែរ ថាខ្ញុំដូចខ្ញុំបានឆ្លើយជម្រាបជូនពីខាងដើមហើយថា ខ្ញុំអត់ដឹងថា មន្ទីរហ្នឹង មន្ទីរអ្វី ហើយអ្នកចាត់ចែងអ្វី គ្រាន់តែឃើញ ក-២៥ កំណត់ឲ្យប្រគល់សម្ភារៈប៉ុនណោះ ប៉ុនណោះជូនតំបន់នេះ តំបន់នោះ តែប៉ុណ្ណឹងទេ។ តែឲ្យត្រង់ថា ចូលចេញ ហើយនិងជួបមុខ ហើយស្គាល់មន្ទីរនោះ គឺក៏អត់ដែលស្គាល់ទេ។ គ្រាន់តែឃើញការ គេហៅថា លេខ១ សំបុត្រ លេខ លិខិតអនុញ្ញាតតែប៉ុណ្ណឹងទេ ខ្ញុំអត់ដែលស្គាល់ទេ។ សូមជម្រាបជូនប៉ុណ្ណឹង។

[១១:២៦:៥៤]

**ស៖** បាទ លេខក-២៥ ដែលលោកឃើញនេះ លោកឃើញនៅក្នុងសំបុត្រប្រភេទយ៉ាងណាដែរ?

**ឆ៖** ខ្ញុំមិនអាចចាំបានទេលោក ពីព្រោះគ្រាន់តែខ្ញុំអាចដឹងថា ឲ្យតែមានឯកសារជាប៉ុង ឬក៏ជាប័ណ្ណ ឬក៏ជាឯកសារខ្នាតយ៉ាងម៉េចៗ ខ្ញុំអត់ចាំបានទេ។ ខ្ញុំគ្រាន់តែដឹងថា លោក រឿង ប្រាប់ថា "នែ៎! ដាក់អីវ៉ាន់ប៉ុនណោះ ជូនទៅអង្គភាពនេះ ជូនទៅក្រសួងនោះ"។ ហើយគ្រាន់តែយកសំបុត្រហ្នឹងមក គឺចំនួនប៉ុនណោះៗ គឺគ្រាន់តែ ខ្ញុំអត់បានចាប់អារម្មណ៍ថាពីទម្រង់ឯកសារហ្នឹងយ៉ាងម៉េចទេ គ្រាន់តែដឹងថាពី ក-២៥ មកៗ តែប៉ុណ្ណឹងទេ បាទ។

**ស៖** បាទ សូមអរគុណ។ លោកស្គាល់ឈ្មោះ លោក ខៀវ នៅ ទេ?

**ឆ៖** សូមសំណួរលោកម្តង បាទ។

**ស៖** ខ្ញុំសួរថា លោកស្គាល់ឈ្មោះ ខៀវ នៅ ទេ?

**ឆ៖** ខ្ញុំអត់ដែលស្គាល់ទេ បាទ។

**ស៖** លោកដែលធ្លាប់ទទួល ឬក៏បានសម្ភារៈឲ្យអ្នកមកពីភូមិភាគនិរតីទេ?

**ឆ៖** បាទ ខ្ញុំធ្លាប់បើកសម្ភារៈជូនភូមិភាគនិរតី ប៉ុន្តែភូមិភាគនិរតីជូនពេលខ្លះ មានអ្នកនេះមកជូនពេល មានអ្នកនោះមក។ ដូច្នេះ ខ្ញុំអត់កំណត់ស្គាល់អ្នកណាពិតប្រាកដបានទេ បាទ។

**ស៖** បាទ សូមអរគុណ។ លោកស្គាល់ឈ្មោះ សេន ទេ?

**ឆ៖** ខ្ញុំអត់ដែលស្គាល់ទេ បាទ។

[១១:២៨:២១]

**ស៖** ខ្ញុំសូមបញ្ជាក់ជូនលោកថា លោក ខៀវ នៅ គាត់បានមកធ្វើជាសាក្សីនៅទីនេះ ហើយដែលមានឯកសារបញ្ជាក់អំពីសវនាការរបស់គាត់ នៅលើឯកសារលេខ E1/90.1។ លោក ខៀវ នៅ ហ្នឹង គាត់បាននៅលើម៉ោង នៅពេលព្រឹក ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១២ ហ្នឹង គាត់ ពេលព្រឹកម៉ោង

មុនម៉ោង ១១:៤៤:០៧ បន្តិច គាត់បានមានប្រសាសន៍ថា "ខ្ញុំមានក្ឃួយប្រសារមួយនៅជាប់ជាមួយនឹងលោក ខៀវ សំផន។ ដូច្នេះខ្ញុំទាក់ទងតាមរយៈហ្នឹង គឺឈ្មោះ សេន ទាក់ទងតាមហ្នឹង ហៅថារបៀបមនោសញ្ចេតនា ធ្វើម៉េចឲ្យបានដំណឹងទៅដល់លើ" នេះជាមធ្យោបាយដែលគាត់បានស្នើសុំសម្ភារៈ។ ហើយនៅថ្ងៃដដែលហ្នឹង ឯកសារដដែល ប៉ុន្តែនៅម៉ោង ១៥:១៤:០២ នៅពេលដែលសួរថា "ឥឡូវខ្ញុំចង់យល់ឲ្យបានលម្អិត លោកនិយាយអំពីការិយាល័យមន្ទីរក-២២ តើអ្នកណាជាប្រធាន? ហើយប្រធាននោះមានតួនាទីអ្វី?" គាត់ឆ្លើយថា "ក-២២ ដែលខ្ញុំទាក់ទងនេះគឺឈ្មោះ សេន ត្រូវជាក្ឃួយប្រសាររបស់ខ្ញុំ ហើយសួរទៅថា នៅជាមួយលោក ខៀវ សំផន ត្រង់ចំណុចយ៉ាងម៉េចតទៅទៀត ខ្ញុំអត់ដឹងទេ"។

តើលោកដែលឮក-២២ នេះដែរទេ?

[១១:៣១:៤៨]

**ផ៖** សូមជម្រាបលោកដែរថាឮតែឈ្មោះទេ អត់ដែលស្គាល់ដែរ ហើយក៏អត់បានទំនាក់ទំនងទៀត។

**ស៖** ខ្ញុំសូមឲ្យលោកបញ្ជាក់ថា តើក-២២នេះ មានដែលស្នើសម្ភារៈមកលោកដែរទេ? សូមទោសខ្ញុំសូមបញ្ជាក់សំណួរខ្ញុំឡើងវិញ។ ខ្ញុំចង់សួរថា តើក-២២នេះ មានដែលបញ្ជូនសំណើមកលោកឲ្យបើកសម្ភារៈឲ្យទៅខាងភូមិភាគ ឬតំបន់ដែរទេ?

**ផ៖** សូមជម្រាបលោកមេធាវីថា ខ្ញុំមិនអាចចាំបានទេ ពីព្រោះការបើកសម្ភារៈនេះគឺតែបើកចេញទៅផុតហើយ គឺសឹងថាលែងមានការចងចាំហើយ ពីព្រោះការងារគឺវាច្រើនពេកដ៏អត់មានការចងចាំបានទេ។ ហើយក៏មិនសន្មតថា មិនបើក ឬមិនថាបើកទេ ដោយការ គេថាគ្មានការចងចាំ ខ្ញុំអត់ចងចាំបានបាទ។

**ស៖** បាទ សូមអរគុណ។ អ៊ីចឹងសូមបញ្ជាក់ឡើងវិញថា លោកមិនអាចចងចាំទៅលើបញ្ហាថាតើមាន ក-២២ ស្នើសុំមកលោកដែរឬទេ។ អ៊ីចឹងត្រឹមត្រូវទេ?

**ផ៖** បាទ ត្រឹមត្រូវហើយបាទខ្ញុំអត់ចងចាំមែន។

[១១:៣៣:២៧]

**ស៖** បាទ សូមអរគុណ។ ពីព្រឹកមិញក៏ដូចជានៅក្នុងកំណត់ហេតុរបស់លោកជាមួយនឹងសហចៅក្រមស៊ើបអង្កេតលោកបានបញ្ជាក់អំពីការប្រជុំរៀនសូត្រដែលមានលោក ខៀវ សំផន ចូលរួមផងដែរ ហើយជាពិសេសការរៀនសូត្រនោះគឺធ្វើប្រចាំឆ្នាំ ហើយលោកបានឆ្លើយបញ្ជាក់ថា លោកបានរៀន

សូត្របួនដងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ តើលោកនៅទទួលស្គាល់ថាអ៊ីចឹងត្រឹមត្រូវទេ?

**ឆ៖** បាទ ក្នុងសក្ខីកម្មរបស់ខ្ញុំគឺត្រឹមត្រូវមែនបាទ។

**ស៖** បាទ សូមអរគុណ។ លោកបានឆ្លើយបញ្ជាក់រួចហើយអំពីការជួបរៀនសូត្រជាមួយលោក ខៀវ សំផន អំពីកិច្ចការរដ្ឋបាល ហើយលោកបានណែនាំឲ្យថែទាំសម្ភារៈជាដើម។ ខ្ញុំចង់សួរបញ្ជាក់លោកនៅពេលមួយគឺនៅថ្ងៃទី០៥ ខែមករា ឆ្នាំ១៩៧៩។ តើលោកចាំបានថាលោកបានជួបប្រជុំជាមួយលោក ខៀវ សំផន ដែរទេនៅថ្ងៃនោះ?

[១១:៣៥:០០]

**ឆ៖** សូមជម្រាបលោកមេធាវី គឺខ្ញុំបានជួបរៀនសូត្រជាមួយគាត់មាននៅថ្ងៃ០៥។

**ស៖** លោកអាចបញ្ជាក់បានទេថា ម៉ោងចាប់ផ្ដើមពីម៉ោងប៉ុន្មានរហូតដល់ម៉ោងប៉ុន្មានដែរ?

**ឆ៖** សូមជម្រាបដែរថា កាលបរិច្ឆេទខ្ញុំអត់បានចាំទេ។ ខ្ញុំអត់ចាំ។ គ្រាន់តែបានដឹងថាថ្ងៃ០៥ហ្នឹងគឺបានរៀនជាមួយនឹងគាត់។

**ស៖** លោកអត់ចាំម៉ោង? លោកអាចបញ្ជាក់បានទេថា វាជាពេលព្រឹក ឬក៏ពេលរសៀល? ឬក៏ពេលយប់?

**ឆ៖** ជាចំណុចចាប់ផ្ដើម គឺចាប់ផ្ដើម ដែលចាប់ផ្ដើមទៅរៀន គឺទៅពីព្រឹកទៅហើយ តែកាលបរិច្ឆេទកំណត់ម៉ោង គឺខ្ញុំអត់ចាំបានទេ។

**ស៖** បាទ សូមអរគុណ។ លោកអាចបញ្ជាក់បានទេថា អ្នកណាជាអ្នកមកចូលរួមរៀនសូត្រជាមួយលោកនាពេលនុ៎ង? មានគ្នាច្រើនប៉ុនណា? ហើយមកពីខាងណាខ្លះ?

**ឆ៖** ខ្ញុំអត់អាចស្គាល់បានទេ ខ្ញុំគ្រាន់តែបានដឹងថា អង្គភាពឃ្លាំង ខ្ញុំមានអារម្មណ៍មួយគឺយកចិត្តទុកដាក់តែអង្គភាពឃ្លាំងមួយទេ។ ក្រៅពីហ្នឹង ខ្ញុំអត់បានចាប់អារម្មណ៍ទេបាទ។

[១១:៣៦:៣៥]

**ស៖** បាទសូមអរគុណ។ អង្គភាពឃ្លាំងហ្នឹងមកគ្នាប៉ុន្មាននាក់ដែរលោក?

**ឆ៖** សូមជម្រាបលោកដែរថា ចំនួនក៏ខ្ញុំអត់ចាំដែរ តែគ្រាន់តែដឹងថាថ្នាក់ដឹកនាំអនុសេនាតូច អនុសេនាធំ និងខ្លះជាមេក្រុមអ៊ីចឹង។ គ្រាន់តែបានដឹងត្រឹមប៉ុណ្ណឹង តែចំនួនអត់ចាំទេបាទ។

**ស៖** បាទ សូមលោកបញ្ជាក់ តើពេលហ្នឹង តើលោក ខៀវ សំផន និយាយអំពីអ្វីដែរ?

**ឆ៖** នៅថ្ងៃ០៥នោះ ខ្ញុំសូមជម្រាបលោកប្រធានដែរថា ក្រោយពីសភាពការណ៍នៅទីក្រុង

ភ្នំពេញមានសភាពប្រែប្រួលទៅ យើញថាគាត់ហៅទៅអប់រំណែនាំអំពីបញ្ហាសភាពការណ៍នៅកម្ពុជា ហើយក្រោយមកទៀត គាត់ថា យើងត្រូវតែចេញពីភ្នំពេញជាបណ្ដោះអាសន្ន។ នេះខ្ញុំសូមបញ្ជាក់ជូនប៉ុណ្ណឹង។ ខ្ញុំគ្រាន់ដឹងថា ឯខ្លឹមសាររៀនសូត្រផ្សេងៗទៀត ខ្ញុំអត់ចាំទេ គ្រាន់តែចាំបានពាក្យខ្លះ គាត់ថាឲ្យយើងចេញពីភ្នំពេញជាបណ្ដោះអាសន្នសិន។ នេះខ្ញុំចាំបានតែប៉ុណ្ណឹង។

**ស៖** បាទ សូមអរគុណ។ លោកមានអ្វីចង់បន្ថែមទៀតទេ?

**ឆ៖** បាទ ខ្ញុំអត់មានអីត្រូវបន្ថែមទេបាទ។

**លោក គង់ សំអុន៖**

សូមអរគុណលោកចំពោះការឆ្លើយសំណួររបស់ខ្ញុំ។ សូមអរគុណលោកប្រធាន។ ខ្ញុំអស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាបន្តអង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅក្រុមសហ -- តំណាងសហព្រះរាជអាជ្ញាដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះសាក្សី!

[១១:៣៨:៤៩]

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរសាជាថ្មី ជម្រាបសួរមេធាវីការពារក្ដី។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** ជម្រាបសួរលោក រស់ ស៊ុយ! អរគុណណាស់ដែលលោកបានអញ្ជើញមកជួយដល់តុលាការចំពោះការដឹងឮនូវព្រឹត្តិការណ៍ទាំងឡាយនៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។ ខ្ញុំឈ្មោះថារីក អាប់ឌុលឡាក់។ ខ្ញុំនឹងមានសំណួរមួយចំនួនសួរទៅលោកជាមួយសហការីរបស់ខ្ញុំដែលមកពីការិយាល័យសហព្រះរាជអាជ្ញា។ ខ្ញុំសូមចាប់ផ្ដើមជាមួយកិច្ចប្រជុំចុងក្រោយ ដែលលោកទើបរៀបរាប់អម្បាញ់មិញនេះ។ គឺកិច្ចប្រជុំដែលធ្វើឡើងនៅថ្ងៃទី០៥ ខែមករា។

[១១:៣៩:៥៧]

ខ្ញុំផ្ដោតទៅលើថាតើអ្នកណាចូលរួមនៅក្នុងកិច្ចប្រជុំនោះ។ ចម្លើយរបស់លោកជូនមជ្ឈមណ្ឌលឯកសារកម្ពុជា គឺឯកសារ 19.158 ERN, ជាភាសាខ្មែរ 00008336, បារាំង 00899501, អង់គ្លេស

00710554។ មជ្ឈមណ្ឌលឯកសារកម្ពុជាសួរ "ថាតើថ្នាក់ដឹកនាំកម្រិតណាចូលរួមនៅក្នុងកិច្ចប្រជុំនោះ?" លោកឆ្លើយថា "មានតែ ខៀវ សំផន ទេដែលចូលរួម"។ ហើយសំណួរបន្ទាប់សួរថា "តើអ្នកណាទៀតដែលគាត់បានហៅឲ្យមកចូលប្រជុំនោះ?" ចម្លើយលោកថា "អ្នកចូលរួមកពីក្រសួង និងមន្ទីរផ្សេងៗ។ អ្នកទាំងនោះគឺជាថ្នាក់ដឹកនាំកងទ័ព ឧស្សាហ៍កម្ម ពាណិជ្ជកម្ម និងឃ្លាំងរដ្ឋ"។ លោក ស៊ុយ តើត្រឹមត្រូវទេដែលថា អ្នកចូលរួមនៅក្នុងការប្រជុំនោះ គឺមានថ្នាក់ដឹកនាំមកពីកងទ័ព មកពីឧស្សាហ៍កម្ម និងពាណិជ្ជកម្ម ក្រៅពីឃ្លាំងរដ្ឋនោះ។ ត្រឹមត្រូវទេ?

[១១:៤១:៣០]

**ឆ៖** សូមជម្រាបលោកប្រធានថា ចម្លើយនេះគឺត្រឹមត្រូវហើយ គ្រាន់តែខ្ញុំបានបញ្ជាក់ខាងដើមជូនលោកមេធាវីលោក ខៀវ សំផន ថាខ្ញុំមិនអាចស្គាល់ គ្រាន់តែខ្ញុំបញ្ជាក់ថា ខ្ញុំអត់អាចស្គាល់គេទេ តែគ្រប់ក្រសួងមន្ទីរមករៀនមែន តែខ្ញុំអត់បានចាំ ហើយអត់បានស្គាល់។

**ស៖** តើយោធាថ្នាក់ ឬកម្រិតណាដែលមានវត្តមាននៅក្នុងកិច្ចប្រជុំនោះ តាមការកត់សម្គាល់របស់លោក?

**ឆ៖** សូមជម្រាបលោក ថាខ្ញុំអត់ស្គាល់ទេគ្រាន់តែឃើញឯកសារទេ តែខ្ញុំអត់ស្គាល់ថាក្នុងឋានៈប៉ុន្មានណាៗទេ ខ្ញុំគ្រាន់តែដឹងថាបើក្នុងអង្គភាពឃ្លាំងខ្ញុំស្គាល់ តែក្រៅពីហ្នឹងខ្ញុំអត់ដឹងថាគេមានឋានៈប៉ុន្មានណាៗមកទេ។

**ស៖** លោកបាននិយាយថា លោក ខៀវ សំផន បានហៅឲ្យលោកចូលប្រជុំនៅក្នុងកិច្ចប្រជុំនេះ។ ថាតើគាត់ហៅលោកដោយរបៀបណា? កោះលោកមកឲ្យប្រជុំហ្នឹងដោយរបៀបណាដែរ?

[១១:៤២:៥៨]

**ឆ៖** សូមជម្រាបលោកដែរថា កាលដែលលោក ខៀវ សំផន ហៅមកនេះគឺមិនមានជាចំណុចមួយដែលលោកហៅផ្ទាល់ទេ គឺតាមរយៈលោក រឿង, ហើយបានលោក រឿង ចាត់ចែងបន្តមកទៀតថាត្រូវ "អ្នក! វរសេនាតូចនេះត្រូវទៅប៉ុណ្ណេះនាក់ អនុសេនាធំនេះត្រូវទៅប៉ុណ្ណេះនាក់" អាហ្នឹងគឺលោក រឿង អ្នកចាត់ចែងទៅវិញបាទ។

**ស៖** តើនោះគឺជានីតិវិធី ឬក៏របៀបរបបតាមធម្មតាដែលលោកចូលរួមប្រជុំជាមួយនឹង ខៀវ សំផន ជារបៀបរបបតាមធម្មតាដែល រឿង មកពីឃ្លាំងរដ្ឋដែលត្រូវតែប្រាប់លោកថា លោកត្រូវប្រជុំនៅក្នុងកិច្ចប្រជុំដូចជាកិច្ចប្រជុំនេះជាដើម អ៊ីចឹងទេ?

**ឆ៖** នេះវាជារឿងមួយ គឺដោយសារតែសភាពការណ៍ប្រែប្រួលទេ បានជាការយល់ឃើញរបស់ខ្ញុំទេ ប្រហែលជាហៅទៅឲ្យជួបជុំគ្នាហ្នឹង គឺដើម្បីនិយាយពីហេតុការណ៍ដែលនៅកម្ពុជាមានបញ្ហាចុងក្រោយហ្នឹងបាទ។ នេះការយល់ឃើញរបស់ខ្ញុំ ខ្ញុំវិភាគឃើញទៅជាអ៊ីចឹង។

[១១:៤៤:២៥]

**ស៖** សូមអរគុណលោក។ បាទ បើពិនិត្យទៅលើអ្វីដែលពិភាក្សានៅក្នុងកិច្ចប្រជុំនោះ ខ្ញុំសូមចូលទៅចម្លើយរបស់លោក ដោយផ្តោតឲ្យបានលម្អិតបន្តិច។ ឯកសារដដែលលោកប្រធាន គឺ ERN ដែលខ្ញុំបានផ្តល់ពីខាងដើម បន្តពីឯកសារដែលខ្ញុំបានសួរ។ គេបានសួរលោកដូចតទៅ៖ "នៅក្នុងវគ្គសិក្សារៀនសូត្រនោះ តើគាត់បាននិយាយអំពីបញ្ហាអ្វីមួយជាមួយខ្មាំងផ្ទៃក្នុងដែរឬទេ?" ចម្លើយរបស់លោកថា "បាទ គាត់បាននិយាយ"។ សំណួរ "តើគាត់បាននិយាយអ្វី?" ចម្លើយរបស់លោក "យោងតាមការវាយតម្លៃរបស់គាត់ស្ថានភាពបច្ចុប្បន្នប្រហែលជាអាចបណ្តាលមកពីបញ្ហាផ្ទៃក្នុង។ បើមិនមានបញ្ហាផ្ទៃក្នុងគឺខ្មាំងខាងក្រៅគឺមិនអាចវាយប្រហារយើងបានទេ"។ តើត្រឹមត្រូវទេដែលថា ខៀវ សំផន បាននិយាយថាបញ្ហាជាមួយខ្មាំងខាងក្រៅ គឺវាកើតមានឡើងដោយសារតែបណ្តាលមកពីមានខ្មាំងផ្ទៃក្នុងនោះ?

**ឆ៖** សូមជម្រាបលោក បញ្ហាហ្នឹងគឺជារឿងត្រឹមត្រូវ ហើយការឆ្លើយរបស់ខ្ញុំ ខ្ញុំសូមឯកភាពទៅតាមអ្វីដែលខ្ញុំឆ្លើយហ្នឹង គឺប្រាកដមែន។

[១១:៤៦:១៨]

**ស៖** នៅក្នុងអត្ថបទដែលលោកបានអានពីខាងដើមនោះ លោកបាននិយាយ លោក ខៀវ សំផន បាននិយាយអំពីផែនការនាពេលអនាគត។ តើលោកអាចរៀបរាប់ឲ្យបានលម្អិតតិចទេ តើផែនការអ្វីដែលគាត់បាននិយាយ ហើយដែលលោក ហើយនិងអ្នកដទៃទៀតត្រូវអនុវត្តតាមនោះ?

**ឆ៖** ខ្ញុំសូមសំណួរលោកម្តងទៀតបាទ។

**ស៖** បាទបាន។ ឯកសារដែលខ្ញុំអានជូនលោកពីមុននេះ ខ្ញុំសូមអានម្តងទៀតដើម្បីឲ្យលោកបានយល់ពេញលេញ។ លោកបាននិយាយដូចតទៅ៖ លោកបាននិយាយចំពោះកិច្ចប្រជុំនោះថា អ្នកចូលរួមមកពីបណ្តាលក្រសួងផ្សេងៗ និងមន្ទីរផ្សេងៗ។ អ្នកទាំងនោះ គឺជាមេដឹកនាំទ័ពឧស្សាហកម្ម ពាណិជ្ជកម្ម និងឃ្លាំងរដ្ឋ។ នៅក្នុងកិច្ចប្រជុំនោះ គាត់បានពន្យល់អំពីស្ថានភាពនៃការវាយប្រហាររបស់ពួកវៀតណាម ដែលពួកគេបានដកថយទៅវិញ ហើយនិងផែនការនាពេលអនាគត។ ដូច្នេះ ខ្ញុំសូមឲ្យលោកពន្យល់បានលម្អិតបន្តិច។ តើនេះត្រឹមត្រូវទេដែលថាគាត់បាននិយាយអំពីការវាយប្រហារដោយ

ពួកវៀតណាម?

**ឆ៖** សូមជម្រាបលោកសហព្រះរាជអាជ្ញាដែលថា បញ្ហាដែលគាត់និយាយហ្នឹង គឺវាជារឿងមួយរឿងពិតហើយ ពីព្រោះជាធម្មតាការដឹកនាំ ឬក៏ជាការជួបជុំគ្នានេះ គឺប្រាកដជាមានទិសដៅៗ។ ឯចំណុចមួយគាត់ថា ឱ្យដកខ្លួនចេញពីភ្នំពេញសិននេះ គឺជាលក្ខណៈបណ្ដោះអាសន្នទេ ហើយចាំរៀបយុទ្ធសាស្ត្រវៃបកមកវិញ។ អាហ្នឹងគឺមានអ៊ីចឹងមែន។

[១១:៤៨:៣៥]

**ស៖** បើខ្ញុំយល់មិនច្រឡំទេ គឺគាត់បាននិយាយថា ផែនការគឺត្រូវចាកចេញពីក្រុងភ្នំពេញបណ្ដោះអាសន្នហើយ ដើម្បីរៀបចំផែនការប្រយុទ្ធជាមួយនឹងកម្លាំងវៀតណាម។ តើនេះត្រឹមត្រូវទេ?

**ឆ៖** នេះជាបញ្ហាត្រឹមត្រូវលោក។

**ស៖** សូមអរគុណលោក។ សូមចូលទៅពិនិត្យមើលវគ្គសិក្សាផ្សេងៗទៀតដែលលោកបានចូលរៀនសូត្រជាមួយលោក ខៀវ សំផន។ លោកបាននិយាយថា គឺកិច្ចប្រជុំនិយាយអំពីបញ្ហាបច្ចេកទេស។ ខ្ញុំសូមអានចម្លើយរបស់លោកតែម្ដង ដើម្បីជួយឱ្យលោករៀបរាប់ឱ្យបានលម្អិតបន្ថែមទៀត។ បាទ ឯកសារនេះគឺឯកសារ19.158, ERN សម្រាប់ផ្នែកនេះគឺខ្មែរ 00008305 ដល់ 6, បារាំង 00899473 ដល់4, អង់គ្លេស 00710531។

[១១:៥០:៣៣]

សំណួរដែលគេបានសួរលោកនោះ គឺ "តើ ខៀវ សំផន តែម្នាក់ទេ ដែលហៅរៀនសូត្រ?" ចម្លើយថា "បាទ គាត់បានហៅយើងឱ្យចូលទៅរៀនសូត្រផ្នែកការងាររដ្ឋបាល"។ ហើយខាងក្រោមនេះបន្តិច លោកបាននិយាយថា "តួនាទីរបស់គាត់ គឺត្រូវហៅប្រជាជនឱ្យចូលរៀនសូត្រ និងរៀបចំអំពីរចនាសម្ព័ន្ធរដ្ឋបាល ហើយចំពោះបញ្ហាផ្ទៃក្នុង គឺប៉ុល ពត ជាអ្នកនិយាយ"។ សំណួរបន្ទាប់ "តើលោកធ្លាប់រៀនសូត្រជាមួយ នួន ជា ទេ?" លោកឆ្លើយថា "បាទ ធ្លាប់រៀនជាមួយគាត់ដែរ"។ សំណួរ "តើ នួន ជា បង្រៀនពីអ្វីដែរ?" ចម្លើយ "គាត់បង្រៀនអំពីនយោបាយ"។ សំណួរ "ហើយចុះវាខុសគ្នាយ៉ាងម៉េចរវាងរដ្ឋបាល និងនយោបាយ?" ចម្លើយ "ទាំងពីរនេះគឺដូចគ្នា ប៉ុន្តែគ្រាន់តែមួយ គេថាត្រូវរៀបចំភូមិឃុំរៀបចំសណ្ដាប់ធ្នាប់ក្នុងភូមិឃុំអ៊ីចឹង នេះជាឧទាហរណ៍"។ ហើយខាងក្រោមលោកពន្យល់មកទៀត "ហើយខាងផ្នែករដ្ឋបាល គេហៅ។ ដល់ហើយបក្សហ្នឹង គេរៀបចំជាបង្រៀនគោលការណ៍ ត្រូវធ្វើអ៊ីចេះ ធ្វើអ៊ីចុះ"។

ដូច្នេះ តើនៅចំណុចចុងក្រោយនេះ តើនេះត្រឹមត្រូវទេ ដែលថាក្នុងវគ្គសិក្សានិយាយអំពីផ្នែក រដ្ឋបាល លោកនិយាយអំពីការរៀបចំរចនាសម្ព័ន្ធភូមិឃុំ និងរបៀបការពារភូមិឃុំ ត្រឹមត្រូវទេ?

**ឆ៖** បាទ ត្រឹមត្រូវ បាទ។

[១១:៥២:៣០]

**ស៖** ហើយពីខាងដើមបន្តិចនេះ លោកនិយាយថា “រដ្ឋបាល ហើយនិងនយោបាយ គឺដូចតែគ្នា។ ក៏ប៉ុន្តែរដ្ឋបាល គឺរៀបចំអំពីបញ្ហារដ្ឋបាលភូមិឃុំ និងការពារ”។ នេះគឺត្រឹមត្រូវដែរ ដែលថារដ្ឋបាល និង នយោបាយដូចតែគ្នានោះ ឬក៏វាខុសគ្នា?

**ឆ៖** នេះចំណុចមួយ បើតាមការវិភាគរបស់ខ្ញុំ គឺការរៀបចំរដ្ឋបាល ហើយនិងនយោបាយ ខ្ញុំ សន្និដ្ឋានថាមិនអាចដូចគ្នាបានទេ។ ព្រោះមូលហេតុ ដែលថាមិនអាចដូចគ្នា ដោយសារការងាររដ្ឋបាល អ្វីដែលផ្នែកនយោបាយ គឺគេអត់មាននិយាយពីការរៀបចំអីទេ គឺគេកំណត់យកតែម្ដង។ ហ្នឹង នយោបាយ។ តែបើការយល់ឃើញរបស់ខ្ញុំ គឺផ្នែករដ្ឋបាល គឺអ្វីដែលគេរៀបហើយ គឺយើងត្រូវអនុវត្ត ឬក៏ត្រូវធ្វើបន្ត ហើយនយោបាយ គឺគេកំណត់ទិសដៅ។ បាទ នេះការយល់ឃើញរបស់ខ្ញុំមានអ៊ីចឹង។

**ស៖** សូមអរគុណ។ ដូច្នេះ នយោបាយនិយាយអំពីការកំណត់គោលនយោបាយ ហើយរដ្ឋបាល និយាយអំពីការអនុវត្ត។ តើអ៊ីចឹងទេ?

**ឆ៖** បាទ អ៊ីចឹងមែន។

[១១:៥៣:៤៦]

**ស៖** បាទ សូមចូលទៅមើលបញ្ហាដែលលោកនិយាយថា “នួន ជា និយាយអំពីនយោបាយ”។ នៅក្នុងវគ្គសិក្សារបស់គាត់ហ្នឹង តើ នួន ជា ធ្លាប់ដែលនិយាយអំពីពួកក្បត់ ឬក៏ខ្មាំងផ្ទៃក្នុងអីដែរឬទេ?

**ឆ៖** ខ្ញុំសូមជម្រាបលោក បញ្ហាការដែលរៀនសូត្រជាមួយលោក នួន ជា គឺគាត់បង្រៀនពី នយោបាយ បង្រៀនពីទិសដៅដែលយើងត្រូវធ្វើឆ្ពោះទៅអីហ្នឹង គឺគាត់ធ្លាប់បានបង្រៀនបញ្ហាហ្នឹងមែន។ តែគ្រាន់តែថា កាលបរិច្ឆេទ ហើយនិងចំណុចរៀបរាប់លម្អិត ខ្ញុំអត់ចាំបាន បាទ។

**ស៖** ខ្ញុំសុំចង់បានចម្លើយសង្ខេប តើគាត់មាននិយាយអំពីពួកក្បត់ ឬក៏ខ្មាំងស៊ីរូងផ្ទៃក្នុងអីទេ?

**ឆ៖** ខ្ញុំធ្លាប់រៀនសូត្រជាមួយគាត់ ហើយក៏សូម្បីតែចម្លើយរបស់ កុយ ធួន ដែលគាត់ចាក់ឲ្យខ្ញុំ ស្ដាប់ក៏ខ្ញុំអត់ចាំបានដែរ។ តែក៏ធ្លាប់បានរៀបរាប់អំពីពួកជនក្បត់ហ្នឹងគឺធ្លាប់រៀបរាប់មែន ប៉ុន្តែគ្រាន់ថា ជនក្បត់នុ៎ងគឺមានសភាពយ៉ាងណាៗ គឺខ្ញុំអត់ដែលបានស្ដាប់ន័យនេះឲ្យច្បាស់ ឬក៏យកមកពិចារណា

យកទុកក្នុងចិត្តទេ គ្រាន់តែដឹងថាអ្នកណាក្បត់ អ្នកណាក្បត់តែប៉ុណ្ណឹងទេ។

[១១:៥៦:០២]

**ស៖** បាទ ខ្ញុំនឹងត្រឡប់ចូលមកនិយាយអំពីអ្វីដែលលោកនិយាយនៅបន្តិចទៀតនេះ ខ្ញុំសូមរំឭកការចងចាំរបស់លោកបន្តិច ពីសម្រង់ពីកិច្ចសម្ភាសន៍របស់លោកជាមួយនឹងចៅក្រមស៊ើបអង្កេត គឺ E3/469 លោកមានឯកសារនៅចំពោះមុខលោកហើយ។ ហើយបើសិនជាយើងមើលទៅទំព័រចាប់ផ្ដើមជាមួយ ERN ភាសាខ្មែរ 00172052, បារាំង 00524390, អង់គ្លេស 00205113។ បាទ គេបានសួរលោកដូចតទៅ “ក្រៅពីលោក នួន ជា ចាក់ខ្សែអាត់ តើគាត់បាននិយាយអំពីខ្សែក្បត់អីដែរទេ?” ចម្លើយថា “មានការនិយាយអំពីជនក្បត់ ខ្ញុំធ្លាប់ឮថា សោ ភឹម ជាជនក្បត់។ អ្នកនិយាយនោះគឺលោក នួន ជា។ គាត់និយាយថា សោ ភឹម ភូមិភាគបូព៌ាជាជនក្បត់, កុយ ធួន ភូមិភាគឧត្តរជាជនក្បត់។ តើនេះជាការសង្ខេបនូវអ្វីដែលលោកបានស្ដាប់ឮនៅពេលដែលលោក នួន ជា និយាយនៅក្នុងវគ្គរៀនសូត្រនោះទេ?

**ឆ៖** គឺប្រាកដអ៊ីចឹងមែនលោក។

**ស៖** សូមអរគុណ។ តើគាត់ធ្លាប់បាននិយាយថា តើត្រូវធ្វើយ៉ាងម៉េចជាមួយជនក្បត់ ឬក៏ថាត្រូវដោះស្រាយយ៉ាងណាជាមួយជនក្បត់នោះ?

**ឆ៖** សុំជម្រាបលោកដែរថា ក្រោយពីចំណុចដែលគាត់រៀបរាប់ហ្នឹងហើយ ក៏គាត់មានការណែនាំដែរថា “ត្រូវតែស្រាវជ្រាវ ហើយនិងពង្រឹងអង្គភាព វាយរកពួកជនក្បត់បន្តទៅទៀត”។ នេះបើតាមការចាំបានរបស់ខ្ញុំ គឺគាត់អប់រំណែនាំអ៊ីចឹង។

[១១:៥៨:៣៦]

**ស៖** តើមានឱកាសដាច់ដោយឡែកប៉ុន្មានដែរ ដែលលោកនៅចាំបានថា លោក នួន ជា បាននិយាយពីបញ្ហានេះ និយាយតែម្ដងទេ ឬក៏និយាយពីរដង ដោយសារថាលោកចូលរួមប្រជុំជារៀងរាល់ឆ្នាំ តើគាត់ធ្លាប់បាននិយាយលើសពីម្ដង ឬក៏និយាយពីបញ្ហានេះតែម្ដងទេ?

**ឆ៖** សូមជម្រាប ខ្ញុំអត់អាចចាំបានទេ គ្រាន់តែដឹងថា គឺគាត់ប្រាកដជានិយាយចំណុចនេះអ៊ីចឹងមែន តែកាលបរិច្ឆេទនិយាយគឺខ្ញុំអត់បានចាំ។

**ស៖** នៅក្នុងឯកសារដដែល ដែលខ្ញុំទើបអានជូនអម្បាញ់មិញ គឺលោកបាននិយាយដូចតទៅ “ខ្ញុំដឹងថា ប៉ង់ ត្រូវបានចាប់ខ្លួន ដឹងតាមរយៈការសំណេះសំណាលជាមួយអ្នកនៅអង្គភាពជាមួយ គេថាប៉ង់ ក្បត់ជាមួយ ប៉ុល ពត”។ តើលោកអាចរៀបរាប់បានទេ ការសំណេះសំណាលនេះគឺជាការសំណេះ

សំណាលធម្មតាជាមួយសហការី គឺការសំណេះសំណាលនៅពេលដែលលោកចូលរួមប្រជុំនោះ?

**ឆ៖** សូមជម្រាបលោកសហព្រះរាជអាជ្ញាដែរថា បញ្ហាដែលខ្ញុំសំណេះសំណាលនេះ គឺក្រោយពីមកពីរៀនសូត្រវិញទេ ដែលខ្ញុំសំណេះសំណាលនេះគឺមិត្តភក្តិនៅក្នុងអង្គភាព។ ហើយបញ្ហាក្រោយពីសភាពការណ៍អ្វីមួយកើតឡើង អង្គភាពមួយៗតែងជួបជុំគ្នា នៅពេលធ្វើការងារហ្នឹង គឺហើយសន្និដ្ឋានហើយ បាត់អ្នកនេះ បាត់អ្នកនោះ ចាប់អ្នកនេះអ្នកនោះហ្នឹង តែមិនគ្រាន់តែមិនប៊ានិយាយ។ មិនដឹងបាត់រឿងអី មិនដឹងជាចាប់រឿងអី គ្រាន់តែបានត្រឹមតែម៉ាដឹងថា គេចាប់អ្នកនេះ គេចាប់អ្នកនោះ ហើយបាត់អ្នកនេះបាត់អ្នកនោះតែប៉ុណ្ណឹងទេ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកតំណាងសហព្រះរាជអាជ្ញា។ អរគុណសាក្សី។ ឥឡូវនេះដល់ពេលសម្រាកអាហារថ្ងៃត្រង់ហើយ។ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយសាមសិននាទីរសៀលនេះអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សីដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលសម្រាកអាហារថ្ងៃត្រង់ ហើយនិងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញនៅរសៀលនេះ នៅវេលាម៉ោងមួយសាមសិបនាទី។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងខ្លួនលោក ខៀវ សំផន ទៅកាន់បន្ទប់រង់ចាំនៅខាងក្រោមសាលសវនាការនេះ ហើយនិងឲ្យនាំគាត់ត្រឡប់មកកាន់បន្ទប់សវនាការនេះវិញ នៅរសៀលនេះឲ្យមុនម៉ោងមួយសាមសិននាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១២:០១ នាទី ដល់ម៉ោង ១៣:៣៥ នាទី)*

[១៣:៣៥:៤៣]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាដើម្បីមានឱកាសក្នុងការបន្តតាំងសំណួរដេញដោលចំពោះសាក្សី។ សូមអញ្ជើញ!

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរអស់លោក លោកស្រីទាំងអស់។ សូមជម្រាបសួរលោក រស់ ស៊ុយ។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** មុនពេលដែលយើងឈប់សម្រាកយើងបានពិភាក្សាទៅលើប្រធានបទមួយ ដែលនិយាយអំពីការរៀនសូត្រ ដែលលោកបានចូលរៀន។ វគ្គរៀនសូត្រដែលលោកបានចូលរួមជាមួយនឹងលោក នួន ជា និងលោក ខៀវ សំផន។ ហើយយើងបានពិភាក្សាអំពីប្រធានបទដែលបានលើកយកមកពិភាក្សានៅក្នុងវគ្គរៀនសូត្រនោះ។

[១៣:៣៦:៤២]

ឥឡូវនេះខ្ញុំចង់សាកសួរបន្ថែម ដោយធ្វើការអានជូននូវកិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា។ ហើយលោកអាចពិនិត្យមើល ហើយបន្ទាប់មកយើងនឹងពិភាក្សាថាតើលោកអាចចែករំលែកនូវព័ត៌មានបន្ថែមទៀតឬក៏អត់?

ឯកសារនេះគឺឯកសារ E190.1.67 ហើយមានលេខ ERN ខ្មែរមានលេខ 0000886 ដល់ 87, បារាំងមានលេខ 00899474 ដល់ 5 និងភាសាអង់គ្លេសមានលេខ 00710532។ ហើយខ្ញុំសូមធ្វើការអាននូវចម្លើយរបស់លោកពីរបីចំណុច ហើយបន្ទាប់មកយើងនឹងពិភាក្សាបន្ត។ ទី១ គឺពាក់ព័ន្ធទៅនឹង សោ ភឹម លោកបាននិយាយដូចតទៅនេះ៖ “ខ្ញុំដឹងអំពី សោ ភឹម នៅពេលដែលគេហៅទៅរៀននយោបាយ។ នៅទីនោះគេនិយាយអំពីជនក្បត់។ គេបាន -- គេចាប់បានខ្សែបានរហូត គ្រាន់តែដឹងថាចលនាមាន។ យើងត្រូវតែតាមដានមើលពួកបង្កប់ ហើយនិងខ្សែពួកបង្កប់”។

ហើយលោកបាននិយាយបន្តទៅទៀតថា “ខ្ញុំដឹងពេលទៅរៀននយោបាយ។ ឧទាហរណ៍ គេនិយាយថា គេបានចាប់ពួកនៅក្នុងខ្សែបង្កប់មួយហ្នឹង គេប្រាប់យើងថា គេនឹងតាមដានសភាពការណ៍ឲ្យបានជាប់លាប់ ហើយគេបានបោះពុម្ពផ្សាយឯកសារទាំងអស់ហ្នឹងនៅក្នុងឯកសារទង់ប្រាំ”។

ឥឡូវនេះខ្ញុំសូមបញ្ចប់ការអានរបស់ខ្ញុំ។ ប៉ុន្តែខ្ញុំចង់ដឹងថាតើអ្នកណាជាអ្នកប្រាប់អំពីខ្សែ ឬក៏បណ្តាញបង្កប់នោះ?

[១៣:៣៩:០០]

**លោក រស់ ស៊ុយ៖**

**ឆ៖** សូមជម្រាបលោកថា ក្រោយពីការរៀនសូត្រហើយ ខ្ញុំបានឮពាក្យមួយដែលថា សោ ភឹម ជាអ្នកក្បត់ហ្នឹងគឺក្រោយពីរៀនសូត្រហ្នឹង គឺឮលោក នួន ជា គាត់និយាយក្នុងពេលដែលរៀនសូត្រហ្នឹងតែម្ដងបាទ។ ហើយបញ្ហាតាមដានសកម្មភាពខ្សែបង្កប់ ខ្សែអីហ្នឹងក៏មានការណែនាំដែរ តែក្រោយពីការរៀនសូត្រហើយមកដល់វិញ ក៏បញ្ហាទាំងអស់នេះក៏ខ្ញុំអត់បានក្ដាប់បានថា វាមានបញ្ហាហេតុការណ៍បន្តយ៉ាងម៉េចទៀតទេបាទ។

**ស៖** នៅពេលដែលលោកនិយាយថាមានការរៀនសូត្របន្តនោះ។ តើវគ្គមួយណា? វគ្គដែលគេរៀបនៅឃ្លាំងរដ្ឋ ឬក៏វគ្គរៀនសូត្រដែលគេរៀនរៀបចំនៅកន្លែងផ្សេងទៀត?

**ឆ៖** នៅពេលដែលរៀនសូត្រហ្នឹង គឺខ្ញុំមិនបានចាំកាលបរិច្ឆេទច្បាស់លាស់ទេ គ្រាន់តែដឹងថាពេលរៀនសូត្រជាមួយលោក នួន ជា ពេលខ្លះរៀននៅវត្តឧណ្ណាលោម, ពេលខ្លះរៀននៅបុរីកីឡា, ពេលខ្លះរៀននៅស្ដាតអូឡាំពិក។ នេះមានប៉ុណ្ណឹង។

**ស៖** តើវគ្គរៀនសូត្រហ្នឹង គឺ នួន ជា ជាអ្នកដឹកនាំវគ្គ ឬមួយក៏អ្នកផ្សេងទៀតជាអ្នកដឹកនាំវគ្គនោះ?

**ឆ៖** បាទ វគ្គរៀនសូត្រហ្នឹងគឺលោក នួន ជា គាត់ជាអ្នកបង្រៀន ក៏ប៉ុន្តែគ្រាន់ថាជាកិច្ចចាប់ផ្ដើមមានអ្នករៀបចំកម្មវិធីបន្តបន្ទាប់មក ដែលខ្ញុំអត់បានស្គាល់ទេ ក៏ប៉ុន្តែដល់ពេលចាប់ផ្ដើមបានគាត់ឡើងឧទ្ទេសនាមបាទ។

[១៣:៤១:២៧]

**ស៖** តើមានអ្នកដឹកនាំជាន់ខ្ពស់មកពីបក្ស ចូលរួមនៅក្នុងវគ្គនោះដែរឬទេ?

**ឆ៖** ជម្រាបលោកដែលថា ខ្ញុំអត់សូវស្គាល់ មានដែរ តែខ្ញុំអត់ស្គាល់។

**ស៖** តើវគ្គរៀនហ្នឹង គឺគេធ្វើឡើងនៅកន្លែងតែមួយ និងនៅពេលតែមួយដូចវគ្គដែលបង្រៀនដោយ ខៀវ សំផន ដែរ ឬមួយក៏មិនមែនទេ?

**ឆ៖** អត់ទៀងៗទេ។ ជួនពេលខ្លះ ដូចខ្ញុំបានជម្រាបខាងលើអ៊ីចឹងថា ជួនពេលខ្លះបង្រៀននៅបុរីកីឡា ជួនពេលខ្លះបង្រៀននៅស្ដាតអូឡាំពិក។

**ស៖** ប៉ុន្តែតើវគ្គដែលបង្រៀនដោយ ខៀវ សំផន តើវគ្គហ្នឹងគេធ្វើឡើងនៅពេលជាមួយគ្នាជាមួយ

នឹងវគ្គដែលបង្រៀនដោយ នួន ជា ឬមួយក៏ធ្វើនៅពេលខុសគ្នា?

**ឆ៖** បាទ ជម្រាបធ្វើខុសគ្នាបាទ។

[១៣:៤៣:០៩]

**ស៖** ឥឡូវនេះខ្ញុំនឹងលើកប្រធានបទថ្មីមួយទៀត មុននឹងយើងបន្តទៅដល់ប្រធានបទខ្លាំង ហើយ អ្វីដែលខ្ញុំចង់និយាយនេះ គឺនិយាយអំពីបញ្ហានៃការប្រតិបត្តិការនៅឃ្លាំងរដ្ឋ គឺឃ្លាំងដែលលោកធ្វើការនៅ ពេលនោះ។ បញ្ហាទី១ ដែលលោកបានពិភាក្សាជាមួយសហការីរបស់ខ្ញុំ គឺនិយាយអំពីការនាំចេញ។ ហើយផ្អែកទៅលើចំណុចនេះ ខ្ញុំសូមអាននូវរបាយការណ៍ចម្លើយរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាដែល លោកបានឆ្លើយ។ បន្ទាប់មក យើងនឹងពិភាក្សាថាតើលោកអាចផ្តល់ព័ត៌មានបន្ថែម ឬក៏អត់ទាក់ទងទៅ នឹងការនាំចេញ ក៏ដូចជាទំនិញដែលនាំចេញ។

អានេះគឺនិយាយអំពីឃ្លាំងគីឡូ៦ គឺឯកសារដែលមានលេខ E188 ដែលមានលេខ ERN គឺខ្មែរ មានលេខ 00008289 ដល់90, បារាំងមានលេខ 00899458 ដល់9, និងភាសាអង់គ្លេសមានលេខ 00707518 ដល់9។ គេសួរលោកនូវចម្លើយដូចទៅ៖ “តើមានការនាំស្រូវអង្ករទៅបរទេសទេ?” លោកឆ្លើយថា “បាទមាន”។ សំណួរ “តើច្រើនទេ?” លោកឆ្លើយថា “នៅពេលដែលនាំចេញម្តងៗ មាន ប្រហែលជា៦០ ទៅ១០០គីឡូ។ ខ្ញុំដឹងថា គេនាំទៅកាណាដា ហើយនិង ហុងកុង។ ខ្ញុំដឹងអំពីបញ្ហានេះ ដោយសារតែមានការបោះត្រា ដែលថាត្រូវនាំអង្ករហ្នឹង ទៅកំពង់សោម”។

[១៣:៤៥:២៦]

ឥឡូវនេះ ទាក់ទងទៅនឹងចំនួននូវការនាំចេញនោះ។ លោករៀបរាប់អំពីវេចខ្ចប់ ក៏ដូចជាការដឹក ជញ្ជូន ហើយលោកបានឆ្លើយដូចតទៅនេះ៖ “ម៉ាស៊ីននៅរោងកិនស្រូវគីឡូម៉ែត្រ៦ គឺអាចធ្វើការកែ សម្រួល ឬក៏អាចវេចខ្ចប់ដោយស្វ័យប្រវត្តិ”។ ហើយក្រោយមកបន្តិចទៀត លោកឆ្លើយថា “អង្ករត្រូវ បានគេបញ្ចូលទៅក្នុងបាវ ហើយគេដាក់នៅតាមបាវ។ នៅពេលដែលគេដាក់ចូលបាវគ្រប់ គឺគេដាក់ត្រឹម ១០០គីឡូ ហើយបន្ទាប់មក អូតូម៉ាទិកវាទម្លាក់មកក្រិបអ៊ីចឹងតែម្តង ហើយយើងដោះក្រវាត់ហ្នឹងចេញ។ ដូច្នេះហើយ គឺគេធ្វើអ៊ីចឹង គឺច្បាស់តែម្តងថាអង្ករហ្នឹង គឺ១០០គីឡូ ហើយបាវហ្នឹង១គីឡូ។ ម៉ាស៊ីនហ្នឹង អាចខ្ចប់ប្រហែលជា១៦០០បាវ ទៅ១៧០០បាវ ក្នុង១ថ្ងៃ”។

តើអ្វីដែលខ្ញុំអានហ្នឹង វាត្រឹមត្រូវដែរឬទេ អំពីការដែលគេវេចខ្ចប់អង្ករ ដែលថាដាក់ម្តង១០០គីឡូ ហើយធ្វើប៉ុន្មានពាន់បាវប៉ុណ្ណឹង។ តើវាត្រឹមត្រូវដែរឬទេ?

[១៣:៤៦:៤២]

**ឆ៖** បាទ ខ្ញុំសូមបញ្ជាក់ជូនលោកដែរថា អ្វីដែលខ្ញុំបានផ្ដល់នេះ ហើយលោកបានតាំងសំណួរសួរមកខ្ញុំនេះ គឺប្រាកដជាបញ្ហាហ្នឹង គឺត្រឹមត្រូវមែន បាទ។

**សៈ** សូមអរគុណលោកសាក្សី។ ហើយក្រោមបន្តិចទៀត លោកបានឆ្លើយថា "ប្រសិនបើយើងបើករោងម៉ាស៊ីនស្រូវតែមួយ យើងមិនអាចបំពេញតម្រូវការបានទេ"។ ហើយក្រោមបន្តិចទៀត លោកបានឆ្លើយថា "មានរោងម៉ាស៊ីនស្រូវប្រហែលប្រាំ ទៅប្រាំមួយ ត្រូវដំណើរការក្នុងពេលជាមួយគ្នា"។ តើវាត្រឹមត្រូវដែរឬទេ ដែលថាមានម៉ាស៊ីនបួនប្រាំហ្នឹង ត្រូវកិនស្រូវក្នុងពេលជាមួយគ្នា ដើម្បីធ្វើការច្រកឲ្យបានគ្រប់១០០គីឡូ នៅតាមបាវមួយៗហ្នឹង។ តើត្រឹមត្រូវទេ?

**ឆ៖** បាទ ត្រឹមត្រូវលោក។

**សៈ** នៅក្នុងចម្លើយលោកដដែលនេះ នៅលើបន្តិច លោកបានឆ្លើយថា គេសួរលោកថា "តើស្រូវអង្ករហ្នឹង មានបញ្ជូនទៅផ្នែក ឬក៏អង្គការដទៃទៀតទេ?" លោកថា "នៅទីក្រុងភ្នំពេញហ្នឹង គឺផ្នែកឬអង្គភាពនានា មកយកអង្ករពីឃ្លាំង"។ តើត្រឹមត្រូវដែរឬទេ ដែលថាក្រសួង ឬមន្ទីរនានានៅក្នុងក្រុងភ្នំពេញហ្នឹង គេមកយកស្រូវអង្ករពីឃ្លាំងគីឡូម៉ែត្រ៦ នុ៎ង?

**ឆ៖** បាទ ត្រឹមត្រូវ បាទ។

[១៣:៤៨:៣៥]

**សៈ** នៅក្នុងគ្រប់ករណីទាំងអស់នេះ តើការបែងចែកអង្ករហ្នឹង ត្រូវមានការអនុម័តយល់ព្រមពីមន្ទីរ ក-២៥ ដូចដែលលោកបានរៀបរាប់ពីមក ឬក៏គេត្រូវការនូវវិធីសាស្ត្រផ្សេងទៀត គឺថានីតិវិធីផ្សេងទៀត ហើយនិងការអនុម័តដើម្បីបែងចែកអង្ករនោះ?

**ឆ៖** បាទ សូមជម្រាបដែរថា រាល់ការចែកចាយហ្នឹង គឺមានតែចេញពី ក-២៥ មួយទេ ដែលមានត្រូវតែយកឯកសារ យកទៅបើកហ្នឹង គឺមានតែចេញពី ក-២៥ ទេ បាទ។

**សៈ** តាមដែលខ្ញុំយល់ពីអ្វីដែលលោកបានផ្ដល់ពីមុននេះ គឺថាមិនមានការអនុម័តយល់ព្រម ឬក៏ការបែងចែកអង្ករទៅតាមភូមិភាគទេ តើខ្ញុំយល់អ៊ីចឹងត្រឹមត្រូវដែរទេ ប្រសិនបើខ្ញុំនិយាយខុស លោកអាចកែខ្ញុំបាន?

**ឆ៖** បាទ ដូចខ្ញុំបានបញ្ជាក់ជូនលោកហើយ ពីខាងដើមថាអត់មានអង្ករនេះ ដឹកបញ្ជូនទៅភូមិភាគ ឬក៏តាមតំបន់វិញទេ មានតែក្រសួងមន្ទីរទេ ដែលទទួលអង្ករចេញពីឃ្លាំងដែលខ្ញុំគ្រប់គ្រង បាទ។

[១៣:៥០:៣០]

**ស៖** ឥឡូវនេះ ខ្ញុំចង់ពិភាក្សាបញ្ហាមួយទៀតជាមួយលោក គឺអ្វីដែលលោកបានផ្តល់សក្ខីកម្មនៅព្រឹកមិញនេះគឺលោកនិយាយអំពីដំណើរទស្សនកិច្ចរបស់អ្នកដឹកនាំមកឃ្លាំងរបស់លោក។ យើងនិយាយអំពីបុគ្គលម្នាក់ឈ្មោះ ឌឿន ហើយលោកបាននិយាយអំពី ឌឿន ហ្នឹងនៅក្នុងចម្លើយជាមួយមជ្ឈមណ្ឌលកម្ពុជា។ ខ្មែរ ERN មានលេខ 00008356, បារាំងមានលេខ 00899520 ដល់ 1 និងភាសាអង់គ្លេសមានលេខ 00710571, ហើយលោកនិយាយដូចតទៅនេះ “នៅពេលដែលមានមនុស្សដូចជា ឌឿន មកគាត់តែងតែហៅខ្ញុំទៅជួបគាត់ ហើយសួរអំពីបញ្ហាមួយចំនួននៅក្នុង -- ដែលបានដាក់ -- អីវ៉ាន់ដែលបានដាក់នៅក្នុងឃ្លាំង”។ តើខ្ញុំនិយាយអ៊ីចឹងត្រឹមត្រូវដែរឬទេ ដែលថានៅពេលដែល ឌឿន មកម្តងៗគាត់តែងតែហៅលោកទៅជួបគាត់ដើម្បីសួរអំពីឃ្លាំងដាក់អីវ៉ាន់ប៉ុន្មាន អីប៉ុន្មាននុ៎ង។ តើជាការពិតដែរឬទេ?

[១៣:៥១:៥១]

**ឆ៖** សូមជម្រាបលោកដែរថា ខ្ញុំមិនបានចាំអស់ត្រង់ចំណុចមួយ គឺថាពេលដែលគេមកពិនិត្យមើលឃ្លាំងហ្នឹង ខ្ញុំអត់បានចាំទេ តែគ្រាន់តែពេលដែលគេចេញទៅវិញបានគេប្រាប់ថា ឈ្មោះនេះៗ។ គ្រាន់តែខ្ញុំជម្រាបជូនលោកប្រធានប៉ុណ្ណឹង។

**ស៖** ខ្ញុំចង់សួរលោកបញ្ជាក់បន្តិច តើលោកចាំដែរឬទេថា បុគ្គលម្នាក់ឈ្មោះ ឌឿន ហ្នឹង ធ្លាប់សួរលោក ហើយសួរលោកអំពីអីវ៉ាន់ដែលដាក់នៅក្នុងឃ្លាំង តើ ឌឿនហ្នឹងគាត់ធ្លាប់សួរលោក និយាយជាមួយលោកអំពីបញ្ហាហ្នឹងទេ?

**ឆ៖** ខ្ញុំសូមជម្រាបលោកដែរថា មានសួរ ប៉ុន្តែគ្រាន់តែខ្ញុំជម្រាបជូនខាងដើមអ៊ីចឹងថា ខ្ញុំអត់ចាំខ្ញុំមានការភ្លេចភ្លាំងខ្លះ ក៏ប៉ុន្តែមានសួរ ប៉ុន្តែដល់លោករំឭកអ៊ីចឹងទៅឃើញថាប្រហែលជាមានមែនណេះ ហើយបើតាមការនឹកឃើញរបស់ខ្ញុំគឺ ឌឿនហ្នឹងគាត់ហាក់ដូចជាខូចជើងម្ខាងផង នេះបើតាមខ្ញុំចាំបាទ។

[១៣:៥៣:២០]

**ស៖** សូមអរគុណ ហើយលោកក៏បាននិយាយអំពីការដែល ឌឿន ហ្នឹងគាត់ខូចជើងម្ខាងហ្នឹងនៅក្នុងចម្លើយរបស់លោកដែរ។ ឥឡូវយើងមើលពីរសន្លឹក ពីរទំព័រចុះទៅក្រោមទៀត នៅក្នុងចម្លើយរបស់លោក។ លោកបាននិយាយអំពីដំណើរទស្សនកិច្ចរបស់ ខៀវ សំផន។ ហើយលោកនិយាយថា ខៀវ សំផន មកពិនិត្យមើលការងារនៅឃ្លាំង។ តើ ខៀវ សំផន គាត់មកមើលឃ្លាំងហ្នឹង -- *អូខេ* ឥឡូវ

ខ្ញុំសួរអ៊ីចេះវិញ។ តើ ខៀវ សំផន ហ្នឹងមកមើលឃ្លាំងរបៀបណាដែរ គាត់មកម្នាក់ឯង ឬមួយក៏មានអ្នកដទៃមកអមជាមួយដែរ?

**ឆ៖** សូមជម្រាបលោកថា ខ្ញុំអត់បានចាំបានទេ ប៉ុន្តែគ្រាន់តែខ្ញុំសូមបញ្ជាក់ថា គាត់មានមកពិនិត្យមើលឃ្លាំងមែនបាទ។ ហើយកន្លងមកថែមទាំងអាចសម្គាល់ឃើញគាត់ គាត់មិនសូវមានឡានឬក៏អ្វីដែលជាយានជំនិះគាត់ហ្នឹងគឺទំនើបល្អដូចគេទេ។ គាត់តែងតែជិះនូវឡាំប៉ាតាធុនល្មមៗប៉ុណ្ណឹងទេ ហើយគាត់តែងតែពាក់ស្បែកជើងផ្ទាត់ ហ្នឹងមក ពេលដែលមកពិនិត្យឃ្លាំងកន្លែងខ្ញុំនៅហ្នឹង។

**ស៖** សូមអរគុណលោក។ ហើយនៅក្នុងចម្លើយដដែលក៏លោកក៏លោកនិយាយថា នួន ជា ក៏បានមកមើលឃ្លាំងហ្នឹងដែរ។ ដូច្នេះ ខ្ញុំចង់ដឹងថា តើ នួន ជា មកមើលឃ្លាំងហ្នឹងជាមួយ ខៀវ សំផន ឬមួយក៏ នួន ជា គាត់មកផ្សេង, មកដាច់ផ្សេងពី ខៀវ សំផន?

**ឆ៖** ខ្ញុំសូមជម្រាបដែលថា ខ្ញុំចាំបាន គឺថាដែលមកជុំទេ។ ក្រែងលោពេលណាដែលគាត់មកជុំគ្នា ខ្ញុំអត់ដឹង អាហ្នឹងក្រែង -- ពីព្រោះការងារខ្ញុំចេញទៅធ្វើការ ទៅដឹកសម្ភារៈតាមរោងចក្រអីទៅក៏ជួនពេលខ្លះអត់ជួប អត់ដឹងក៏មានដែរលោក។

[១៣:៥៥:២៧]

**ស៖** តើ ខៀវ សំផន មកកន្លែងហ្នឹង តើមកញឹកញាប់ប៉ុនណាដែរ?

**ឆ៖** គាត់អត់សូវមកញឹកញាប់ទេបាទ។

**ស៖** តើលោកដឹងទេមានអីកើតឡើងចំពោះ ឌឿន?

**ឆ៖** ខ្ញុំអត់ដឹងអ្វីដែលកើតមានចំពោះ ឌឿន ទេបាទ។

**ស៖** សូមអរគុណលោក។ ខ្ញុំចង់ឲ្យលោកបញ្ជាក់ទៅលើចំណុចមួយទាក់ទងទៅនឹងរចនាសម្ព័ន្ធរបស់ឃ្លាំងរដ្ឋ។ នៅព្រឹកមិញហ្នឹង លោកបាននិយាយអំពីបុគ្គលម្នាក់ឈ្មោះៗ រឿង ដែលជាប្រធានឃ្លាំងរដ្ឋនោះ។ នៅក្នុងចម្លើយរបស់លោក ទៅលើចម្លើយដែលបានផ្តល់នោះ គឺលោកបាននិយាយអំពីបុគ្គលម្នាក់ឈ្មោះ រិទ្ធ -- មិនមែនមនុស្សម្នាក់ជាមួយ វ៉ាន់ រិទ្ធ ទេ ប៉ុន្តែជាមនុស្សផ្សេងមួយទៀត។

[១៣:៥៧:០២]

ហើយយើងឃើញចម្លើយរបស់លោកនៅខ្មែរមានលេខ 00008343, បារាំងមានលេខ 00899 508, និងភាសាអង់គ្លេសមានលេខ 00710560។ ហើយលោកបានឆ្លើយដូចតទៅនេះ "ប្រធានឈ្មោះ រិទ្ធ ផ្នែកមួយទៀតគឺ អនុគឺ តេង។ គឺនៅជ្រោងចង្វា និងឫស្សីកែវ"។ ហើយព្រឹកមិញលោកនិយាយថា

គណៈហ្នឹងគឺមាន ឌឿន, រិទ្ធ, ហើយនិង តេង។ មាន រឿង, តេង ហើយនិង ជន។ តើអាចដែរឬទេថា រិទ្ធ ហើយនិង រឿង ហ្នឹងគឺជាមនុស្សតែមួយ គ្រាន់តែថាអាចនិយាយឈ្មោះទៅវាច្រឡំធ្វើឲ្យដូរទៅជា រឿង និង រិទ្ធ ហ្នឹង។ តើ រិទ្ធ និង រឿង ហ្នឹងមនុស្សតែមួយឬក៏ផ្សេងគ្នា?

**ឆ៖** សូមជម្រាបលោកថាឈ្មោះ រឿង នេះ ពីដើមឡើយគាត់ឈ្មោះ រិទ្ធ។ ដល់ដែលលោក វ៉ាន់ រិទ្ធ ក៏ឈ្មោះ រិទ្ធ, លោក រឿង ក៏ឈ្មោះ រិទ្ធ។ ដល់ក្រោយមកទៀត គាត់ផ្លាស់ឈ្មោះមកជា រឿង វិញ បាទ។

[១៣:៥៨:៤០]

**ស៖** សូមអរគុណដែលលោកបានបញ្ជាក់។ ការបញ្ជាក់របស់លោកនេះ គឺជួយយើងបានច្រើន។ ហើយនៅក្នុងចម្លើយរបស់លោកដដែលហ្នឹង គឺលោកបាននិយាយអំពីបុគ្គលទាំងអស់នេះ ហើយគឺ និយាយពី វ៉ាន់ រិទ្ធ។ ខ្មែរ ERN មានលេខ 00008338, បារាំងមានលេខ 00899503 ដល់ 04, និង ភាសាអង់គ្លេសមានលេខ 0071056។ ហើយលោកបានឆ្លើយដូចតទៅនេះ គេសួរលោកថា "តើ វ៉ាន់ រិទ្ធ ជាប្រធានរបស់ខាង -- មួយទៀត ហើយ រិត ហ្នឹងគឺជាប្រធានរដ្ឋមែនទេ?" ហើយលោកនិយាយថា "ប្រសិនបើនិយាយអំពីតួនាទី រិត មួយនេះគឺមានតួនាទីទៀបជាង គឺទាបជាង រិទ្ធ មួយទៀត។ តាំងពី យើងមិនទាន់បែកភ្នំពេញ នៅក្រោមការគ្រប់គ្រងរបស់ រិទ្ធ នេះ"។ តើខ្ញុំយល់ត្រឹមត្រូវដែរឬទេ ដែលថា រិទ្ធ ដែលគណៈឃ្លាំងរដ្ឋ ហើយនិងបុគ្គលិកដទៃទៀតហ្នឹងគឺស្ថិតនៅក្រោមការគ្រប់គ្រងរបស់ វ៉ាន់ រិទ្ធ?

**ឆ៖** សូមជម្រាបលោកថា លោក រិទ្ធ ដែលក្រោយមកនៅបែរឈ្មោះមក រឿង វិញនេះ កាលពី ដើមឡើយមិនទាន់រៀបអង្គភាពហ្នឹងចូលមកទីក្រុងភ្នំពេញ លោក វ៉ាន់ រិទ្ធ ហ្នឹងគាត់ឈ្មោះ វ៉ាន់ រិទ្ធ ហ្នឹងហើយ តែលោក រឿង ក៏ឈ្មោះ រិទ្ធ ដែរ។ ក្រោយពីចូលមកដល់ភ្នំពេញគាត់ត្រូវបានប្តូរឈ្មោះពី រិទ្ធ ហ្នឹងមក រឿង។ ឯលោក វ៉ាន់ រិទ្ធ គឺនៅតែលោក វ៉ាន់ រិទ្ធ ដដែលបាទ។

[១៤:០០:៥៨]

**ស៖** តើ វ៉ាន់ រិទ្ធ ហ្នឹងជាមេរបស់ រឿង នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ តើមែនទេ?

**ឆ៖** ក្រោយពីចូលមកនៅភ្នំពេញមក គឺលោក រឿង ត្រូវដាច់ស្រឡះពីលោក វ៉ាន់ រិទ្ធ ហើយ ពីព្រោះលោក វ៉ាន់ រិទ្ធ គាត់ខាងពាណិជ្ជកម្ម លោក រឿង គាត់នៅឃ្លាំងបាទ។

**ស៖** សូមអរគុណ។ ឥឡូវនេះ យើងខ្ញុំសួរសំណួរចុងក្រោយទាក់ទងទៅនឹងផ្នែកនេះ។ ខ្មែរមាន លេខ 0000833, បារាំងមានលេខ 00899499 និងភាសាអង់គ្លេសមានលេខ 00710552។ គេសួរ

លោកដូចតទៅនេះ "តើអ៊ីចឹងមានន័យថា ខាងពាណិជ្ជកម្ម ហើយនិងខាងឃ្លាំងរដ្ឋស្ថិតនៅក្នុងឋានានុក្រមស្មើគ្នា ប៉ុន្តែផ្នែកផ្សេងគ្នាមែនទេ?" លោកឆ្លើយថា "ទាំងពីរហ្នឹងដាច់ពីគ្នា ឃ្លាំងរដ្ឋវាតូច បើនិយាយពីឋានៈវា វាតូចជាងពាណិជ្ជកម្មទេ"។ តើវាត្រឹមត្រូវដែរទេ បើយើងនិយាយពីឋានៈហ្នឹងគឺឋានៈរបស់ឃ្លាំងរដ្ឋវាទាប គឺទាបជាងពាណិជ្ជកម្ម?

[១៤:០២:៥០]

**ឆ៖** បាទ អ៊ីចឹងមែនបាទ ត្រឹមត្រូវ។

**ស៖** សូមអរគុណ។ យើងបាននិយាយគ្នាបន្តិចហើយអំពីបញ្ហាពាក់ព័ន្ធនឹងការឃាត់ខ្លួន ការចាប់ខ្លួន ឬក៏បទបញ្ជាដែលគេឲ្យធ្វើទាក់ទងទៅនឹងការចាប់ខ្លួននេះ។ ដូច្នេះ ខ្ញុំចង់សួរលោកបន្ថែមបន្តិច សូមឲ្យមានការពន្យល់ពីលោកបន្តិចអំពីបទបញ្ជាឲ្យចាប់ខ្លួននេះ។ ខ្ញុំអាចសូមសួរដំបូងបំផុត គឺថាតើការបាត់ខ្លួនអ្នកមួយចំនួនហ្នឹង តើវាមានការចាប់ខ្លួនអ្នកទាំងគ្នាទុំង ឬយ៉ាងដូចម្ដេច? ឬក៏ថាតើមានការចាប់ខ្លួនអ្នកណាម្នាក់ដែលធ្វើការនៅឃ្លាំងរដ្ឋហ្នឹងទេកាលពីលោកនៅទីនោះ?

**ឆ៖** សូមជម្រាបជូនលោកថា បញ្ហាចាប់ខ្លួននេះកន្លងមកឃើញថា មានជាហូរហែៗ។ ប៉ុន្តែគ្រាន់តែថាការចាប់ខ្លួននេះមិនមានឃើញចាប់វាយដំធ្វើបាបអីទេ គ្រាន់តែគេថាមានការហៅប្រជុំណែនាំហើយ បានប្រាប់ថាផ្លាស់ទៅកន្លែងថ្មី។ ហ្នឹងចំពោះកន្លែងអង្គភាពដែលខ្ញុំរស់នៅ គឺមានឃើញអ៊ីចឹង។ ហើយចំពោះមុខទៀត អ្នកដែលចាប់ខ្លួនទៅហ្នឹង ខ្លះក៏ឃើញនៅ ខ្លះក៏បាត់ខ្លួន តែមិនដឹងបាត់ហ្នឹងតាមរបៀបណា។ សូមជម្រាបប៉ុណ្ណឹង។

[១៤:០៥:០៧]

**ស៖** ឥឡូវខ្ញុំចង់សូមអានកន្លែងនេះសម្រាប់លោក។ អាហ្នឹងលេខខ្មែរ 00008289, បារាំង 00899457 ទៅដល់ 458, អង់គ្លេស 00710518។ តើលោកអាច -- ពេលនោះ គឺលោកនិយាយអំពីស្ថានភាពពាក់ព័ន្ធទៅនឹងការចាប់ខ្លួននេះ។ លោកបានលើកឡើងដូចខាងលើនេះ "ថាគ្មាននរណាម្នាក់ដឹងទេ ថាតើវេនរបស់គេមកដល់ពេលណាទេ ដែលត្រូវគេចាប់ខ្លួន ឃាត់ខ្លួននោះ។ ដូច្នេះគាត់ព្យាយាមធ្វើអ្វីឲ្យតែអាចខ្លួនឯងធ្វើបានដើម្បីចៀសវាងការចាប់ខ្លួនបែបនោះ"។ ហើយនៅខាងក្រោមមកទៀត លោកបានបន្ថែមថា "នៅក្នុងអំឡុងពេលនោះបន្ទាប់ពីបុគ្គលណាមួយត្រូវបានគេចាប់ខ្លួន ខ្ញុំគិតថាអ្នកទាំងអស់នោះត្រូវបានគេយកទៅធ្វើផ្លូវ។ ប៉ុន្តែក្រោយមក ខ្ញុំដឹងថាប្រសិនបើនរណាម្នាក់មួយត្រូវបានគេចោទដាក់ហើយដោយអ្នកដែលគេចាប់ខ្លួនកាលពីមុនហ្នឹង អ៊ីចឹងបុគ្គលហ្នឹងត្រូវបានគេចោទថាជាអ្នកជាជនក្បត់

ហើយក្រោយមកត្រូវគេយកទៅសម្លាប់"។ តើហ្នឹងគឺជាចម្លើយដែលលោកបានឆ្លើយទាក់ទងទៅនឹងការយល់ដឹងរបស់លោកចំពោះជនមួយចំនួនដែលត្រូវបានគេចាប់ខ្លួនដោយសារតែមានអ្នកគេឆ្លើយដាក់គាត់ហើយបន្ទាប់មកអ្នកនោះត្រូវបាត់ខ្លួន?

[១៤:០៦:៣១]

**ឆៈ** រាល់ចំណុចទាំងអស់ខាងលើដែលលោកបានសួរខ្ញុំនេះ គឺបញ្ហានេះវាជារឿងពិតៗ។ បញ្ហាចាប់ខ្លួនបងប្អូនកន្លែងមកហ្នឹង គឺមានអ៊ីចឹងមែន។ បើកាលណាចម្លើយអ្នកដែលចាប់ទៅមុនហ្នឹង បើតាមខ្ញុំពិចារណា ហើយវិភាគ ហើយតាមការយល់ដឹង បើតែឆ្លើយពីរបីនាក់ត្រូវគ្នាហ្នឹង គឺច្បាស់ជាគេមកចាប់ហើយ ទោះបីបុគ្គលហ្នឹងគ្មានកំហុសអីក៏ដោយ ឲ្យតែមានចម្លើយមកពីរបីនាក់ត្រូវគ្នាហ្នឹង គឺត្រូវតែគេដកចេញ។ ហើយពេលដែលគេចាប់ទៅហ្នឹងទៀត ដូចខ្ញុំបានជម្រាបជូនខាងលើអ៊ីចឹងថា កាលដែលចាប់នេះ គឺគេមិនដែលមកចាប់ប្រទូសប្រទាំងគ្នាអីទេ។ គ្រាន់តែគេហៅទៅប្រជុំហើយ គេថាផ្លាស់កន្លែងអីអ៊ីចឹងទៅ ក្រោយមកទៀតក៏ចេញទៅៗ។ នេះគ្រាន់តែឃើញការចាប់ហ្នឹង ឃើញមានអ៊ីចឹង។

**សៈ** តើលោកបានឃើញអ្នកដែលគេដកចេញហ្នឹង គេចាប់ខ្លួនយកទៅហ្នឹងដោយផ្ទាល់ភ្នែកទេឬក៏ ហើយតើលោកធ្លាប់បានគេសួរឲ្យបញ្ជូនមនុស្សហ្នឹងទៅឲ្យសន្តិសុខចំពោះអ្នកណាដែលគេត្រូវឃាត់ខ្លួនហ្នឹង តើគេធ្លាប់មានបានប្រាប់លោក ឲ្យលោកបញ្ជូនខ្លួនបុគ្គលហ្នឹងទៅឲ្យសន្តិសុខដែលមកចាប់ខ្លួនអ្នកទាំងអស់ហ្នឹងទេ?

[១៤:០៨:០៤]

**ឆៈ** សូមជម្រាបលោកដែរថា បើគេមានផែនការចង់ចាប់អ្នកណាមួយហើយ គេអត់ដែលប្រាប់ទេ។ គ្រប់កន្លែងទាំងអស់ គឺគេអត់ប្រាប់ទេ បើដល់ពេលថា "ហ! ត្រូវទៅ" គេចាប់ខ្លួនហើយគេហៅទៅប្រជុំ ហើយបើមិនអ៊ីចឹងទេ ក្រោយពីប្រជុំហើយហ្នឹងទៅ គឺគេឲ្យរៀបចំខោអាវ អីវ៉ាន់ផ្លាស់កន្លែងទៅនៅកន្លែងថ្មីអ៊ីចឹងទៅ។ ដល់ផុតពីហ្នឹងមក គឺលែងឃើញបុគ្គលហ្នឹងនៅកន្លែងអង្គភាពហ្នឹងរហូតបាទ។

**សៈ** ឥឡូវខ្ញុំសូមអានន្ទូវកថាខណ្ឌខាងក្រោមនេះជូនលោក ផ្នែកមួយនៃបទសម្ភាសន៍របស់លោកនៅខាងក្រោមនេះ។ ខ្មែរERN 00008342, ភាសាបារាំង 0089507, អង់គ្លេស 00710559។ លោកបានឆ្លើយថា ដូចខាងក្រោម៖ "ប្រសិនបើគេចង់ចាប់ខ្លួននរណាម្នាក់ គេនឹងមក ហើយនិងប្រាប់ខ្ញុំតាមទូរស័ព្ទ ប្រាប់ខ្ញុំថា ពួកគេចង់ចាប់កម្មាភិបាល ឬក៏សមមិត្តមួយនេះ និងមួយនេះ។ ហើយខ្ញុំបានហៅ

អ្នកហ្នឹងមកពីកន្លែងធ្វើការរបស់គាត់ដើម្បីឲ្យជួបជាមួយនឹងពួកគេ”។ សូមទោស នៅខាង ERN មួយផ្សេងទៀត នៅទំព័រហ្នឹង អំពីប្រធានបទដូចគ្នាហ្នឹង។ ខ្មែរ 00008349, បារាំង 00899513, ហើយនិងអង់គ្លេស 00710565។ លោកលើកឡើងថា “នៅពេលដែលសន្តិសុខជាតិមកចាប់ខ្លួនអ្នកណាម្នាក់ ពួកគេមានឈ្មោះបុគ្គលដែលជាមុខសញ្ញារបស់ពួកគេហ្នឹងហើយ។ ហើយមុនពេលដែលពួកគេមក គេទូរស័ព្ទមកប្រាប់យើងថា គេចង់មក ហើយនិងធ្វើការជាមួយនឹងយើងនៅថ្ងៃណាមួយ ហើយនិងនៅម៉ោងណាមួយជាក់លាក់ហ្នឹង”។ អ៊ីចឹង តើវាជាការត្រឹមត្រូវទេលោក?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! សូមអញ្ជើញលោកមេធាវីអន្តរជាតិការពារក្តីឲ្យលោក នួន ជា?

[១៤:១០:៤០]

**លោក វ៉ិចទ័រ កូប៉េ៖**

សូមទោសលោកប្រធាន ប្រហែលជាសហសេវិករបស់យើង គួរអាចត្រូវការពន្យល់។ ថាតើអ្វីដែលគាត់សួរនោះ វាស្ថិតនៅក្នុងវិសាលភាពនៃសវនាការ ដែលយើងកំពុងដំណើរការឬទេ?

**លោក អាប់ឌុលឡាក់ ចារីក៖**

យើងទទួលបាននូវការជំទាស់ច្រើនដងហើយ ពីខាងមេធាវី ហើយយើងមិនដែលបានតវ៉ាទេចំពោះបញ្ហាជំទាស់នេះ។ ប៉ុន្តែការពិតចំពោះករណីនេះ យើងឃើញហើយថា យើងបានសួរពាក់ព័ន្ធទៅនឹងការិយាល័យ ហើយនិងក្រសួងនានារបស់របបកម្ពុជាប្រជាធិបតេយ្យ។ ដូច្នេះ យើងចង់សួរអំពីទិដ្ឋភាពជាច្រើន ជាពិសេសអំពីការងារពាក់ព័ន្ធជាមួយនឹងឃ្លាំងរដ្ឋ ការងារពាក់ព័ន្ធទៅនឹងការបែងចែកគ្រឿងឧបភោគបរិភោគ ហើយគឺជាទិដ្ឋភាពមួយដែលពាក់ព័ន្ធទៅនឹងប្រតិបត្តិការរបស់រដ្ឋាភិបាលនេះ ដែលខ្ញុំគិតថាអ្វីដែលខាងមេធាវីលើកឡើង គឺមិនជាការសមស្របទេ ពីព្រោះអ្វីដែលខ្ញុំសួរ គឺខ្ញុំចង់ដឹងអំពីដំណើរការជាទូទៅ ហើយតើគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជានៅក្នុងក្រសួង និងស្ថាប័ននីមួយៗពេលនោះ វាដំណើរការយ៉ាងដូចម្តេច?

[១៤:១១:៥២]

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:១២:២៥]

**ប្រធានអង្គជំនុំ៖**

បាទ សេចក្តីជំទាស់របស់មេធាវីការពារក្តីមិនមានប្រសិទ្ធភាព។ សាក្សីត្រូវឆ្លើយតបទៅនឹងសំណួរដែលសួរដោយតំណាងសហព្រះរាជអាជ្ញាអម្បាញ់មិញនេះ ប្រសិនបើលោកនៅចាំនូវសំណួរ។

**លោក រស់ ស៊ុយ៖**

**ឆ៖** សូមឲ្យលោកតាំងសំណួរម្តងទៀត បាទ។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** ខ្ញុំសំណួររបស់ខ្ញុំ គឺថាតើវាជាការពិតទេ ដូចដែលលោកបានលើកឡើងនៅក្នុងចម្លើយរបស់លោកថា៖ អង្គភាពសន្តិសុខជាតិហ្នឹង គាត់ពាក់ព័ន្ធ -- ទាក់ទងមកលោកនៅកន្លែងឃ្លាំងរដ្ឋហ្នឹង ដើម្បីប្រាប់លោកថាពួកគេនឹងចុះមក ដើម្បីអនុវត្តនូវការឃាត់ខ្លួនទៅលើជនណាមួយនៅទីនោះ។ ហើយនៅពេលដែលពួកគេមកដល់ លោកនឹងជួយពួកគេហ្នឹង នៅក្នុងការបញ្ជូនមនុស្សហ្នឹង គឺលោកហៅមនុស្សហ្នឹងមក ហើយអង្គភាពខាងសន្តិសុខជាតិហ្នឹង នឹងយកអ្នកនោះទៅ។ តើជាការពិតឬទេ?

[១៤:១៣:៣៦]

**ឆ៖** ជាការពិតបាទ។

**ស៖** សូមអរគុណ។ ឥឡូវ ខ្ញុំចង់សួរពាក់ព័ន្ធទៅនឹងឃ្លាខ្លីមួយទៀត ពីអ្វីដែលខ្ញុំបានអាន ប៉ុន្តែខាងក្រោមចុងក្រោយបំផុត។ ខ្ញុំសូមដកស្រង់ “ពួកគេបានប្រាប់យើងឲ្យហៅសមមិត្តមួយនេះ ឬក៏សមមិត្តមួយនោះ មកឲ្យពួកគេ។ អ៊ីចឹង គឺគេអាចធ្វើការជាមួយនឹងអ្នកទាំងអស់ហ្នឹង។ នៅពេលដែលគេហៅអ្នកហ្នឹងមកចូលប្រជុំ បានន័យថា គេហៅមកឃាត់ និងចាប់ខ្លួនទាំងអស់គ្នាហ្នឹងហើយ”។ ដូច្នេះសំណួររបស់ខ្ញុំសម្រាប់លោក “ថាតើអ្នកទាំងអស់គ្នាហ្នឹងដឹងទេ ថាពួកគេត្រូវឃាត់ខ្លួន? ហើយលោកឆ្លើយថា “ពួកគេដឹង នៅពេលណាបុគ្គលមួយត្រូវបានគេហៅពីកន្លែងធ្វើការមក សម្រាប់មកចូលរួមការប្រជុំអីមួយអ៊ីចឹង គឺគេដឹងហើយ ថាគេត្រូវមក ត្រូវបានគេចាប់ខ្លួនហើយ”។ នៅខាងក្រោមមកទៀត “ពួកគេដឹងថា ពួកគេនឹងត្រូវគេឃាត់ខ្លួន ចាប់ខ្លួន ប៉ុន្តែពួកគាត់អត់ដឹងថា ពួកគេនឹងត្រូវគេសម្លាប់ចោលឬអត់ទេ ប៉ុន្តែគេដឹងថា ប្រសិនបើគេហៅមកពីកន្លែងធ្វើការ មកប្រជុំហ្នឹង គឺគេប្រាកដជាហៅមកចាប់ខ្លួនហើយ”។

អ៊ីចឹងបើតាមអានចម្លើយរបស់លោកនេះ ថាតើបានន័យថា នៅក្នុងកន្លែងការងាររបស់លោកហ្នឹងលោកដឹងហើយ គេទាំងអស់គ្នាគេដឹងហើយ ថាសិនបើជាអ្នកណាម្នាក់ត្រូវបានគេហៅមកចូល

ប្រជុំ គឺគេដឹងថាប្រាកដជាមានការចាប់ខ្លួនហើយ។ ថាតើមានវាបរិយាកាសភ័យខ្លាចអ៊ីចឹង នៅកន្លែងធ្វើការ នៅកន្លែងឃ្លាំងរដ្ឋនោះអ៊ីចឹងដែរឬទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកមេធាវី!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំនៅតែទទូចដដែលចំពោះបញ្ហានេះ ពីព្រោះខ្ញុំការសួរអំពីបរិយាកាសអីនៅកន្លែងធ្វើការ វាដូចជាអត់ពាក់ព័ន្ធជាមួយនឹងរឿងទំនាក់ទំនងកន្លែងការងារសោះ។

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធាន ខ្ញុំដឹងថាយើងអត់សូវមានពេល ឥឡូវខ្ញុំសូមបន្តសំណួររបស់ខ្ញុំទៅទៀតចុះ ដោយសារខ្ញុំចង់សន្សំពេលវេលា។ ខ្ញុំដឹងថាយើងនៅមានបញ្ហាជាច្រើនទៀតដែលខ្ញុំចង់សួរ ឥឡូវខ្ញុំសូមហួសទៅសំណួរមុខតែម្តង។

[១៤:១៥:៥១]

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** ខ្មែរ 00008352, បារាំង 00089956, ភាសាអង់គ្លេស 00710567។ សំណួរ៖ "នៅពេលដែលខាងអង្គភាពសន្តិសុខហ្នឹងសួរលោកអំពីថា គេត្រូវការបុគ្គលនេះ ឬបុគ្គលនោះ ថាតើគេដែលបដិសេធទៅនឹងសសំណើរបស់ខាងអង្គភាពហ្នឹងទេ?" ចម្លើយថា "អត់ទេ ដោយសារតែនេះគឺជាបញ្ជាពីខាងថ្នាក់លើគឺគេចាំបាច់ត្រូវតែអនុវត្តតាម ហើយយើងគ្រាន់តែជាអ្នកធ្វើការនៅក្នុងឃ្លាំងរដ្ឋតូចតាចមួយតែប៉ុណ្ណោះ យើងមិនអាចមិនធ្វើតាមបញ្ជាទេ"។ សំណួរថា "តើអ្នកណាគេធ្វើទៅតាមបទបញ្ជាទាក់ទងទៅនឹងការចាប់ខ្លួននេះ?" ចម្លើយ "គឺយើងធ្វើទៅតាមរយៈអង្គភាពសន្តិសុខជាតិ"។ អ៊ីចឹងថាតើការយល់របស់លោកនៅពេលនោះ អង្គភាពសន្តិសុខជាតិហ្នឹង គឺគាត់មកធ្វើការឃាត់ខ្លួនហ្នឹងទៅតាមបញ្ជាពីថ្នាក់លើ។ តើជាការត្រឹមត្រូវទេ?

[១៤:១៧:០២]

**ឆ៖** រឿងបញ្ហាខាងសន្តិសុខមកនេះ ដូចលោកតាំងសំណួរសួរខ្ញុំនេះ នេះគឺជារឿងត្រឹមត្រូវមែនបាទ។

**ស៖** អ៊ីចឹងថាតើលោកដឹងថា តើនរណាគេជាថ្នាក់លើហ្នឹងទេ ដែលចេញបទបញ្ជាឲ្យខាងសន្តិសុខជាតិហ្នឹងមកចាប់ខ្លួនហ្នឹងលោកមានដឹងទេ?

**ឆ៖** ខ្ញុំសូមជម្រាបលោកបន្ថែមរាល់បញ្ហាសំណួរ ដែលលោកសួរទាំងប៉ុន្មានអម្បាញ់មិញនេះឃើញថា ក្រោយពីមានបញ្ហាហ្នឹងមួយកើតឡើងគឺឥតមានខ្ញុំដឹងមុនលោក រឿង ហ្នឹងទេ។ លោក រឿង បញ្ហាមកតែតាមទូរស័ព្ទ ឬក៏ទូរស័ព្ទលើតុមកថា "ឲ្យមកហៅបុគ្គលនេះ បុគ្គលនោះទៅប្រជុំកន្លែងនេះ កន្លែងនោះ"។ ខ្ញុំមានតួនាទីត្រឹមថាទៅប្រាប់បុគ្គលនេះ បុគ្គលនោះដែលគេដាក់បញ្ហាមកឲ្យប្រាប់ទៅប្រជុំកន្លែងនេះ កន្លែងនោះហ្នឹង ខ្ញុំទៅប្រាប់ហើយតួនាទីខ្ញុំចប់ត្រឹមហ្នឹង តែត្រង់ដឹងថា គេចាប់ ឬក៏គេអីយ៉ាងម៉េច គឺខ្ញុំអត់ដឹងទេ។ តែក្រោយពីហៅទៅប្រជុំហ្នឹងហើយបាត់ឈ្មោះហ្នឹងទៅរហូតបាទ។

[១៤:១៨:២៣]

**ស៖** សូមអរគុណ។ ខ្ញុំចង់បន្តទៅប្រធានបទថ្មីមួយទៀត ហើយខ្ញុំនឹងព្យាយាមធ្វើម៉េចសួរលោកឲ្យខ្លីៗដើម្បីងាយយល់។ ព្រឹកមិញនេះនៅពេលដែលលោកត្រូវបានសួរដោយសហសេវិករបស់ខ្ញុំដែលខាងមេធាវីការពារក្តីនោះ លោកបានលើកឡើងអំពីព្រឹត្តិការណ៍មួយចំនួនទាក់ទងទៅនឹងការសិក្សាកម្មវិធីសិក្សា ហើយនៅពេលនោះគឺគេបានបង្ហាញអំពីការសារភាពរបស់ កុយ ធួន តាមរយៈការចាក់ខ្សែអាត់។ បើតាមសហសេវិករបស់ខ្ញុំ ដែលគាត់បានអានផ្នែកមួយនៃសម្ភាសរបស់លោកជាមួយនឹងការិយាល័យសហចៅក្រមស៊ើបអង្កេតហ្នឹង លោកបាននិយាយថា "លោក ខៀវ សំផន អត់មានវត្តមាននៅទីនោះទេ នៅពេលដែលគេចាក់ខ្សែអាត់ហ្នឹង" ប៉ុន្តែលោកក៏បានថាពិភាក្សាលើកឡើងអំពីព្រឹត្តិការណ៍ហ្នឹង ពីរដងជាមួយនឹងអ្នកស្រាវជ្រាវនៃការិយាល័យនេះ។

លើកទី១ គឺនៅក្នុងឆ្នាំ២០០៣ ប្រហែលជា៥ឆ្នាំ១ មុនពេលដែលខាងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតទៅសម្ភាសរបស់លោក។ ហើយនៅពេលនោះលោកបានរៀបរាប់ព្រឹត្តិ-ការណ៍ដូចក្នុងនោះ គឺឯកសារលេខខ្មែរ 0089 (*ស៊ីក*), ភាសាអង់គ្លេស 00--, ភាសាបារាំង 00899468, ភាសាអង់គ្លេស 00710405 ទៅដល់ 07, ឯកសារ IS19.158។ អ៊ីចឹងខ្ញុំសូមលើកឡើង៖

[១៤:២០:០២]

"សំណួរ៖ នៅពេលនោះ ថាតើគេមានចោទប្រកាន់ កុយ ធួន ជាភ្នាក់ងារ ឬក៏ជាក្រុមណាមួយក្បត់ទេ? ចម្លើយ៖ គេបានលើកឡើងអំពី កុយ ធួន ប៉ុន្តែពេល កុយ -- ខៀវ សំផន ហៅខ្ញុំមកចូលវគ្គខ្ញុំសិក្សា គេបានចាក់ខ្សែអាត់ពីការសារភាពរបស់ កុយ ធួន នេះ។ សំណួរ៖ តើគាត់ចាក់ខ្សែអាត់នោះ

ឱ្យលោកស្តាប់ទេ? ចម្លើយ៖ គាត់ចាក់ខ្សែអាត់ការសារភាពរបស់ កុយ ធួន នេះ”។ តើលោកយល់ស្រប ជាមួយខ្ញុំទេ ថានៅក្នុងចម្លើយរបស់លោកដែលឆ្លើយនៅក្នុងឆ្នាំ២០០៣ហ្នឹង លោកបានពិពណ៌នាថា លោក ខៀវ សំផន មិនមែនត្រឹមតែមានវត្តមាន ប៉ុន្តែគាត់ថែមទាំងអ្នកដែលចាក់ខ្សែអាត់សំឡេងសារ-ភាពរបស់លោក កុយ ធួន ទៀតផង?

**ផ៖** សូមអភ័យទោសបញ្ហា--

[១៤:២១:០៤]

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយតបលោកសាក្សី! សូមអញ្ជើញលោកមេធាវីជាតិការពារក្តីលោក ខៀវ សំផន!

**លោក គង់ សំអុន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមឱ្យតំណាងសហព្រះរាជអាជ្ញា ពិនិត្យទៅលើអត្ថបទជាភាសាខ្មែរ ហើយនៅពេលនោះ គឺការបកស្រាយរបស់សាក្សីមិនបាននិយាយទៅលើថាលោក ខៀវ សំផន ជាអ្នកចាក់អ៊ីចឹងទេ។ វាជាការនិយាយបែបច្រឡំ។ បាទ សូមឱ្យជួយពិនិត្យ។ សូមអរគុណ។

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធាន ការពិតខ្ញុំមានឯកសារនេះនៅក្នុងដៃរបស់ខ្ញុំ ហើយខ្ញុំរីករាយនឹងប្រគល់ជូនឯក-សារនេះទៅសាក្សី បើសិនជាគាត់ចង់បាន។ ប៉ុន្តែខ្ញុំអានអំពីឯកសារនេះពីការបកប្រែផ្លូវការ ហើយពាក្យនេះក៏ខ្ញុំអានចេញពីឯកសារបកប្រែនេះផងដែរ។ បើសិនជាលោកប្រធានអនុញ្ញាត ហើយសាក្សីគាត់ចង់មើល។ ខ្ញុំអាចជូនឯកសារនេះជូនទៅគាត់ គាត់អាចអានមើលជាភាសារបស់គាត់ ឬក៏បើមិនអ៊ីចឹងទេ សហសេវិករបស់ខ្ញុំអាចនៅផ្នែកដែលពាក់ព័ន្ធនេះ។ វាអាស្រ័យទៅលើលោកប្រធាន ថាតើចង់ឱ្យយើងខ្ញុំធ្វើយ៉ាងដូចម្តេចបាទ។

[១៤:២២:២១]

**ប្រធានអង្គជំនុំ៖**

លោកបង្ហាញអត្តសញ្ញាណឯកសារនេះ សាជាថ្មីម្តងទៀត!

**លោក អាប់ឌុលឡាក់ ថារីក៖**

អរគុណលោកប្រធាន គឺនេះគឺជាការសម្ភាសមួយដែលសាក្សី គាត់បានផ្តល់បទសម្ភាសន៍ទៅដល់អ្នកស្រាវជ្រាវនៅមជ្ឈមណ្ឌលឯកសារកម្ពុជា។ ឯកសារ IS19.158 ឯកសារសម្ភាសពីឆ្នាំ២០០៣

និងឆ្នាំ២០០៤។ ហើយខ្ញុំអម្បាញ់មិញនេះ ខ្ញុំបានអានផ្នែកដែលពាក់ព័ន្ធនៅទីនេះ ខ្ញុំអាចបញ្ជូនឯកសារនេះទៅសាក្សី បើសិនជាសាក្សីគាត់យល់ថា គាត់ចង់មើលឯកសារនេះដោយផ្ទាល់។

[១៤:២៣:០១]

**ប្រធានអង្គជំនុំ៖**

ឯកសារនេះទំនងជាសាក្សីបានឃើញទេ ព្រោះកាលពីលើកឡើងកាលពីព្រឹកហើយ ក្រុមមេធាវីការពារក្ដីលោក ខៀវ សំផន បានលើកឡើងបញ្ហាដូចគ្នា។ អង្គជំនុំជម្រះមិនអនុញ្ញាតទេ ដោយច្បាស់លាស់ហើយថា អ្នកស្រាវជ្រាវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានត្រឹមតែធ្វើសម្ភាស ហើយអាត់សំឡេងប៉ុណ្ណោះ។ ហើយចំណែកឯកសារនេះ ក្រុមការងារគឺយកទៅស្ដាប់ និងអាត់សំឡេង ហើយសរសេររៀបរាងដោយខ្លួនឯង។ មានអត្ថន័យថា សាក្សីរូបនេះមិនបានស្គាល់ មិនដែលស្គាល់ទាល់តែសោះឯកសារនេះ។ សាក្សីដែលមិនស្គាល់ឯកសារ ឯកសារដែលសាក្សីមិនស្គាល់មិនអាចបង្ហាញសាក្សីឲ្យសាក្សីឆ្លើយតបបានទេ។ តែអាចដកស្រង់នូវខ្លឹមសារទូទៅនៃឯកសារនោះ ដើម្បីសួរដេញដោលបាន។ នេះជាការណែនាំរួមដែលយើងអនុវត្តជាយូរ ហើយជាញឹកញាប់មកហើយ។

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធាន ជាការពិតខ្ញុំចង់ធ្វើការបន្តទៅមុខទៀត។ ខ្ញុំចង់ឲ្យសហសេវិកខ្មែររបស់ខ្ញុំ គាត់អានផ្នែកនេះជាភាសាខ្មែរតែម្ដង ហើយឲ្យគេបកប្រែទៅជាភាសាអង់គ្លេសផ្ទាល់ពីអ្នកបកប្រែមក ដើម្បីយើងធ្វើការផ្ទៀងផ្ទាត់មើល ថាតើវាខុស ឬក៏ត្រូវ។ ហើយបើសិនជាយើងអាចធ្វើអ៊ីចឹងបាន យើងនឹងខ្ញុំនឹងចាប់ផ្ដើមធ្វើការបន្តសាកសួរពីនេះតទៅទៀត។ សូមអរគុណ។

[១៤:២៤:២៤]

**ប្រធានអង្គជំនុំ៖**

អញ្ជើញ!

**លោក វ៉េង ហ៊ត់៖**

អរគុណលោកប្រធាន។

"សី អាហ្នឹងវាបើតាមខ្ញុំវិភាគ ហើយខ្ញុំយល់វិញ ថា អឿន ហ្នឹងគាត់នៅក្រោម កុយ ធួន។ សុជា៖ កុយ ធួន ហ្នឹងហើយកាលហ្នឹងគេចោទថា កុយ ធួន ហ្នឹងគាត់ជាភ្នាក់ងារ ជាខ្សែអីនៅក្នុងហ្នឹងអ៊ីចឹង? ស៊ុយ ឆ្លើយ៖ កុយ ធួន ហ្នឹងគេមានឯកសារអីមកចាក់ថ តខ្សែចាក់អាត់ចម្លើយសារភាព

ដែលលោក ខៀវ សំផន ហៅពួកខ្ញុំទៅរៀន។ សុជា សួរ៖ ហើយគេចាក់ឲ្យស្ដាប់? ស៊ុយ ឆ្លើយ៖ គេចាក់ឲ្យស្ដាប់ចម្លើយសារភាព។ សុជា សួរ៖ ឆ្លើយថាម៉េចទៅ? ស៊ុយ ឆ្លើយ៖ ខ្ញុំមិនអាចចាំអត់ទេ ប៉ុន្តែខ្ញុំដឹងត្រង់ថាគោលការណ៍ប្រុងធ្វើរដ្ឋប្រហារ ប៉ុល ពត ច្រើនលើកមកហើយ តែធ្វើមិនបានសម្រេច"។ អរគុណលោកប្រធាន។

[១៤:២៦:១៦]

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវី!

**លោក គង់ សំអុន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមលោកប្រធានអនុញ្ញាតមេត្តាឲ្យតំណាងសហព្រះរាជអាជ្ញាសួរបញ្ជាក់ ពីព្រោះនៅក្នុងភាសាខ្មែរនេះប្រើថា "គេចាក់" ព្រោះគេនេះវាអត់ច្បាស់ទេ មិនដឹងជាអ្នកណាទេ ហើយការដែលមករៀនវាមានទាំង នួន ជា វាទាំងលោក ខៀវ សំផន ដែលបានហៅសាក្សីមករៀន។ អ៊ីចឹងសូមឲ្យជួយបញ្ជាក់ត្រង់ពាក្យ "គេ" នេះផងបាទ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ លោកតំណាងសហព្រះរាជអាជ្ញាសូមបញ្ជាក់សាជាថ្មីម្ដងទៀត ពីព្រោះជាភាសាខ្មែរមិនមានអត្ថន័យថា លោក ខៀវ សំផន ចាក់ឲ្យស្ដាប់ទេ។ នៅក្នុងពាក្យហ្នឹងគឺប្រើ "គេ" គឺមិនមានបញ្ជាក់ថា "គេ" ហ្នឹងតំណាងឲ្យបុគ្គលណាមួយច្បាស់លាស់ទេ។ ពាក្យដែលនៅក្នុងឃ្លាអម្បាញ់មិញនេះគឺមានពាក់ព័ន្ធតែ ខៀវ សំផន ហៅពួកខ្ញុំទៅរៀន។ បានន័យថាគ្រាន់តែជាអ្នកកោះហៅក្រុមគាត់ទៅរៀនប៉ុណ្ណោះ ហើយអ្នកចាក់គឺអ្នកផ្សេងទេ មិនមែន អ៎! ប្រើពាក្យ "គេ" មិនដឹងថាបុគ្គលណាមួយទេ។ មិនមានអត្ថន័យថា "គេ" ហ្នឹងគឺជា ខៀវ សំផន ទេ។ នេះជាភាសាខ្មែរ។

[១៤:២៧:៣១]

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន ខ្ញុំនឹងបន្តដោយផ្អែកទៅលើចំណុចនេះ។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** អ៊ីចឹងទី១ លោកសាក្សី លោកយល់ស្របទេដែលនៅក្នុងចម្លើយហ្នឹងដែលថាខ្សែអាត់របស់ កុយ ធួន ការសារភាពរបស់ កុយ ធួន ហ្នឹងត្រូវបានគេចាក់ ហើយនៅពេលនោះគឺមានលោក ខៀវ

សំផន នៅទីនោះដែរ?

**លោក រស់ ស៊ុយ៖**

**ឆ៖** ខ្ញុំសូមបញ្ជាក់ឡើងវិញ ពីព្រោះបញ្ហាអ្វីដែលខ្ញុំបាននិយាយ មិនត្រឹមប៉ុណ្ណឹង ក៏ខ្ញុំបានទាំងស្បថថែមទៀត។ បញ្ហាដែលខ្ញុំនិយាយថា "គេចាក់" តែបើខ្ញុំចាំមិនភ្លេចទេក្រែងលោកគឺថា ការសរសេរស្តាប់មិនបានពីខ្ញុំយ៉ាងម៉េចមិនដឹងទេ តែគ្រាន់តែខ្ញុំច្បាស់ថា "គេចាក់ឲ្យស្តាប់" ពេលដល់គេសួរបកចុះបកឡើងទៅ ខ្ញុំគ្រាន់តែប្រើពាក្យថា "គេចាក់" តែបើខ្ញុំចាំច្បាស់ថាលោក នួន ជា ចាក់ទេបាទ។

[១៤:២៨:៣៤]

**ស៖** សូមអរគុណ។ អ៊ីចឹងតើជាការត្រឹមត្រូវទេ ដែលលោកនិយាយនៅក្នុងចម្លើយរបស់លោកហ្នឹងនៅក្នុងឆ្នាំ២០០៣ ដែលថាលោក ខៀវ សំផន មានវត្តមាននៅទីនោះដែរនៅពេលដែលគេចាក់ខ្សែអាត់នោះ?

**ឆ៖** ខ្ញុំសូមជម្រាបលោកថា ក្រែងស្តាប់គ្នាមិនបាន ខ្ញុំថាឥតមានទេ តែដល់ឃើញនិយាយអ៊ីចឹងវិញ ខ្ញុំដូចឆ្ងល់ដែរថា ខ្ញុំបានបញ្ជាក់ហើយថា ពេលដែលចាក់ខ្សែអាត់ហ្នឹងអត់មានវត្តមានលោក ខៀវ សំផន ទេ។ ក្រែងពាក្យនេះស្តាប់គ្នាអត់បាន វាទៅជាមានទៅវិញបាទ។

**ស៖** ឥឡូវបើយើងក្រឡេកមើលការសម្ភាសមួយទៀត ដែលលោកបានផ្តល់ដែរ។ ជាថ្មីម្តងទៀតជាមួយនឹងមជ្ឈមណ្ឌលឯកសារកម្ពុជា ឥឡូវហ្នឹងខ្មែរ ERN 00189502, ខ្មែរ 00008337, អង់គ្លេស 00071555។ សំណួរ លោកសួរអំពីការប្រជុំជាមួយគ្នាហ្នឹង គឺពេលនោះលោកធ្វើក្នុងឆ្នាំ ២០០៤ បទសម្ភាសន៍នេះ។ "តើលោកខៀវ សំផន ហៅមកប្រជុំមែនទេ? ចម្លើយ គឺបាទ លោក ខៀវ សំផន បានហៅមក"។ ឥឡូវខ្ញុំសូមសួរលោកបន្ថែមទៀត លោកក៏បានបញ្ជាក់ថាគេបានចាក់ខ្សែអាត់របស់លោក កុយ ធួន ប៉ុន្តែលោកមានការច្រឡំមិនដឹងថាតើពីណាគេជាអ្នកចាក់កាសែតហ្នឹងទេ? ថាតើជាលោក ខៀវ សំផន ឬក៏លោក នួន ជា លោកមិនចាំច្បាស់ទេ។ តើលោកមានចាំថាលោកបានឆ្លើយអ៊ីចឹងទេ ជាមួយនឹងអ្នកស្រាវជ្រាវហ្នឹងទាក់ទងទៅនឹងការចាក់ខ្សែអាត់សារភាពរបស់ កុយ ធួនហ្នឹង?

[១៤:៣០:៣៦]

**ឆ៖** បាទ ខ្ញុំបានឆ្លើយអ៊ីចឹងមែន។ ក៏ប៉ុន្តែក្រោយមកទៀត ខ្ញុំនឹកឃើញការចងចាំរបស់ខ្ញុំវិញថា ពេលដែលចាក់ហ្នឹងមានតែលោក នួន ជា ទេដែលចាក់។ លោកខៀវ សំផន អត់មានចាក់ជាមួយខ្ញុំទេ។

**ស៖** សូមអរគុណ ឥឡូវលោកបានឆ្លើយច្បាស់ហើយ។ សូមអរគុណលោកសាក្សី។ ខ្ញុំមាន

សំណួរពីរបីចុងក្រោយមុនពេលដែលខ្ញុំបញ្ចប់ការសាកសួរទៅលើលោក ស៊ុយ។ នៅព្រឹកនេះលោកបាននិយាយថា លោកមិនគិតថាលោក ខៀវ សំផន គឺជាមេដឹកនាំជាន់ខ្ពស់នោះទេ ហើយសហការីរបស់ខ្ញុំបានអាននូវចម្លើយរបស់សាក្សីមួយផ្សេងទៀត។ ដូច្នេះខ្ញុំចង់ដឹងថា តើលោកដឹងដែរឬទេថានៅក្នុងពេលនេះគឺនៅក្នុងទីនេះ គឺលោកខៀវ សំផន បាននិយាយថាគាត់គឺជាសមាជិករបស់គណៈមជ្ឈិម។ តើលោកដឹងដែរឬទេ?

[១៤:៣២:១០]

**ឆ៖** សូមជម្រាបលោកសហព្រះរាជអាជ្ញា បញ្ហាទាំងអស់នេះ ខ្ញុំសូមជម្រាបលោកដែលថា ចំណុចមួយដែលខ្ញុំចង់បញ្ជាក់នៅពេលនេះថាជាការយល់ឃើញរបស់ខ្ញុំថាលោក ខៀវ សំផន គាត់ជាគណៈកម្មការអចិន្ត្រៃយ៍ ឬក៏មិនមែនក្តី ខ្ញុំក្តាប់អត់បានទេ។ តែខ្ញុំមិនអាចយល់ដល់ហ្នឹងទេ ក៏ប៉ុន្តែគ្រាន់តែដឹងថា ក្នុងឋានៈគាត់ ក្រោយពីខ្ញុំដឹងថាគាត់ជាប្រធានគណៈប្រធានរដ្ឋ អាហ្នឹងខ្ញុំដឹងច្បាស់។ ក៏ប៉ុន្តែការយល់ឃើញរបស់ខ្ញុំសូមបញ្ជាក់ឲ្យច្បាស់ថា ប្រធានគណៈប្រធានរដ្ឋ គឺការសម្រេចធំជាងគេ នៅលើបក្ស។ តែក្រោយពីបក្សសម្រេចហើយ គឺតាមខ្ញុំធ្លាប់សម្គាល់ហើយ ហើយក៏ខ្ញុំមិនមែនជាអ្នកកាន់ជើងគាត់ទេ។ តែខ្ញុំនិយាយការពិត។ ពេលដែលគាត់ហៅខាងរដ្ឋបាលទៅប្រជុំ ទៅរៀនសូត្រ គាត់មិនដែលនិយាយពីបញ្ហាអី ក្រៅពីការណែនាំឲ្យថែទាំសម្ភារៈរបស់របរទេ។ ហើយការសម្រេចធ្វើអីមួយក៏ខ្ញុំមិនដែលឃើញថា គាត់មកសម្រេចថាឲ្យធ្វើឃ្លាំងអីចេះ ធ្វើឃ្លាំងអីចុះ ឬក៏សម្រេចធ្វើនេះ ធ្វើនោះទេ។ នេះការពិតខ្ញុំសូមជម្រាបជូនប៉ុណ្ណឹង។

[១៤:៣៣:៣៧]

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោក ស៊ុយ។ ដោយសារតែពេលវេលាមានកំណត់ ខ្ញុំសូមបញ្ចប់ត្រឹមណេះ។ សូមអរគុណលោកដែលផ្តល់ចម្លើយចំពោះខ្ញុំ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ បាទ សូមអញ្ជើញលោកស្រីមេធាវីអន្តរជាតិការពារក្តីលោក ខៀវ សំផន!

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ខ្ញុំសូមកែតម្រូវមួយ។ អម្បាញ់មិញហ្នឹង ខ្ញុំឮថារបៀបចោទសំណួររបស់សហព្រះរាជអាជ្ញាអំមិញនេះគឺថា ព្រឹកមិញនោះ ខ្ញុំចង់ហៅសាក្សីផ្សេងមួយទៀត។ ខ្ញុំដកស្រង់ដែលសាក្សី

មួយទៀត។ តាមពិតទៅ ព្រឹកមិញនោះ គឺថាខ្ញុំដកស្រង់សក្ខីកម្មរបស់សាក្សីនៅចំពោះមុខយើងនេះឯង ព្រោះថាឮការបកប្រែព្រឹកមិញនោះ ថាខ្ញុំដកស្រង់នូវចម្លើយរបស់សាក្សីមួយទៀត។ តាមពិតមិនមែនទេ គឺសាក្សីនៅក្នុងសាលសវនាការយើងនេះឯង។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ!

[១៤:៣៤:៤៧]

**លោក អាប់ឌុលឡាក់ ថាវីក៖**

ដូច្នេះដើម្បីឲ្យកំណត់ត្រាច្បាស់លាស់ ហើយប្រាកដ គឺថាមេធាវីការពារជាតិលោក ខៀវ សំផន បានអានចេញពីចម្លើយរបស់សាក្សី។ ដូច្នេះខ្ញុំចង់បញ្ជាក់ឲ្យបានច្បាស់នៅក្នុងកំណត់ត្រា។

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក២០នាទីចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបីខ្វះប្រាំនាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។ មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សីនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យនាំគាត់មកចូលមកកាន់បន្ទប់សវនាការកន្លែងផ្តល់សក្ខីកម្មនេះវិញ នៅវេលាម៉ោងបីខ្វះប្រាំនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៣៥ នាទី ដល់ម៉ោង ១៤:៥៨ នាទី)*

[១៤:៥៧:៥១]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្តល់វេទិកាជូនទៅក្រុមសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។ សូមអញ្ជើញ!

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

សូមអរគុណលោកប្រធាន។ ខ្ញុំចាប់ផ្ដើមមុន ហើយសហភាតាខ្ញុំបន្ត។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី**

**សួរដោយលោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

**ស៖** ជម្រាបសួរលោកសាក្សី! សូមអរគុណដែលឆ្លើយនឹងសំណួររបស់យើងដោយអត់ធ្មត់។ ខ្ញុំសន្មតថា មិនជាការងាយស្រួលនោះទេ ចំពោះលោកក្នុងការរំឭកព្រឹត្តិការណ៍ដែលកើតមានឡើងនៅអតីតកាល។ ខ្ញុំនឹងចាប់ផ្ដើមនូវសំណួរបន្តចំនួនធៀបទៅនឹងអ្វីដែលបាននិយាយកាលព្រឹកមិញ ហើយនិងពេលរសៀលនេះ។ ហើយបន្ទាប់មកទៀត ខ្ញុំនឹងនិយាយអំពីលក្ខខណ្ឌការងារនៅក្នុងរចនាសម្ព័ន្ធដែលលោកធ្វើការនៅទីនោះ។

[១៤:៥៨:៥៥]

ជាបឋម ខ្ញុំសូមត្រឡប់មកនិយាយអំពីអ្វីដែលលោកបានលើកឡើងកាលពីព្រឹកមិញ គឺថាមុនរយៈពេលឆ្នាំ៧៣។ លោកបាននិយាយអំពីអង្គភាពរបស់លោក ហើយលោកបាននិយាយផងដែរថាមានគេ -- មានលោកសង្ឃដែលផ្សឹក ហើយនិងយកមកអប់រំ ដោយពុំមានការបង្ខំអ្វីទេ។ អ៊ីចឹងខ្ញុំចង់ដឹងថាតើលោកជាអ្នកអប់រំព្រះសង្ឃដែលត្រូវបានផ្សឹកទាំងអស់នោះ ឬក៏អ្នកណាផ្សេងទៀត?

**លោក រស់ ស៊ុយ៖**

**ឆ៖** បាទ សូមជម្រាបជូនលោក ពាក់ព័ន្ធបញ្ហាលោកសង្ឃដែលត្រូវបានផ្សឹក ហើយបញ្ជូនទៅធ្វើកងទ័ពនេះ គឺសូមជម្រាបលោកឲ្យបានជ្រាបថា បញ្ហាលោកសង្ឃ ឬក៏មិនលោកសង្ឃនោះ គឺខ្ញុំអត់បានដឹងទេ តែគ្រាន់តែដឹងថា ពេលដែលគេប្រមូល ឬក៏គេជ្រើសរើសតាមភូមិ តាមឃុំមកហើយ គឺគេបញ្ជូនមកដល់កន្លែងខ្ញុំហ្នឹង គឺ ហើយក៏មិនមែនជាកន្លែងមួយសម្រាប់អប់រំធំដុំ ឬក៏អីទេ។ គ្រាន់តែជាកន្លែងមួយ គេហៅថា កន្លែងសុំចតបណ្ដោះអាសន្ន។ ទម្រាំតែការរៀបចំរបស់ថ្នាក់លើៗហ្នឹង គេត្រូវតម្រូវថា អ្ហ៎! ទៅ បញ្ជូនទៅអង្គភាព កងទ័ព កងពលនេះប៉ុនណេះ កងពលនោះប៉ុណ្ណឹងទេ។ ចំណែកបញ្ហាលោកសង្ឃ ឬក៏យុវជនណាដែលស្ម័គ្រចិត្តចូលមកកន្លែងហ្នឹង គឺខ្ញុំអត់បានដឹងថា មកដោយសារអ្វីទេ។ គ្រាន់តែដឹងថា មកតាមរយៈហ្នឹង ឃើញទើបតែដុះសក់ហ្នឹង ខ្ញុំសន្និដ្ឋានថា លោកសង្ឃហ្នឹងដែលទើបផ្សឹកហ្នឹងទៅ។

[១៥:០១:០៤]

**សៈ** សូមអរគុណលោកសាក្សី។ ឥឡូវនេះ ខ្ញុំសូមចោទសំណួរមួយទៀត ទាក់ទងទៅនឹងឃ្លាំង របស់លោក ឃ្លាំងដែលលោកជាអ្នកគ្រប់គ្រង។ ម្សិលមិញ សាក្សីបាននិយាយថា "នៅស្រុកស្រែមាន មីក្រូដែលផ្សព្វផ្សាយព័ត៌មានរបស់បក្ស ដែលនិយាយអំពីការតស៊ូប្រឆាំងនឹងខ្មាំង ហើយនិងការលើក ទឹកចិត្តដល់ប្រជាជនជាដើម"។ តើនៅឃ្លាំងរបស់លោកនោះ មានមីក្រូដែរឬទេ នៅកន្លែងដែលលោក ស្រស់ស្រូបអាហារ និងកន្លែងលោកសម្រាកជាដើមនោះ មានមីក្រូចាក់ផ្សាយអីទេ?

**ឆៈ** ខ្ញុំសូមជម្រាបលោកវិញថា នៅកន្លែងសហករណ៍ហូបបាយហ្នឹង គឺមានគេចាក់មីក្រូ ជាចម្រៀង ជាអីទៅ ហើយនៅកន្លែងការងារហ្នឹង គឺមានចាក់ចម្រៀងឲ្យអ្នកធ្វើការនៅក្នុងហ្នឹងស្ដាប់ ហើយនិងមានពេលខ្លះ មានអត្ថាធិប្បាយ និយាយពីបញ្ហាកសាងជាតិ មានចាក់ចំរៀងអម។ អាហ្នឹង គឺមានរាល់ថ្ងៃតែម្ដង បាទ។

**សៈ** ក៏ប៉ុន្តែនៅឃ្លាំងរបស់លោកនោះ តើមានមីក្រូដែរឬទេ? ឬក៏មានមីក្រូនៅក្បែរកន្លែងដែល លោកសម្រាកដែរឬទេ?

**ឆៈ** មីក្រូមាន បាទ មាននៅប្រចាំការនៅនឹងកន្លែងហ្នឹងតែម្ដង។

[១៥:០២:៥៩]

**សៈ** សូមអរគុណ។ ទាក់ទងទៅនឹងឃ្លាំងលោកដដែលនោះ តើលោកត្រូវរក្សារបាយការណ៍ ទូលេខឯកសារ ឬក៏លិខិតឧទ្ទេសនាមផ្សេងៗទេ លោកមានបានរក្សាឯកសារទាំងអស់នេះ នៅកន្លែង ណាមួយទេ?

**ឆៈ** សូមជម្រាបលោក បញ្ហាឯកសារទាំងអស់ ក្រោយពីបែកថ្ងៃ០៧ មករា ហ្នឹងមក គឺ ឯកសារ សូម្បីតែសោឃ្លាំង សូម្បីតែឯកសារអី គឺអត់បានរក្សាទុកទេ គឺនៅនឹងកន្លឹង។ ក្រោយពីថ្ងៃ០៧ មករា ហ្នឹង គឺត្រូវចេញទាំងអស់ អត់មានបានរក្សាឯកសារអ្វីទុកទេ បាទ។

**សៈ** សូមអរគុណ។ ឥឡូវនេះ ខ្ញុំសូមចូលទៅនិយាយទៅប្រធានបទមួយទៀត ហើយនិងខ្ញុំ ត្រឡប់មកនិយាយអំពីអ្វីដែលសហព្រះរាជអាជ្ញាបានសួរកាលពីព្រឹកមិញ ទាក់ទងទៅនឹងការបាត់ខ្លួន ដែលកើតមានឡើងនៅក្នុងឃ្លាំងទាំងពីរដែលលោកធ្វើការ។ ពីព្រោះថា លោកបាននិយាយអំពីការចាប់ ខ្លួននៅក្នុងឃ្លាំងទីមួយ ហើយលោកក៏បាននិយាយអំពីចាប់ខ្លួននៅក្នុងឃ្លាំងទីពីរផងដែរ។

[១៥:០៤:២៦]

លោកបានផ្ដល់ព័ត៌មានលម្អិតមួយចំនួនហើយ។ ឥឡូវនេះ ខ្ញុំសូមការបញ្ជាក់បំភ្លឺមួយ លោកជា

អ្នកទទួលខុសត្រូវនៅឃ្លាំងទាំងពីរនោះ។ តើក្នុងឋានៈលោកជាប្រធាន នៅពេលដែលគេមកចាប់មនុស្ស តើគេមានផ្តល់ឯកសារអីមួយទៅលោក ឬក៏ចម្លើយសារភាព ឬក៏ការឆ្លើយដាក់អីមួយទៅលោកទេ? ឯកសារឆ្លើយដាក់?

**ផ៖** ខ្ញុំសូមជម្រាបលោកថា ក្រោយពីគេចាប់នោះ មុនដំបូងខ្ញុំសូមជម្រាបអំពីតួនាទីខ្ញុំជាមុនសិន។ ដោយសារតែខ្ញុំមិនមែនជាប្រធាន ហើយគ្រាន់តែគេថាជាមេផ្នែកមួយសម្រាប់ចាត់តែងកម្លាំងធ្វើការនេះ ធ្វើការនោះ ត្រូវដាក់សម្ភារៈទៅខាងនេះ ដាក់សម្ភារៈទៅខាងនោះតែប៉ុណ្ណឹងទេ។ ឯចំណែកបញ្ហាគេផ្តល់ជាឯកសារ ឬក៏គេកំណត់ថាចាប់ហ្នឹង គឺខ្ញុំអត់បានទទួលទេ ឬក៏មានគេឆ្លើយដាក់អត់ទេ ក៏ប៉ុន្តែគ្រាន់ថា ដឹងថាមានគេចាប់នៅក្នុងអង្គភាពខ្ញុំហ្នឹងគឺមាន។ តែត្រង់ចំណុចមួយថាមានទោសពីរឿងអ្វីៗមួយ គឺខ្ញុំអត់បានដឹងទេ ដឹងគ្រាន់តែត្រឹមថាគេហៅឲ្យទៅប្រជុំទៅ គេថាផ្លាស់កន្លែងគឺបានដឹងត្រឹមតែប៉ុណ្ណឹងទេ។

**ស៖** ទោះបីជាលោកមានតំណែងយ៉ាងណាក៏ដោយគេមិនឲ្យ -- គេមិនពន្យល់អ្វីទៅលោកទាល់តែសោះ អ៊ីចឹងមែនទេ?

**ផ៖** បាទ ពិតប្រាកដអ៊ីចឹងមែន។

[១៥:០៦:៣១]

**ស៖** កាលពីព្រឹកមិញលោកក៏បាននិយាយផងដែរ ហើយនៅរសៀលនេះផងដែរ លោកបានឆ្លើយទៅសហព្រះរាជអាជ្ញាគឺថា "នៅពេលវគ្គរៀនសូត្រនោះ នួន ជា បានផ្តល់ជាដំបូន្មានឲ្យលោកស្វែងរកជនក្បត់" អានេះខ្ញុំស្តាប់ឮពីការបកប្រែជាភាសាបារាំង។ តើគាត់ប្រាប់លោកថា ជាកាតព្វកិច្ចក្នុងការរាយការណ៍អំពីខ្មាំងនេះ?

**ផ៖** សូមជម្រាបដែរថា បញ្ហាដែលខ្ញុំបានផ្តល់សក្ខីកម្មកាលពីព្រឹកនេះថា "ក្រោយពីមកពីការរៀនសូត្រវិញ គាត់ថាយើងត្រូវតែស្រាវជ្រាវរកជនបង្កប់" ក៏ប៉ុន្តែខ្ញុំសូមពិចារណាជម្រាបជូនលោកថា អ្នកដែលត្រូវចាប់នោះ ក្រោយពីមកពីរៀនសូត្រវិញសុទ្ធតែអ្នកនៅស្រុកជាមួយគ្នាហ្នឹងទាំងអស់ ហើយសព្វថ្ងៃនៅរស់ទៀត តែខ្ញុំអត់ឃើញថាសកម្មភាពអីយ៉ាងម៉េច ហើយខ្ញុំក៏មិនដឹងថាចាប់ហ្នឹងមកពីមូលហេតុអី ហើយក៏មិនដឹងជាជាប់ខ្សែខាងណាៗទេ គឺគ្រាន់តែបានជាការស្មាន ឬក៏ជាការសន្និដ្ឋានតែប៉ុណ្ណឹងទេ តែចាប់គឺពេលដែលឆ្នាំ៧៦ ក្រោយពីមកពីរៀនសូត្រវិញហ្នឹង គឺចាប់ទាំងដែលយុទ្ធជនដែលនៅជាមួយនឹងអង្គភាពខ្ញុំហ្នឹង គឺខ្លះ ហើយនៅតាមអង្គភាពក្រៅពីអ្នកគ្រប់គ្រងឃ្លាំងហ្នឹងខ្លះ សរុបទៅ

ប្រាំបីនាក់ ពេលចាប់មួយពេលហ្នឹង។ តែនេះនៅក្នុងឃ្លាំងកំពង់ទឹកកក។ ដល់តែទៅ ខ្ញុំទៅនៅឃ្លាំងគីឡូលេខ៦ គឺមានចាប់ម្នាក់ពីរនាក់ដែរ តែក្រៅពីនេះគេចាប់លាយជាមួយនឹងខាងកម្លាំងដែលត្រូវចេញចូលមកលីសែង មកលើកដាក់នេះ តែប៉ុណ្ណឹងទេ។ ហើយតែការចាប់ហ្នឹងគឺក៏ដូចខ្ញុំបានបញ្ជាក់ហើយបញ្ជាក់ទៀតថា អត់ដឹងថាជាខុសរឿងអី ជាប់ខ្សែអ្នកណា ធ្វើហើយក៏អត់ដឹងថា គេចាប់ហ្នឹងគឺខុសពីរឿងអីគឺអត់ដឹងទេ ដឹងត្រឹមថា គេជូនពេលខ្លះគេថា នែ! តេមកណេះឲ្យមិត្តនេះទៅប្រជុំកន្លែងនេះៗតែប៉ុណ្ណឹង។ តែក្រោយពីប្រជុំហើយគឺការសន្និដ្ឋានមួយថាប្រជុំហើយបាត់ៗ។ នេះសន្និដ្ឋានថាច្បាស់ជាមានទោសអីមួយដែលគេត្រូវចាប់ហើយ។ តែយើងគ្រាន់តែមិនអាចដឹងថាមានទោសអី មានកំហុសអី បាទ។

[១៥:០៩:១១]

**ស៖** សូមអរគុណលោកសាក្សី។ ឥឡូវនេះ ខ្ញុំសូមនិយាយអំពីសមាជិកក្រុមគ្រួសាររបស់លោកនៅពេលដែលសហចៅក្រមស៊ើបអង្កេតសួរចម្លើយលោកនៅក្នុងឯកសារ E3/469, ERN ជាភាសាបារាំងគឺ 00524390, អង់គ្លេសគឺ 00205113, ហើយជាភាសាខ្មែរគឺ 00172042 -- 52 (សូមទោស)។ លោកក៏បាននិយាយថា បងប្រុសថ្លៃរបស់លោកឈ្មោះ សាយ ត្រូវបានសម្លាប់ ហើយបងស្រីរបស់លោកហ្នឹងត្រូវបានសម្លាប់នៅគុកទួលស្លែង។ តើបងថ្លៃរបស់លោកនោះត្រូវបានចាប់ខ្លួននៅពេលណា? ហើយសម្លាប់នៅពេលណា?

**ឆ៖** បាទ សូមអរគុណចំណុចនេះ។ គឺជាការពិតណាស់ ក្រោយពេលដែលខ្ញុំធ្វើការសម្ភាសជាមួយនឹងមជ្ឈមណ្ឌលស្រាវជ្រាវឯកសារ ក៏គាត់បានអញ្ជើញខ្ញុំឲ្យមករៀនសូត្រវគ្គអំពីច្បាស់ខ្លះ ក្រោយពីសម្រាកនៅក្នុងមជ្ឈមណ្ឌលហ្នឹង ខ្ញុំក៏បើកឯកសារមើលទៅឃើញរូបថតបងខ្ញុំ។ ក្រោយពីឃើញទៅអត់មានឈ្មោះ។ បន្ទាប់មកទៀត ខ្ញុំសូមឲ្យខាងមជ្ឈមណ្ឌល គឺសូមឲ្យជួយស្រាវជ្រាវឲ្យខ្ញុំ។ ដល់ស្រាវជ្រាវទៅឃើញបងស្រីម្នាក់ តែខ្ញុំអត់បានចាំទេណា។ ឃើញទាំងបងស្រី ឃើញទាំងប្រុស ហើយនិងកូនពីរនាក់ទៀត គឺអត់ដឹង។ អត់ស្រាវជ្រាវរកអត់ឃើញ។ តែខ្ញុំគ្រាន់តែពេលនោះ ខ្ញុំនៅចាំ ថ្ងៃចាប់ចូលទៅ ថ្ងៃទីប៉ុណ្ណោះ ខែប៉ុណ្ណោះ ថ្ងៃកម្មេច ថ្ងៃប៉ុណ្ណោះ ខែប៉ុណ្ណោះ គ្រាន់តែមកដល់ពេលនេះ ខ្ញុំអត់ចាំ។ តែដឹងច្បាស់ថា ខ្ញុំស្រាវជ្រាវទៅឃើញថា មជ្ឈមណ្ឌលស្រាវជ្រាវឲ្យខ្ញុំ ឃើញថាសម្លាប់នៅនឹងគុកទួលស្លែងពិតប្រាកដមែន។ រហូតទៅដល់ខ្ញុំឲ្យគាត់ស្រាវជ្រាវបានទាំងរូបថត បានថ្ងៃកម្មេច ថ្ងៃអីទៅ តែខ្ញុំអត់ចាំ។ សព្វថ្ងៃ ខ្ញុំយករូបថតទៅរក្សាទុកនៅនឹងផ្ទះទាល់សព្វថ្ងៃបាទ។

[១៥:១១:៤៧]

**ស៖** ទាក់ទងទៅនឹងបងថ្លៃរបស់លោកនោះ តើលោកមានចាំថាគាត់ត្រូវបានសម្លាប់នេះមុនឆ្នាំ៧៥ ឬក៏ក្រោយឆ្នាំ៧៥?

**ឆ៖** ស្តាប់ពេលដែលគាត់ស្លាប់នេះ គឺត្រូវបានគេសម្លាប់នេះ គឺមិនមែនមុនឆ្នាំ៧៥ទេ ហើយក៏មិនមែនជាប់នឹងឆ្នាំ៧៥ដែរ ខ្ទង់ឆ្នាំ៧៧ ដែលគេសម្លាប់នោះ។

**ស៖** សូមអរគុណដែលបានឆ្លើយបញ្ជាក់បំភ្លឺនេះ។ លោកបានឆ្លើយប្រាប់សហចៅក្រមស៊ើបអង្កេតក្នុងឯកសារ E3/469, ERN ជាភាសាបារាំងគឺ 0052 -- អង់គ្លេស ជាភាសាអង់គ្លេសគឺថា 00205111, ជាភាសាខ្មែរគឺ 00172050។ លោកបាននិយាយថា គេបានដាក់ថ្នាំបំពុលនៅក្នុងអាហាររបស់លោក ហើយលោកក៏បាននិយាយថាផងដែរលោកបានសង្គ្រោះក្មេងៗ ដែលថាគេដាក់បំពុលអាហារក្មេងៗនេះដែរ។ តើលោកអាចនិយាយដោយសង្ខេបចំណុចនេះបានដែរឬទេ ថានេះជាបញ្ហាអីដែរទៅរឿងបំពុលអាហារ ចំណីអាហារនេះ?

[១៥:១៣:១៦]

**ឆ៖** ខ្ញុំសូមជម្រាបលោក នេះវាជារឿងពិត។ ក្រោយពីការផ្លាស់ប្តូរចាប់ខាងនេះ យកខាងនោះទៅគ្រប់គ្រង ជាចំណុចមួយៗធ្វើឱ្យអារម្មណ៍អ្នកដែលមានខ្សែមានរយៈហ្នឹង គឺមានការខឹងហើយ។ ដូច្នោះកាលដែលផ្លាស់ខ្ញុំទៅនៅគីឡូលេខ៦ហ្នឹង គឺត្រូវបានចាប់គេៗចេញពីកន្លែងហ្នឹង។ ហើយដល់ពេលខ្ញុំទៅ ក្រោយពីមិនទាន់ដឹងរឿង ម្ល៉ោះហើយបញ្ហាដែលត្រូវសងសឹកហ្នឹង គឺចៀសអត់ផុត។ បើអ៊ីចឹងទេ ទោះបីអ្នកនោះយ៉ាងណាក៏ដោយ អ្នកស្មោះត្រង់យ៉ាងម៉េច អ្នកអត់ដឹងរឿងយ៉ាងម៉េច ក៏ត្រូវតែគេប៉ានធ្វើដែរ។ ហើយការដែលធ្វើហ្នឹង គឺក៏អត់ដឹងថាខាងណាៗដែរ។ តែដល់គេស្រាវជ្រាវទៅឃើញថានៅតាមអង្គភាព។ អ៊ីចឹងទៅគេស្រាវជ្រាវទៅ គេចាប់។ ហើយអាហ្នឹង អាការពុលគឺប្រាកដមែន។ នៅកន្លែងមន្ទីរចាត់ការឃ្លាំងគីឡូលេខ៦ហ្នឹង គឺរាល់ថ្ងៃត្រូវបានអង្គភាពមួយៗគឺគេតែងយកចំណីយកម្ហូបអាហារទៅជូនមេធំៗខាងលើហ្នឹង។

តែដោយឡែកខ្ញុំអ្នកគ្រប់គ្រងអង្គភាពឃ្លាំងបន្ទាប់ពីមេធំៗហ្នឹងមក គឺខ្ញុំត្រូវមើលការខុសត្រូវខ្លះ។ ដល់អ៊ីចឹងទៅ ពេលដែលគេយកម្ហូបយកអីហ្នឹងមក ក្មេងដែលគាត់ហេវខ្លាំង ហេវទៅ គាត់ហូបមុនអីចឹង។ ដល់ហូបមុនទៅ ត្រូវពុល។ ដល់ត្រូវពុលទៅ ខ្ញុំដើម្បីដោះស្រាយជាបន្ទាន់ហ្នឹង ខ្ញុំទៅបេះដូង។ ដល់ទៅបេះដូងទៅ ត្រូវបានគេចោទប្រកាន់ថា ខ្ញុំបេះដូងសេរី។ ដល់គេគំរាម គេថាឱ្យខ្ញុំហ្នឹងថ្នាក់ដឹកនាំធំៗ មានលោក រឿង លោកអីហ្នឹង។ ដល់ហើយខ្ញុំថា "លោកពិចារណាទៅ ខ្ញុំបេះដូង

បើខ្ញុំបេះយកមកហូបលោកថាខ្ញុំសេរីចុះ តែខ្ញុំយកមកបន្សាបថ្នាំ បើលោកចាត់ទុកថាខ្ញុំក្បត់យ៉ាងម៉េច ស្រេចតែលោកវិនិច្ឆ័យចុះ"។ តែក្រោយមកទៀតអត់មានគេហៅខ្ញុំ ឬក៏គេឃាត់ខ្លួនខ្ញុំទេ គឺរឿងហ្នឹងត្រូវបញ្ចប់ត្រឹមហ្នឹង ត្រឹមក្មេងត្រូវយកទៅមន្ទីរពេទ្យទាន់បាទ។

[១៥:១៥:៣៦]

**ប្រធានអង្គជំនុំ៖**

លោកស្រីមេធាវីគប្បីកំណត់ឲ្យបានច្បាស់លាស់ សួរសាក្សី ឋានៈគាត់ជាសាក្សីមិនមែនជាដើមបណ្ដឹងរដ្ឋប្បវេណីទេ ហ្នឹងបញ្ហាទី១។ ហើយទី២ គិតគូរនូវការតាំងសំណួរដែលពាក់ព័ន្ធទៅនឹងអង្គហេតុដែលអង្គជំនុំជម្រះកំណត់ធ្វើសវនាការ ចៀសវាងចាកឆ្ងាយ ឬក៏មានការពាក់ព័ន្ធតិចតួចដែលមិនមានផលប្រយោជន៍ ឬតម្លៃក្នុងការស្វែងរកការពិតក្នុងរឿងក្ដីនេះទេ។

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

ខ្ញុំសល់សំណួរតែមួយទេលោកប្រធាន។ ខ្ញុំគ្រាន់តែសូមជម្រាបជូនតុលាការថា បើសិនជាមិនដឹងមិនយល់អំពីអារម្មណ៍អ្នកទទួលខុសត្រូវក្នុងកម្រិតណាមួយនោះទេ គឺថាយើងនឹងបាត់ព័ត៌មានបំភ្លឺពីពួកសំណាក់ពួកគាត់ហើយ។ អ៊ីចឹងខ្ញុំសូមចោទសំណួរចុងក្រោយ។

[១៥:១៦:៣៦]

**សួរដោយលោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

**ស៖** លោកបានឆ្លើយទៅសហចៅក្រមស៊ើបអង្កេត ជាចម្លើយចុងក្រោយរបស់លោកនៅក្នុងចម្លើយហ្នឹង លោកនិយាយថា "លោកភ័យខ្លាច ហើយលោកមិនដឹងថាពេលណាទេ លោកនឹងត្រូវបានគេចាប់ខ្លួននោះ"។ អ៊ីចឹងលោកនៅរក្សាចម្លើយលោកនេះទេ អង្កាល់ហ្នឹងលោកភ័យខ្លាច ហើយមិនដឹងថាគេចាប់ខ្លួនលោកពេលណាទេ?

**លោក រស់ ស៊ុយ៖**

**ឆ៖** បាទ ខ្ញុំសូមឯកភាពនឹងសំណួរលោកនេះហើយ ពីព្រោះវាជារឿងពិត ហើយវាជាការពិត គឺជំនាន់នោះឲ្យតែជាប់ខ្សែ គឺយុទ្ធជនគ្រប់រូបទាំងអស់ត្រូវតែមានការបារម្ភ ហើយភ័យហើយ តែគេចាប់ថ្នាក់មេៗរបស់ខ្លួន បងប្អូនរបស់ខ្លួនដែលជាប់មានសាច់សាលោហិតជាប់គ្នាហ្នឹងគឺច្បាស់ជាគេចាប់ដែរហើយ។ ម្ល៉ោះការដែលឃើញគេចាប់ហ្នឹង គឺតែងតែមានការព្រួយបារម្ភជាហូរហែ រហូតទៅដល់លាក់បងប្អូនមិនឲ្យអ្នកអង្គភាពជាមួយស្គាល់ជាបងប្អូនទៅទៀតនោះក៏មានដែរ នេះចំពោះរូបខ្ញុំ។ ទាល់

សព្វថ្ងៃ ទាល់តែបែកភ្នំពេញហើយបានដឹងថាជាមា ជាមីង ជាបង ជាប្អូនអីអ៊ីចឹងទៅ។ លាក់រហូតដល់ប៉ុណ្ណឹងទៀត។

[១៥:១៧:៥៥]

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

ខ្ញុំសូមអរគុណលោកច្រើនដែលបានឆ្លើយ ហើយខ្ញុំគិតថាសក្ខីកម្មរបស់លោកនេះចូលរួមវិភាគទានក្នុងការរកឃើញការពិត។ សូមអរគុណច្រើនលោកប្រធាន។

**លោក ពេជ អង្គ៖**

បាទលោកប្រធាន សូមគោរពលោកប្រធាន សូមអនុញ្ញាតបន្តសំណួរ។ បាទគោរពលោកប្រធាន លោក លោកស្រីចៅក្រម អង្គសវនាការទាំងមូល ដើមបណ្តឹងរដ្ឋប្បវេណី និងសាធារណជន។ សូមគោរពលោកសាក្សី ខ្ញុំបាទ ពេជ អង្គ ជាមេធាវីជាតិនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ខ្ញុំមានសំណួរមួយចំនួនសម្រាប់សូមសួរលោក ដើម្បីឲ្យលោកជួយបំភ្លឺបន្ថែម ដើម្បីជាប្រយោជន៍នៅក្នុងការរកការពិត។

[១៥:១៨:៤៦]

**សួរដោយលោក ពេជ អង្គ៖**

**ស៖** ជាបឋមពាក់ព័ន្ធទៅនឹងអំឡុងពេលឆ្នាំ១៩៧៥ តើលោកអាចបំភ្លឺបានទេថាតើទិដ្ឋភាពដែល ១៩៧៥ តើលោកមានបានឃើញទិដ្ឋភាពនៃការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញដែរឬទេ?

**លោក រស់ ស៊ុយ៖**

**ឆ៖** សូមជម្រាបលោកមេធាវីបញ្ហាជម្លៀសប្រជាពលរដ្ឋចេញពីក្រុងភ្នំពេញនេះ គឺខ្ញុំបានឃើញ តែអត់ដឹងថាមូលហេតុជម្លៀស ឬក៏ផែនការជម្លៀសយ៉ាងម៉េច ខ្ញុំអត់ដឹងទេ គ្រាន់តែបានឃើញដែលប្រជាពលរដ្ឋពពាក់ពពូនចេញពីក្រុងភ្នំពេញហ្នឹង គឺបានឃើញបាទ។

**ស៖** តើលោកអាចបញ្ជាក់បានទេ តើនៅ -- លោកបានឃើញហ្នឹង ឃើញនៅកន្លែងណាខ្លះ? តាមផ្លូវដែលចូលភ្នំពេញ ឬក៏នៅក្នុងទីក្រុងភ្នំពេញ?

**ឆ៖** សូមជម្រាបលោកមេធាវីថា ពេលដែលខ្ញុំឃើញនេះ គឺមិនមែនឃើញនៅទីក្រុងភ្នំពេញទេ ឃើញគាត់ទៅដល់ជនបទហើយ មុននឹងខ្ញុំចូលមកដល់ក្រុងភ្នំពេញហ្នឹងគឺខ្ញុំឃើញនៅឯជនបទនោះទេ ដែលគាត់ត្រូវបានគេជម្លៀសចេញទៅបាទ។

**សៈ** សូមលោកជួយបញ្ជាក់បន្ថែម ជនបទហ្នឹងគឺនៅខេត្តណា? ស្រុកណា? ហើយពេលណាដែលលោកអញ្ជើញចូលភ្នំពេញ? សូមលោកបញ្ជាក់ផង។

[១៥:២០:៣៥]

**ឆៈ** សូមអរគុណនឹងការសួរបញ្ជាក់។ ក្រោយពីគេជម្លៀសប្រជាពលរដ្ឋចេញទៅជនបទហ្នឹង គឺនៅពេលនោះខ្ញុំនៅស្ថិតនៅក្នុងខេត្តតាកែវនៅឡើយ។ ហើយគេជម្លៀសទៅ គឺឃើញគាត់ទៅដល់នោះហើយ។ ក្រោយពីគេជម្លៀសគាត់ចេញទៅ បានអង្គភាពខ្ញុំរៀបចំរំសាយនៅកន្លែងនោះ ហើយរៀបចំពូតផ្តុំជាអង្គភាព រៀបចំជាសមាសភាព កម្លាំងដើម្បីចូលមកនៅភ្នំពេញ គឺពេលដែលមកដល់ភ្នំពេញគឺអត់មានឃើញប្រជាពលរដ្ឋនៅក្នុងក្រុងភ្នំពេញទេ។

**សៈ** ខ្ញុំចង់សុំសួរបញ្ជាក់ថា ពេលដែលលោកផ្តុំគ្នា ហើយធ្វើដំណើរមកភ្នំពេញក្នុងអំឡុងពេលដែលលោកធ្វើដំណើរមកភ្នំពេញ លោកបានឃើញសកម្មភាពរបស់ប្រជាជនធ្វើដំណើរតាមដងផ្លូវមករហូត ៗដល់ពេលចេញដំណើររហូតមកដល់ភ្នំពេញតែម្តង ឬក៏យ៉ាងម៉េច?

**ឆៈ** ពេលដែលខ្ញុំចេញមកពីខាងខេត្តតាកែវ ស្រុកព្រៃកប្បាសហ្នឹង គឺទៅពេលដែលខ្ញុំចេញមកហ្នឹងគឺមកចាប់ផ្តើមដំបូងមកជួបជុំគ្នានៅតំបន់២៥ បានន័យថាជួរដងទន្លេបាសាក់។ នៅពេលនោះអត់ឃើញប្រជាពលរដ្ឋទេ ក្រោយពីរៀបចំកម្លាំងហើយ ក៏ពួកខ្ញុំគឺចេញដំណើរមកគឺអត់បានជួបប្រជាពលរដ្ឋទេ។ មកនៅកំពង់ទឹកកក ឃ្លាំងកំពង់ទឹកកក ខាងកើតផ្សារថ្មីនេះតែម្តងបាទ។

[១៥:២២:១០]

**សៈ** ខ្ញុំសូមឲ្យលោកបញ្ជាក់បន្តិច ខ្ញុំអត់បានឮមានប្រសាសន៍។ ថាតើលោកចេញមកភ្នំពេញនៅថ្ងៃណា ហើយមកដល់ភ្នំពេញថ្ងៃណា?

**ឆៈ** សូមជម្រាបលោកដែរថា ខ្ញុំអត់បានចាំកាលបរិច្ឆេទទេបាទ។ គ្រាន់តែដឹងថារៀបចំតាមស្តាប់តាមថ្នាក់ដឹកនាំខាងលើ ៗហ្នឹង គឺអត់បានយកចិត្តទុកដាក់កាលបរិច្ឆេទថាត្រូវមកថ្ងៃណា ៗ អត់បានចាំទេ។

**សៈ** តើលោកអាចនិយាយបានទេ ប្រជាជនដែលលោកឃើញគាត់អញ្ជើញទៅខេត្តតាកែវស្រុកព្រៃកប្បាសដែលលោកបានឃើញហ្នឹង ថាតើសភាពរបស់គាត់មានលក្ខណៈយ៉ាងម៉េចដែរ គាត់មានការរីករាយ ឬក៏តើគាត់មានជួបប្រទះនឹងការលំបាកអ្វីខ្លះដែរឬទេនៅក្នុងពេលដែលគាត់ធ្វើដំណើរទៅហ្នឹង?

**ឆ៖** សូមជម្រាបលោកមេធាវីថា ជាធម្មតាផ្ទះដែលនៅហើយ ដែលគេឲ្យចេញពីផ្ទះ គឺអត់ដែលសប្បាយចិត្តម្ដងណាទេ។ ខ្លះយំ ខ្លះដល់ថ្នាក់មែនទែន គឺយកអីវ៉ាន់ទៅអត់រួច ឡានខូច ឡានអស់សាំង ចងខ្សែអូស ក្រុមគ្រួសារជួយរុញទៀតក៏មានដែរ។ នេះចំពោះប្រជាពលរដ្ឋដែលចេញពីភ្នំពេញទៅ។ សូមលោកជ្រាប។

[១៥:២៣:៤៦]

**ស៖** បាទ តើមានមនុស្សស្ថិតនៅក្នុងវ័យណាខ្លះ តើលោកអាចបញ្ជាក់បានទេ? ហើយអាចមានអ្នកជំងឺស្ត្រី ឬក៏មនុស្សចាស់ដែរឬទេ ហើយតើគាត់ធ្វើដំណើរដោយលឿន ឬក៏យឺត ដោយលំបាក ឬងាយស្រួលយ៉ាងណា? សូមលោកបញ្ជាក់បន្តិច។

**ឆ៖** ពាក់ព័ន្ធបញ្ហាលោកសួរនេះ គឺខ្ញុំសូមជម្រាបជូនលោកថា មានគ្រប់វ័យ។ ខ្លះមានតែងម្ដាយឈឺ ហើយដើរមិនរួច។ ដល់ដើរមិនរួចអ៊ីចឹង គឺមានឡានទៅពីនេះអ៊ីចឹងទៅ គាត់ ដល់ឡានអស់ប្រេង អស់អីអ៊ីចឹងទៅ គាត់នាំគ្នារុញអ៊ីចឹងទៅ។ ពេលខ្លះអត់បានទាំងស្បៀងយកទៅ គឺដើរសំពះសុំប្រជាជនពលរដ្ឋដែលនៅជនបទហ្នឹង គឺបានបាយហូប បានអីអ៊ីចឹងទៅ។ ខ្លះជូនអីយកសម្លៀកបំពាក់ដូរអង្ករ ដូរអីពីប្រជាពលរដ្ឋនៅមូលដ្ឋានហ្នឹង គឺដើម្បីបានការហូបចុកហ្នឹង គឺខ្ញុំឃើញពិតប្រាកដអ៊ីចឹងមែនបាទ។

**ស៖** តើកម្មាភិបាលខ្មែរក្រហមមានរៀបចំឲ្យចំណីអាហារ ឬក៏ការព្យាបាលអ្វីទៅដល់ប្រជាជនដែលគាត់អញ្ជើញមកថ្មីហ្នឹងដែរឬទេ?

[១៥:២៥:១៩]

**ឆ៖** ខ្ញុំសូមជម្រាបយ៉ាងខ្លីមួយមាត់ថា គ្មានទេ បាទ។

**ស៖** នៅពេលដែលគាត់ទៅដល់គោលដៅរបស់គាត់ហើយ ថាតើគាត់រស់នៅយ៉ាងដូចម្ដេចដែរនៅទីនោះ? តើគាត់មានចំណីអាហារគ្រប់គ្រាន់ដែរឬទេ? ហើយតើអ្នក -- គេមានសម្គាល់គាត់រវាងអ្នកថ្មី ហើយនិងអ្នកចាស់ដែរឬទេ នៅកន្លែងដែលគាត់នៅនោះ?

**ឆ៖** សូមជម្រាបលោកមេធាវីថា ចំណុចនេះ គឺញែកដាច់ពីគ្នាច្បាស់ណាស់។ គឺគេចាត់ទុកថាអ្នកដែលចេញពីភ្នំពេញទៅ គេថា"ពួក១៧មេសា"។ ហ្នឹងគេឲ្យឈ្មោះអ៊ីចឹងតែម្ដង ហើយការទទួលខុសត្រូវសព្វគ្រប់ទាំងអស់ហ្នឹង គឺអត់មានទេ។ ហើយអ្នកដែលជម្លៀសទៅ ត្រូវបានថា បើមានខ្សែរយៈបងប្អូននៅស្រុកណា គឺគាត់សំដៅទៅស្រុកនោះ។ ក្រោយពីពេលទៅដល់ស្រុកហើយ គឺបងប្អូនស្ទើរតែមិន

ប៊ានឧបត្ថម្ភទៅទៀត ដោយសារតែខ្លាចៗ។ បាទ ដូច្នេះ ជួនពេលខ្លះ ក៏លួចឲ្យហូបទៅ។ ជួនពេលខ្លួនក៏នៅជាមួយគ្នាទៅ ខ្លះក៏ប្តូរផ្តាច់នៅជាមួយគ្នាទៅ។ អ្នកណាយកទៅធ្វើម៉េចក៏យកចុះ។ គឺអ្នកខ្លះប៊ានប្តូរដល់ប៉ុណ្ណឹង។ ហើយនេះសម្រាប់អ្នកដឹកនាំនៅមូលដ្ឋានហ្នឹង គឺក៏អត់រកខុសត្រូវទទួលរាល់អ្នកដែលជម្លៀសទៅហ្នឹងទេ។

[១៥:២៦:៥៦]

**ស៖** លោកមានប្រសាសន៍ថា អ្នកមូលដ្ឋានខ្លាចនៅក្នុងការជួយអ្នកមកថ្មី។ ថាតើហេតុអ្វីបានជាមានការខ្លាចយ៉ាងដូច្នេះ? ថាតើអាចមានអ្វីកើតឡើង ប្រសិនបើជាគេដឹងថា គាត់បានជួយអ្នកថ្មី?

**ឆ៖** ចំណុចនេះ ខ្ញុំសូមជម្រាបលោកមេធាវីថា មូលហេតុដែលគាត់ខ្លាច ពីព្រោះបើខ្ញុំនិយាយពន្យល់លោកដល់ខ្លីទៅវិញ ថាដល់ដំណាក់មួយថា សូម្បីតែបងប្អូនធ្វើការហ្នឹង គឺមិនប៊ានឈរនិយាយគ្នាឲ្យលើសម៉ោង លើសពេលផង។ ចុះទម្រាំអ្នកទៅថ្មី គឺខ្លាចជាប់ខ្សែ១៧មេសា បើបងប្អូនធ្វើទាហានធ្វើអី គឺខ្លាចគេចាប់បន្តតាមខ្សែ។ ម្ល៉ោះហើយគាត់ចេះតែបារម្ភ អត់ប៊ានទេ គាត់ប៊ានទេ។ តែដោយឡែកមួយទៀត ពេលដែលទៅដល់ហើយ គេចាប់ទុកពួក១៧មេសា គេយកទៅដល់មួយម្តុំទៀត គេអត់ឲ្យនៅចូលគ្នាជាមួយនឹងអ្នកនៅមូលដ្ឋានហ្នឹងទៀត។

**ស៖** សូមទោស ដែលខ្ញុំត្រូវសួរបញ្ជាក់បន្ថែម។ លោកថា ខ្លាចគេចោទថា ១៧មេសា ឬក៏ខ្លាចចោទផ្សេងៗ ថាតើហេតុអ្វីបានជាចាំបាច់ខ្លាចគេចោទថា ជាអ្នក១៧មេសា? ហើយតើអ្នកណាជាអ្នក --
- តើមានការណែនាំអ្វីឲ្យមានការធ្វើអ្វីមួយទៅលើអ្នក១៧មេសា ដែរឬទេ?

[១៥:២៨:៤៥]

**ឆ៖** នេះវាជាការងាររបស់ភូមិឃុំ ខ្ញុំអត់អាចក្តាប់បានទេ គ្រាន់តែខ្ញុំពិនិត្យទិដ្ឋភាពរួមទេថាសម្រាប់អ្នក១៧មេសាហ្នឹង គឺត្រូវបានគេចែកដាច់ស្រឡះពីមូលដ្ឋានហើយ។ ដូច្នេះ គឺគេដាក់១៧មេសាហ្នឹង គឺដោយឡែក។ ឯការងារក៏គេដាក់បន្ទុកធ្ងន់ឲ្យជាងអ្នកនៅមូលដ្ឋានទៅទៀត។ នេះចំណុចនេះគឺខ្ញុំសូមជម្រាបលោកអ៊ីចឹង។

**ស៖** បាទ សូមអរគុណដែលបានឆ្លើយក្បោះក្បាយពាក់ព័ន្ធទៅនឹងស្ថានភាពរបស់អ្នក១៧មេសា។ ខ្ញុំចង់សួរនៅភ្នំពេញវិញ ថានៅពេលដែលលោកអញ្ជើញមកភ្នំពេញ តើសភាពនៅភ្នំពេញយ៉ាងដូចម្តេចដែរ? តើមានប្រជាជនរស់នៅទីក្រុងភ្នំពេញដែរឬទេ? ហើយបើ -- តើមានអ្នកផ្សេង ក្រៅពីប្រជាជនរស់នៅទីក្រុងភ្នំពេញដែរឬទេ?

**ឆ៖** ខ្ញុំសូមជម្រាបលោកថា ក្រោយពីមកដល់ភ្នំពេញ គឺមិនបាច់ថាមានមនុស្សនៅទេ សូម្បីតែដើរហ្នឹង គឺស្ងាត់ សឹងថាខ្លាចទៅទៀតនោះ។ គឺគ្មានមនុស្សទេ សូម្បីតែម្នាក់គ្មានទេ បើសិនជាមានកងទ័ពនៅ គឺអាហ្នឹងឃើញជាមនុស្សខ្លះ។ បើថាមិនមានទេ គឺមានតែផ្ទះថ្មទទេៗទាំងអស់ អត់មានមនុស្សនៅ ខ្លះក៏ទ្វារចាក់សោរជាប់ ខ្លះក៏ចំហទ្វារ ក្រោយពីចេញពីផ្ទះទៅគឺចំហទ្វារទុកហ្នឹង គឺមានអីចឹង។

[១៥:៣០:១៨]

**ស៖** ខ្ញុំសូមអរគុណ ខ្ញុំសូមចូលទៅដល់ចំណុចមួយទៀត សូមលើកបន្ថែមបន្តិច ដើម្បីបំពេញបន្ថែមទៅលើអ្នកសំណួរដែលបានសួរទៅលើលោកកន្លងមក។ តើលោកអាចនិយាយបានទេអំពីរចនាសម្ព័ន្ធ ឬក៏ទំនាក់ទំនងរវាងឃ្លាំងរដ្ឋជាមួយនឹងផ្នែកផ្សេងៗទៀតដូច -- តើមានឃ្លាំងរដ្ឋហ្នឹងតែមួយ ឬក៏ថាមានឃ្លាំងរដ្ឋនៅក្នុងក្រសួងអីផ្សេងៗទៀតដែរឬទេ?

**ឆ៖** ខ្ញុំសូមជម្រាបលោកថា ខ្ញុំដឹងអត់ដល់ទេ ដឹងតែត្រឹមតែឃ្លាំង អង្គភាពឃ្លាំងខ្ញុំគ្រប់គ្រង ខ្ញុំរស់នៅកន្លែងប៉ុនណា គឺខ្ញុំដឹងប៉ុណ្ណឹង ដែលឃ្លាំងកន្លែងអង្គភាពផ្សេងៗ គេមានឃ្លាំងរបស់គេសម្រាប់ផ្ទុកសម្ភារៈ គឺផ្សេងៗគេមានរបស់គេទៅ តែខ្ញុំមិនអាចដឹងទេ ដឹងត្រឹមថាឃ្លាំងរដ្ឋនេះសម្រាប់ផ្ទុកនៅស្រូវ, អង្ករ, កៅស៊ូ, ស៊ីម៉ង់ត៍, អំបិល ហើយក្រណាត់ សម្ភារៈផ្សេងៗដែលផលិតបានចេញពីរោងចក្រហ្នឹង គឺខ្ញុំដឹងមានតែប៉ុណ្ណឹងទេ តែក្រៅពីឃ្លាំងផ្សេងៗទៀត គឺខ្ញុំអត់អាចដឹងដល់ទេបាទ។

**ស៖** មេរបស់លោក ដែលលោកបានលើកឡើងហ្នឹងថា ឈ្មោះ រឿង ហ្នឹងថា តើមេរបស់លោកហ្នឹងគាត់មានអ្នកណាគេនៅពីលើមេរបស់លោកហ្នឹងទៀតដែរឬទេ?

**ឆ៖** សូមជម្រាបលោកមេធាវីថា ជាធម្មតារចនាសម្ព័ន្ធសម្រាប់ថ្នាក់ដឹកនាំគឺមាន ក៏ប៉ុន្តែខ្ញុំអត់ស្គាល់។ ខ្ញុំស្គាល់ត្រឹមលោក រឿង តែប៉ុណ្ណឹងមកទេ ក្រៅពីហ្នឹង ខ្ញុំអត់ស្គាល់ទៅលើទេ ខ្ញុំអត់ស្គាល់ទេបាទ។

[១៥:៣២:២០]

**ស៖** តើថ្នាក់ដឹកនាំណាខ្លះដែលធ្លាប់មកឃ្លាំងរដ្ឋ?

**ឆ៖** ខ្ញុំសូមជម្រាបថា ថ្នាក់ដឹកនាំដែលធ្លាប់មក ដូចខ្ញុំបានជម្រាបពីព្រឹកមកក្តីគឺថា មានលោក នួន ជា, លោក ខៀវ សំផន ហើយនិងមានអ្នកផ្សេងៗទៀតដែលចំណុចខ្លះ ខ្ញុំចាំមិនបាន ចំណុចខ្លះក៏ខ្ញុំអត់ស្គាល់ គឺមានមក តែអ្នកខ្លះខ្ញុំស្គាល់ អ្នកខ្លះខ្ញុំអត់ស្គាល់។ បាទ សូមជម្រាបប៉ុណ្ណឹង។

**ស៖** បាទ សូមអរគុណ។ ចំពោះលោក ខៀវ សំផន ហើយនិងលោក នួន ជា ដែលធ្លាប់អញ្ជើញមកឃ្លាំងរដ្ឋរបស់លោក ដែលលោកនៅធ្វើការនៅទីនោះ ថាតើគាត់ធ្លាប់សំណេះសំណាលជាមួយលោកដែរឬទេ ឬក៏ថាបុគ្គលិកនៅក្នុងឃ្លាំងរដ្ឋហ្នឹងដែរឬទេ?

**ឆ៖** នេះខ្ញុំសូមជម្រាបលោកថា ក្រោយពេលដែលគាត់អញ្ជើញមកហ្នឹង គឺខ្ញុំអត់បានជួបគាត់ទេ តែគាត់ណែនាំតាមរយៈអស់លោកផ្សេងៗទៀត។ តែខ្ញុំបានត្រឹមដឹងថាគាត់អប់រំណែនាំកាលពីមករៀនសូត្រ ពីរឿងបញ្ហាគ្រប់គ្រងសម្ភារៈ ថែទាំសម្ភារៈ និងទុកដាក់សម្ភារៈកុំឲ្យខូច គឺមានប៉ុណ្ណឹង ដែលពេលដែលគាត់មកទស្សនកិច្ចគាត់មកពិនិត្យអី គឺខ្ញុំអត់បានជួបជាមួយគាត់ផ្ទាល់ទេបាទ។

[១៥:៣៣:៥៤]

**ស៖** ការណែនាំតាមរយៈអ្នកដទៃហ្នឹងថា តើអ្នកដទៃដែលលោកមានប្រសាសន៍ហ្នឹងគាត់បានមានធ្លាប់ជម្រាបជូនលោកទេ ថាតើអ្វីខ្លះដែលលោក ខៀវ សំផន ឬក៏លោក នួន ជា បានណែនាំមកតាមរយៈអ្នកដទៃហ្នឹង?

**ឆ៖** ថ្នាក់ដឹកនាំដែលគាត់បានការណែនាំពីលោក ដូចខ្ញុំជម្រាបជូនខាងលើហ្នឹង គឺគាត់តែងតែយកពាក្យអប់រំណែនាំ យកមកណែនាំ តែក៏ពេលដែលណែនាំគាត់អត់បាននិយាយថា អេ! លោក ខៀវ សំផន ណែនាំឲ្យធ្វើអីចេះ លោក នួន ជា ណែនាំឲ្យធ្វើអីចុះទេ។ មានតែលោក វឿង ឬក៏លោក តេង ឬក៏លោក ជួន ទេដែលគាត់ថា ដើម្បីឆ្លើយតបនឹងការដឹកនាំរបស់ខាងលើហ្នឹង គឺយើងត្រូវតែបង្កើនស្មារតីទទួលខុសត្រូវ ត្រូវតែបង្កើនស្មារតីគឺគ្រប់គ្រងសម្ភារៈ ថែទាំ និងចែកចាយត្រូវប្រុងប្រយ័ត្នបញ្ជី១០០ ធ្វើយ៉ាងម៉េចកុំឲ្យច្រឡំ កុំឲ្យបាត់។ នេះមានតែប៉ុណ្ណឹងបាទ។

[១៥:៣៥:០០]

**ស៖** បាទ សំណួរបន្ថែមទៀត។ ឃ្លាំងរដ្ឋ សម្ភារៈដែលមាននៅក្នុងឃ្លាំងរដ្ឋថាតើមាន -- ដែលលោកធ្លាប់ដឹងហ្នឹង សម្ភារៈទាំងអស់នោះមានធ្លាប់ត្រូវបានចែកចាយជូនទៅប្រជាជនដែរឬទេ?

**ឆ៖** បាទ ខ្ញុំសូមជម្រាបលោកមេធាវីថា បើតាមខ្ញុំដឹង ហើយខ្ញុំបានធ្វើផ្ទាល់ គឺបើសម្ភារៈចេញពីរោងចក្រ គឺប្រាកដជាត្រូវ១អាទិត្យត្រូវចែកចាយជូនប្រជាពលរដ្ឋម្តង។ ហើយចំពោះការដឹក ខ្ញុំជាអ្នកដើរដឹកសម្ភារៈចេញពីរោងចក្រហ្នឹង គឺមានច្រើនមុនណាស់។ អ្វីដែលផលិតបាននៅនឹងរោងចក្រប៉ុន្មាន គឺខ្ញុំដឹកយកមកដាក់នៅក្នុងឃ្លាំង។ ហើយមួយផ្នែកទៀត ពេលដែលខ្ញុំអ្នកទៅដឹកឯណោះទៅ បងប្អូននៅប្រចាំការឃ្លាំង គឺទទួលបានការណែនាំពីក-២៥ ជាឯកសារដែលគេទៅសុំការអនុញ្ញាតយកឯកសារមក

ដើម្បីយកមកបង្ហាញ ដើម្បីបើកហ្នឹង គឺគេបើក គឺ១អាទិត្យម្ដងដូចគ្នា។ តែត្រង់ចំណុចថា ដល់ដៃប្រជាពលរដ្ឋ ឬក៏មិនដល់ទេ ខ្ញុំអត់ដឹងទេ។ ដឹងថា១អាទិត្យគឺប្រាកដជាចែកម្ដង។

**ស៖** សូមលោកជួយមានប្រសាសន៍បន្ថែមបន្តិច រឿងដែលថាដល់ដៃប្រជាពលរដ្ឋ ឬក៏មិនមែនហ្នឹង ថាតើគេយកពីឃ្លាំងលោកទៅ ហើយកម្មាភិបាល ឬក៏បុគ្គលិកគេយកទៅ ឬក៏ៗលោកយកទៅដល់ខ្លួនឯកយកទៅដាក់នៅភូមិឃុំ ឬក៏សហករណ៍តែម្ដង?

[១៥:៣៦:៥៤]

**ឆ៖** បាទ បញ្ហាការចែកចាយនេះ គឺខ្ញុំអត់បានទៅដល់ផ្ទាល់ទេ គ្រាន់តែបើសិនជាខ្ញុំអត់មកដឹកសម្ភារៈពីរោងចក្រទៅ គឺខ្ញុំនៅនឹងឃ្លាំង គឺខ្ញុំទទួលកាន់គេហៅថាវិក្កយបត្រហ្នឹង គឺដាក់ផ្ទេរពីឃ្លាំងហ្នឹងលើកដាក់ៗលើឡានហើយ គឺស៊ីញ៉េប្រគល់ ស៊ីញ៉េទទួលហើយ គឺចប់ត្រឹមប៉ុណ្ណឹងបាទ។

**ស៖** តើលោកអាចបញ្ជាក់បានទេ ហេតុអ្វីបានជាលោកមានប្រសាសន៍ថា សម្ភារៈមួយចំនួនហ្នឹងយកទៅចែកជូនទៅដល់ប្រជាពលរដ្ឋតែម្ដង? ឬក៏ថាសម្ភារៈហ្នឹងមានគោលដៅយកទៅសម្រាប់ទៅចែកជូនប្រជាពលរដ្ឋ។ ថាតើលោកអាចបញ្ជាក់រឿងហ្នឹងបានទេ? គេមានសរសេរនៅក្នុងលិខិតហ្នឹងច្បាស់លាស់ដែរឬទេ?

**ឆ៖** ខ្ញុំសូមបញ្ជាក់ជូនលោកថា ខ្ញុំអត់ក្ដាប់បានថាគេចែក ឬក៏មិនចែកទេ។ ក៏ប៉ុន្តែគ្រាន់តែជាគោលការណ៍ គឺតាមតំបន់ក្ដី តាមភូមិភាគក្ដីធ្លាប់ដឹងថាកន្លងមក គឺតាមភូមិភាគ តាមតំបន់ដែលដឹកស្រូវយកមកជូនរដ្ឋ បានន័យថាស្រូវជូនរដ្ឋចូលឃ្លាំង គឺរដ្ឋត្រូវតែមានសម្ភារៈហ្នឹង គឺចែកទៅតាមតំបន់តាមភូមិភាគវិញ។ ឯកសារចែកចាយនេះទៀតសោតក៏ដូចគ្នានឹងការដឹកមកដែរ កាលណាខាងណាមកច្រើនទៅ ខ្ញុំតែងតែឃើញថាការចែកចាយទៅវិញ ឃើញថាហាក់ដូចជាច្រើនជាងអ្នកយកតិចដែរ។ នេះការចែកចាយ ខ្ញុំឃើញអ៊ីចឹង។ តែចំណុចខ្លះ ដូចខ្ញុំបញ្ជាក់ហើយបញ្ជាក់ទៀតថា មិនមានការយកទៅចែកហ្នឹង គឺចែកផ្ទាល់ដៃប្រជាពលរដ្ឋទេ គឺសំដៅទៅសហករណ៍ ឬក៏ស្អីហ្នឹង កន្លែងថ្នាក់ដឹកនាំបន្តៗទៅទៀតទៅតាមសហករណ៍ ឬក៏តាមអង្គភាពអ៊ីចឹងទៅបាទ។

[១៥:៣៩:០៥]

**ប្រធានអង្គជំនុំ៖**

អស់ពេលហើយលោកមេធាវី។ បាទ អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅក្រុមមេធាវីការក្ដីលោកនួន ជា ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះសាក្សី!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី នៅពេលដែលលោកបានស្តាប់នូវខ្សែអាត់ដែលថាលោក នួន ជា អ្នកចាក់ឲ្យស្តាប់នៅក្នុងវគ្គរៀនសូត្រហ្នឹង តើលោកចាំទេ ថាតើលោកបានឮអីខ្លះនៅក្នុងខ្សែអាត់នុ៎ង? លោកថា ជាចម្លើយសារភាពរបស់ កុយ ធួន តើលោកឮ កុយ ធួន គាត់និយាយអីខ្លះនៅក្នុងខ្សែអាត់នោះ?

**លោក រស់ ស៊ុយ៖**

**ឆ៖** សូមជម្រាបលោកមេធាវីថា ក្រោយពីការចាក់ខ្សែអាត់ហ្នឹង គឺខ្ញុំបានឮ ខ្ញុំមិនអាចចាំបានអស់បានទេ ចាំខ្លះៗ។ ចំណុចខ្លះបានបញ្ជាក់ថា ប៉ុនប៉ងសម្លាប់ ប៉ុល ពត តែសម្លាប់មិនបានសម្រេច។ ម្ល៉ោះហើយគឺដល់ធ្វើមិនបានសម្រេច បានជាកើតឡើងសារភាព តែពាក្យសារភាពខ្លះគឺខ្ញុំអត់ចាំបានទេ ចាំបានត្រង់ថា កុយ ធួន សារភាព។ កុយ ធួន សារភាពប៉ុណ្ណឹងបាទ។

[១៥:៤០:៤០]

**ស៖** តើចាំដែរឬទេថាការប៉ុនប៉ង ឬក៏ការប៉ងដូចធ្វើឃាត ប៉ុល ពត ហ្នឹងគឺជាការប៉ងដោយការដាក់ថ្នាំ ប៉ុល នៅក្នុងអាហារ? តើលោកចាំថាមាននិយាយពីបញ្ហាហ្នឹងទេ?

**ឆ៖** សូមជម្រាបលោកមេធាវីថា ខ្ញុំអត់បានចាំទេ គ្រាន់តែដឹងថាប៉ុនប៉ងធ្វើឃាត តែមិនដឹងជាដាក់ថ្នាំតាមម្ហូបអាហារ ឬក៏ប្រើវិធីណាខ្ញុំអត់ចាប់អារម្មណ៍ទេ គ្រាន់តែដឹងថាប៉ុនប៉ងធ្វើឃាត។ ប៉ុន្តែមកតាមការសន្និដ្ឋានប្រហែលជាតាមម្ហូបអាហារច្រើនជាងធ្វើសកម្មភាពផ្សេងហើយបាទ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទ ខ្ញុំសូមការបំភ្លឺ ធ្វើការបំភ្លឺទៅជាមួយលោកមេធាវី កូប៉េ។ តើលោកចង់និយាយអំពីខ្លឹមសារនៃសេចក្តីចម្លើយសារភាពរបស់ កុយ ធួន? ខ្ញុំគិតថាយើងអាចពិភាក្សាពីបញ្ហានេះបាន គឺថាយើងមិនអាចនិយាយពីខ្លឹមសារនេះបានទេ ពីព្រោះថាចម្លើយសារភាពរបស់ កុយ ធួន នេះធ្វើឡើងក្រោមការធ្វើទារុណកម្ម។

**លោក វ៉ិចទ័រ កូប៉េ៖**

លោកចៅក្រម ខ្ញុំមិនមានចេតនាសួរបន្ថែមទៅលើខ្លឹមសារនៃចម្លើយសារភាពនោះទេ។ គឺថាខ្ញុំគ្រាន់តែរំឭកការចងចាំរបស់គាត់ ព្រោះថាគាត់បានឆ្លើយតបទៅនឹងមជ្ឈមណ្ឌលឯកសារកម្ពុជា។ ប៉ុន្តែយ៉ាងណាក៏ដោយខ្ញុំសូមបន្តទៅមុខទៀត។

[១៥:៤២:២១]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សីនៅពេលដែលលោកស្ដាប់ខ្សែអាត់នុ៎ង តើមានអ្នកចូលរួមស្ដាប់ខ្សែអាត់ជាមួយនុ៎ងប៉ុន្មាននាក់ដែរ?

**លោក រស់ ស៊ុយ៖**

**ឆ៖** សូមជម្រាបលោកមេធាវីថា បើកវគ្គរៀនសូត្រនោះ គឺដូចខ្ញុំបានជម្រាបជូនអ៊ីចឹង មានគ្នាច្រើនណាស់ ក៏ប៉ុន្តែខ្ញុំអត់ចាំបានថាចំនួនប៉ុន្មាននាក់ទេ ពីព្រោះថាគ្រប់អង្គភាពទៅហ្នឹង គឺខ្ញុំគ្រាន់តែចុះវគ្គមានតាមអង្គភាពហើយ ប្រគល់ជូនទៅខាងថ្នាក់ដឹកនាំទៅ គឺខ្ញុំអត់បានចាំថាចំនួនប៉ុន្មាននាក់ៗ ដែលអង្គុយស្ដាប់ហ្នឹងទេបាទ។

**ស៖** ខ្ញុំយល់ ប៉ុន្តែអាចគិតមើលថាតើមានប្រហែលប៉ុន្មាននាក់? ប៉ុន្មានរយនាក់ ឬក៏ប៉ុន្មានពាន់នាក់អីដែរ? លោកអាចគិតឃើញថាមានប៉ុណ្ណឹងទេ?

[១៥:៤៣:៤០]

**ឆ៖** ការសន្និដ្ឋានរបស់ខ្ញុំហ្នឹង គឺមិនដល់ពាន់នាក់ទេបាទ គ្រាន់ថាអាចជារយអីហ្នឹងគឺប្រហែលព្រោះវគ្គរៀនសូត្រនេះគឺមិនអាចរាប់ពាន់នាក់បានទេ ព្រោះមិនអាចហៅជាទូទៅទៅទាំងអស់ទេបាទ។

**ស៖** លោកសាក្សី តើលោកចាំទេថាបន្ទាប់ពីបានស្ដាប់ខ្សែអាត់នោះ តើមានការពិភាក្សាក្នុងចំណោមអ្នកដែលចូលរួមស្ដាប់នុ៎ងដែរឬទេ? តើមានការពិភាក្សាជជែកគ្នាថា កុយ ធួន ហ្នឹងគេចោទប្រកាន់ថាជាជនក្បត់ហ្នឹងត្រឹមត្រូវ ឬក៏ខុស? តើមានការជជែកគ្នាអីបែបនេះទេ?

**ឆ៖** សូមជម្រាបលោកមេធាវីដែរថា នៅពេលនោះក្រោយពីការពិភាក្សាគ្នាហើយ ឃើញការសារភាពនេះក៏ក្នុងកាលៈទេសៈបច្ចុប្បន្ន -- អ:! ក្នុងកាលៈទេសៈពេលនោះអាចសន្និដ្ឋានថាជាជនក្បត់ហើយ។ ពីព្រោះក្នុងអំឡុងពេលនោះ អ្នកណាមួយដែលថាមិនប៉ាននិយាយពាក្យនេះ គឺត្រូវតែប៉ានហើយ ពីព្រោះត្រូវតែគាំទ្រការធ្វើសកម្មភាពបែបហ្នឹងហើយ។ នេះខ្ញុំសូមជម្រាបអ៊ីចឹងបាទ។

**ស៖** នៅក្នុងចម្លើយរបស់ជាមួយសហចៅក្រមស៊ើបអង្កេត E3/469, ERN មានលេខអង់គ្លេស 00205113, ខ្មែរមានលេខ 00172052, បារាំមានលេខ 00524390។ លោកបានបញ្ជាក់ថា ខ្សែអាត់ត្រូវបានគេលេង និងថត -- គេចាក់នៅឆ្នាំ១៩៧៧ គឺវគ្គសិក្សាឆ្នាំ១៩៧៧ តើត្រឹមត្រូវដែរឬទេ -- គឺ៧៦ តើត្រឹមត្រូវដែរឬទេ?

[១៥:៤៥:៥២]

**ឆ៖** ខ្ញុំសូមជម្រាបលោកមេធាវីថា ដូចខ្ញុំបានផ្តល់សក្ខីកម្មហើយថា ការរៀនសូត្រនេះ ជួនពេលខ្លះ គាត់បានចាក់ ជួនពេលខ្លះអត់បានចាក់ទេ។ ក៏ប៉ុន្តែក្នុងចន្លោះឆ្នាំ៧៦-៧៧ គឺគាត់ចាក់នៅក្នុងចន្លោះឆ្នាំហ្នឹងបាទ។

**ស៖** នៅក្នុងចម្លើយដដែលនេះ គឺនៅទំព័រដដែល គឺមានលេខ ERN ដដែល។ លោកបានញ្ជាក់ជាមួយនឹងអ្នកស៊ើបអង្កេតរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតថា នៅក្នុងវគ្គរៀនសូត្រ នៅពេលដែលគេចាក់ខ្សែអាត់ហ្នឹង លោកក៏បានឮថា សោ ភឹម គឺជាជនក្បត់ដែរ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ ត្រឹមត្រូវបាទ។

**ស៖** តើលោកដឹងដែរឬទេថា ពេលណាលោក សោ ភឹម ស្លាប់?

**ឆ៖** ខ្ញុំអត់ដឹងថា ត្រូវស្លាប់នៅពេលណាទេ គ្រាន់តែបានឮថា សោ ភឹម ជាជនក្បត់។ បានឮត្រឹមតែប៉ុណ្ណឹងទេ អត់ដឹងថាពេលវេលាណា កាលបរិច្ឆេទថ្ងៃណា អត់ដឹងបាទ។

[១៥:៤៧:២៦]

**ស៖** លោកសាក្សីមានភស្តុតាងដែលបង្ហាញថា សោ ភឹម សម្លាប់ខ្លួននៅថ្ងៃទី០៣ ខែមិថុនាឆ្នាំ៧៨។ ហើយខ្ញុំចង់ដឹងថាតើលោកប្រាកដទេថា នៅក្នុងឆ្នាំ៧៧ គឺវគ្គរៀនសូត្រឆ្នាំ៧៧ហ្នឹង នួន ជា បាននិយាយអំពី សោ ភឹម ថាជាជនក្បត់ តើលោកច្បាស់ទេ? តើលោកច្បាស់ទេថានៅពេលដែល នួន ជា និយាយថា សោ ភឹម ជាជនក្បត់ហ្នឹង គឺគាត់និយាយនៅក្នុងកិច្ចប្រជុំនៅក្នុងវគ្គរៀនសូត្រដែលគេនិយាយថា កុយ ធួន ជាជនក្បត់ដែរហ្នឹង តើលោកប្រាកដទេ?

**ឆ៖** សូមជម្រាបលោកមេធាវីថា សម្រាប់ឈ្មោះ សោ ភឹម នេះខ្ញុំសុំបញ្ជាក់ថាអត់ ខ្ញុំអត់សន្និដ្ឋានថាគាត់និយាយទេ។ ក៏ប៉ុន្តែគ្រាន់តែយូរក្រោយពីការពិភាក្សាគ្នា គឺសន្និដ្ឋានហើយក៏ឮបន្តគ្នា។ តែបើសម្រាប់ កុយ ធួន គឺអាហ្នឹងគាត់និយាយផ្ទាល់មែនបាទ។

**ស៖** ឥឡូវនេះ ខ្ញុំចង់ដឹងថាតើលោកបានស្តាប់ឮថា សោ ភឹម ជាជនក្បត់ គឺស្តាប់ឮនៅក្នុងវគ្គ

រៀនសូត្រតែមួយ ដូចដែលលោកនិយាយមុនហ្នឹង ឬក៏អត់ទេ?

**ឆ៖** បាទ នៅពេលដែលវគ្គរៀនសូត្រ បទពិភាក្សាគ្នាតាមៗក្រុមហ្នឹង គឺឮពាក្យហ្នឹងតគ្នាបាទ។

[១៥:៤៩:២២]

**ស៖** សំណួររបស់ខ្ញុំ គឺចង់សួរថា តើលោកប្រាកដទេថាលោកបានឮគេនិយាយថា សោ ភឹម គឺជាជនក្បត់ គឺឮក្នុងវគ្គរៀនសូត្រតែមួយ ដែលក្នុងវគ្គរៀនសូត្រដដែលហ្នឹង លោកឮថា កុយ ធួន ជាជនក្បត់ តើលោកឮក្នុងពេលជាមួយគ្នាហ្នឹងនៅក្នុងវគ្គរៀនសូត្រតែមួយហ្នឹង ឬក៏នៅពេលផ្សេងទេ?

**ឆ៖** បាទ សូមជម្រាបលោកមេធាវីថា ឮនៅពេលដែល ទី១ដឹងថាសោ ភឹម -- កុយ ធួន ក្បត់ហ្នឹងគឺនៅពេលដែលគាត់ចាក់ខ្សែអាត់ហ្នឹង ដែលគេសន្មតថា កុយ ធួន ជាជនក្បត់។ ឯចំណែក សោ ភឹម អាហ្នឹង គឺការពិភាក្សាគ្នា ហើយការពិតទៀត សោ ភឹម ហ្នឹង ក្រោយពីពេលនោះ គឺឮតៗថាគាត់ត្រូវបានក្បត់ពីបក្សកុម្មុយនីស្តអ៊ីចឹងមែន បាទ។

**ស៖** តើលោកមានន័យយ៉ាងម៉េច ដែលលោកនិយាយថា នៅក្រោយៗ មកនោះ?

**ឆ៖** ខ្ញុំចង់បញ្ជាក់ជូនថា ពេលដែលខ្ញុំជម្រាបជូនថា "ក្រោយៗមកហ្នឹង" គឺបានន័យថា ការពិភាក្សាក្រោយៗនេះ គឺធម្មតាអ្វីមួយដែលធ្វើហើយ គឺមិនអាចលាក់នឹងពាក្យមហាជនបានទេ។ ដូច្នេះគ្រាន់ថាជំនាន់ហ្នឹង គឺមិនដឹង មិនឮ គេមាន គេហៅថា ពាក្យមួយចំនួន គេថា "មិនដឹង មិនឮ មិនឃើញតែមិនប៉ាននិយាយ"។ អាមួយដឹងហើយឮហើយ តែនៅមិនប៉ាននិយាយ។ នេះខ្ញុំចង់បញ្ជាក់ន័យអ៊ីចឹង។

[១៥:៥១:១៣]

**ស៖** លោកសាក្សី ឥឡូវខ្ញុំចង់សួរលោកបែបនេះវិញ។ គឺថានៅក្នុងវគ្គរៀនសូត្រ ដែលលោកបានស្តាប់ខ្សែអាត់ពីចម្លើយសារភាពរបស់ កុយ ធួន នោះ គឺថានៅពេលនោះអត់មានអ្នកណាម្នាក់និយាយថា សោ ភឹម ជាជនក្បត់ទេ។ តើខ្ញុំនិយាយអ៊ីចឹងត្រឹមត្រូវដែរឬទេ?

**ឆ៖** ខ្ញុំសូមជម្រាបលោកមេធាវីថា ខ្ញុំអត់ទាន់សន្និដ្ឋានថា លោក នួន ជា និយាយទេ ក៏ប៉ុន្តែខ្ញុំគ្រាន់តែការពិភាក្សាគ្នា ក្រុមពិភាក្សាខ្ញុំ គឺគេនាំគ្នាសន្និដ្ឋាន ហើយធ្វើការប្រៀបធៀប។ ហើយការប្រៀបធៀបនេះ ក្រោយពីហ្នឹងមក ឃើញថា សោ ភឹម ក៏ត្រូវបាត់ខ្លួនទៀត។ ដូច្នេះ គ្រាន់តែជាការវិភាគទេ តែមិនបានឮ នួន ជា គាត់និយាយផ្ទាល់ថា សោ ភឹម គាត់ជាអ្នកក្បត់ទេ។ បានឮត្រឹមតែថា កុយ ធួន ជាអ្នកក្បត់ បាទ។

**ស៖** ហើយនៅពេលដែល នួន ជា និយាយប្រាប់អស់លោកទាំងអស់គ្នាហ្នឹង តើវាជាការរឿង

ដែលដឹងជាទូទៅនៅក្នុងចំណោមកម្មាភិបាល នៅក្នុងចំណោមបក្សកុម្មុយនីស្តកម្ពុជា ឬក៏នៅក្នុងប្រទេសកម្ពុជា តើអ្វីដែលគេនិយាយនេះ ជារឿងដែលគេដឹងទូទៅ ឬក៏អត់ទេ?

[១៥:៥២:៤២]

**ឆៈ** សូមជម្រាបលោកមេធាវីថា បើសម្រាប់អង្គភាពឃ្លាំងរដ្ឋ ពួកខ្ញុំទាំងមូល គឺសូម្បីតែយុវជនប៉ុនណាក៏អាចដឹងដែលថា កុយ ធួន ក្បត់ ហើយបានទាំងចាក់ចម្លើយសារភាព បាទ។ តែអង្គភាពផ្សេង គឺខ្ញុំអត់បានដឹងទេ។ តែដឹងត្រឹមថា អង្គភាពឃ្លាំងគឺគេដឹងគ្រប់គ្នាអ៊ីចឹង។

**សៈ** តើខ្ញុំអាចនិយាយបានដែរឬទេ ថានៅពេលដែល នួន ជា ចាក់ខ្សែអាត់ហ្នឹង មនុស្សទាំងអស់ហ្នឹង គេដឹងថា កុយ ធួន ហ្នឹង ត្រូវគេចាត់ទុកថាជាជនក្បត់។ តើខ្ញុំនិយាយអ៊ីចឹងត្រឹមត្រូវទេ?

**ឆៈ** បាទ ជារឿងត្រឹមត្រូវ បាទ។

**សៈ** សំណួរមួយទៀត ដែលខ្ញុំចង់បញ្ជាក់ទៅលើចំណុចនេះផងដែរ ដូច្នេះគឺថា នួន ជា គាត់អត់ដែលនិយាយជាមួយលោកផ្ទាល់ ឬក៏ទល់មុខគ្នាទេ។ គឺបានន័យថា គាត់មិនដែលនិយាយអំពីបញ្ហាខ្មាំង ឬក៏បញ្ហាអីជាមួយលោកផ្ទាល់ ឬក៏ទល់មុខគ្នា តើអ៊ីចឹងមែនទេ?

**ឆៈ** បាទ ប្រាកដអ៊ីចឹងមែន បាទ។

[១៥:៥៤:០៥]

**សៈ** មុននេះលោកបានផ្តល់សក្ខីកម្មថា "អ្នកដែលធ្វើការនៅក្នុងឃ្លាំងរដ្ឋ ពេលខ្លះត្រូវបានគេកោះហៅទៅប្រជុំ ហើយមុនគេទៅប្រជុំហ្នឹង គេភ័យថា ពួកអ្នកដែលកោះហៅហ្នឹង គឺភ័យខ្លាចបាត់ខ្លួន"។ ហើយលោកក៏បានផ្តល់សក្ខីកម្មថា "លោកត្រូវបានគេហៅទៅប្រជុំ ប៉ុន្តែលោកអត់បាត់ខ្លួនទេ"។ តើនៅពេលដែលគេកោះហៅលោកទៅប្រជុំ គឺថ្នាក់លើហៅលោកទៅប្រជុំហ្នឹង លោកភ័យទេ?

**ឆៈ** សូមជម្រាបលោកមេធាវីថា បញ្ហាដែលគេត្រូវតម្រូវឲ្យទៅប្រជុំ ជាលក្ខណៈអង្គភាព ជាលក្ខណៈដែលថាការងារហ្នឹង គឺខ្ញុំអត់មានបារម្ភទេ។ ក៏ប៉ុន្តែដោយឡែក ពេលដែលគេចាប់ខ្លួនតាមអង្គភាពនេះគឺខ្ញុំគ្រាន់ត្រូវបានដឹងថា គេតេមក ឬក៏គេតេឡេហ្វូនមកថា "នែ៎! ឲ្យមិត្តនេះ មិត្តនោះទៅប្រជុំកន្លែងនេះ ទៅប្រជុំកន្លែងនោះ" គឺខ្ញុំមានតួនាទីគ្រាន់តែប្រាប់ថា "នែ៎! ទៅប្រជុំកន្លែងនេះ ទៅប្រជុំកន្លែងនោះ" ទេ តែរឿងគេចាប់យ៉ាងណាគឺខ្ញុំអត់បានដឹងគេចាប់ទេ ហើយការគំរាមពីខ្ញុំ ពីអ្នកដទៃផ្សេងទៀតគឺអត់ដែលមានទេបាទ។

**សៈ** ខ្ញុំមានសំណួរបីដែលចង់សួរលោក លោកសាក្សី។ តើខ្ញុំអាចនិយាយបានទេថា នៅក្នុង

ឃ្លាំងរដ្ឋហ្នឹងគឺមានស្រូវ ពីរប្រភេទ គឺស្រូវ ហើយនិងអង្ករ។ តើត្រឹមត្រូវដែរឬទេ?

[១៥:៥៦:១៥]

**ផ៖** សូមជម្រាបលោកមេធាវីថា ក្នុងឃ្លាំងហ្នឹងមិនមែនមានតែស្រូវ ហើយនិងអង្ករទេបាទ។ បើឃ្លាំងនៅកំពង់ទឹកកកដូចខ្ញុំបានជម្រាបហើយ ជម្រាបទៀតថា មានកំណាត់, មានស្បែកជើង, មានអំបោះដេរ, មានមុង, មានភួយ, មានដែកគោល, មានថ្មដែកកេះ, មានបើនិយាយឲ្យចំទៅមានទាំងគ្រឿងខ្មៅខ្យង, មានគ្រឿងបន្លាស់មកពីបរទេសទៀតបាទ។ តែដោយឡែកនៅឃ្លាំងគីឡូលេខ៦ គឺមានស្រូវ, មានអង្ករ, មានស៊ីម៉ង់ត៍, មានកៅស៊ូ, មានកន្ទក់។ នេះនៅឃ្លាំងគីឡូលេខ៦ គឺមានប៉ុណ្ណឹងបាទ។

**សៈ** សូមអរគុណលោកសាក្សី។ ខ្ញុំ តាមដែលខ្ញុំស្តាប់សក្ខីកម្មរបស់លោកពីដើមគឺថា ផ្នែកស្រូវ តើផ្នែកស្រូវហ្នឹងមាននាំចេញទៅអត់?

**ផ៖** សូមជម្រាបលោកថា កន្លងមកខ្ញុំបានផ្តល់ចម្លើយជូននូវចំណុចមួយថា ខ្ញុំផ្តល់សក្ខីកម្មមួយថា អស់លោកសួរថា “មានស្រូវ អង្ករចេញទេ?” ខ្ញុំថា “មាន” ក៏ប៉ុន្តែប្រហែលជាខ្ញុំស្តាប់មិនច្បាស់ត្រង់ចំណុចមួយថា “មានស្រូវចេញទេ?” ខ្ញុំថា “មាន” នេះគឺការពិតអត់មានទេ តែដោយខ្ញុំក្តាប់សំណួរអត់បាន ខ្ញុំថាមាននេះ គឺការពិតមានតែអង្ករទេដែលត្រូវចេញ ព្រោះស្រូវដឹកមកពីតំបន់ ពីភូមិភាគអីមកយកមកស្តុកក្នុងឃ្លាំងហ្នឹងហើយបានកិន។ ហើយជួនពេលខ្លះអង្ករក៏កិនមកពីបាត់ដំបង គឺកិនមកហើយស្រេច តែយកមកដល់នៅឃ្លាំងនេះគឺត្រូវបានចម្រាញ់ចេញ ហើយបើអង្ករត្រូវមានកំណត់ថាចេញ គឺគេកំណត់ថា “ឥឡូវត្រូវការអង្ករប៉ុន្មានភាគរយ?” បើត្រូវការអង្ករ ៣០ភាគរយ ប៉ុន្មានតោន គឺប៉ុន្មានរយតោនអីចឹងទៅ គេដាក់បញ្ជាមកគឺខាងផ្នែករោងម៉ាស៊ីន។ អាហ្នឹងគឺមានជំនាញផ្សេងថែមទៀត។ ខ្ញុំមិនបានគ្រប់គ្រងទាំងជំនាញហ្នឹងទេ តែខ្ញុំគ្រាន់តែដឹងថា សម្ភារៈដែលត្រូវចូលមានចំនួនប៉ុន្មាន? មកពីភូមិភាគណា? មកពីស្រុកណា? មកពីខេត្តណា? ហើយដាក់តាមផ្នែកវាតែប៉ុណ្ណឹងទេ។ ឯចំណែកថាត្រូវចេញហ្នឹងគឺអត់មានទេ គឺមានតែចេញអង្ករបាទ។

**សៈ** ខ្ញុំមានសំណួរចុងក្រោយ ខ្ញុំចង់ឲ្យបញ្ជាក់ អីចឹងគឺថា ស្រូវអត់បញ្ចេញ អត់មាននាំចេញទៅក្រៅទេ អីចឹងទេ?

[១៥:៥៩:២០]

**ប្រធានអង្គជំនុំៈ**

សាក្សីកុំអាលទាន់ឆ្លើយ!

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

**លោក អាប់ឌុលឡាក់ ថាវីក៖**

ខ្ញុំសូមអភ័យទោសលោកប្រធាន។ ខ្ញុំគិតថា សំណួរហ្នឹងគឺជាសំណួរនាំមុខ ហើយម្យ៉ាងទៀតវាអត់មាន -- សាក្សីគាត់អត់មានផ្តល់សក្ខីកម្មអីទេទាក់ទងទៅនឹងបញ្ហានេះ។ ដូច្នេះហើយគឺប្រសិនបើមេធាវីការពារក្តីគាត់ចង់សួរអំពីរឿងនាំចេញស្រូវ នាំចេញអង្ករ ឬក៏សម្រុកសម្រួតអីហ្នឹងគឺថា កុំនេះ--

**លោក វ៉ិចទ័រ កូប៉េ៖**

ប្រហែលជាដោយសារតែខ្ញុំសួរសំណួរកាត់ហើយ ប៉ុន្តែដោយសារពេលវេលា ដូច្នេះៗខ្ញុំសួរឡើងវិញ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ថាតើស្រូវហ្នឹងគេយកទៅណាដែរ?

[១៦:០០:០០]

**លោក រស់ ស៊ុយ៖**

**ឆ៖** សូមជម្រាបលោកមេធាវីថា ស្រូវហ្នឹងគឺក្រោយពីនាំមកចូលដល់ឃ្លាំងហើយ គឺខ្ញុំនៅគ្រប់គ្រងមើលការខុសត្រូវហ្នឹង គឺអត់មាននាំចេញទៅណាទេ។ បើសិនជាតម្រូវថា អ្ហ៎! ត្រូវកិនជាអង្ករណ៎ះ ទៅខាងណាៗ ឬក៏កិនអង្ករទុកសម្រាប់បើកឲ្យតាមក្រសួងមន្ទីរ អាហ្នឹងគឺខ្ញុំដឹង។ តែបើរឿងស្រូវនាំចេញ គឺអត់មានទេបាទ។

**ស៖** អ៊ីចឹងតើគេបញ្ជូនអីទៅខាងភូមិភាគ?

**ឆ៖** ត្រូវបានគេបញ្ជូនទៅតាមភូមិភាគហ្នឹង គឺមានសម្ភារៈច្រើនមុខដែរ។ ទី១ ស៊ីម៉ង់ត៍ ដែលត្រូវបញ្ជូនទៅតាមភូមិភាគ និងអំបិល។ ហើយទី២ទៀត សម្ភារៈចេញពីរោងចក្រ ដូចខ្ញុំបានរៀបរាប់ខាងលើអ៊ីចឹងថា សម្ភារៈដែលផលិតបាននៅក្នុងរោងចក្រស្រុកខ្មែរមានប៉ុន្មាន គឺគេត្រូវតែចែកចាយទៅរាល់អាទិត្យអ៊ីចឹង។ តែបើស៊ីម៉ង់ត៍ ហើយនិងអំបិលហ្នឹង គឺឥតមានកំណត់អាទិត្យទេ តម្រូវការគឺពេលណាដែលត្រូវ គឺផ្តល់ទៅតាមភូមិភាគ ឬក៏តំបន់ គឺអត់ទៀង។ បើសម្ភារៈនៅក្នុងឃ្លាំងកំពង់ទឹកកក មានសម្ភារៈច្រើនមុខ ដូចខ្ញុំបានជម្រាបជូនខាងលើ គឺ១អាទិត្យគឺត្រូវតែផ្តល់ទៅតាមភូមិភាគ ឬក៏តំបន់ម្តងហើយ។ នេះសូមលោកជ្រាបបាទ។

[១៦:០១:៤៩]

**ស៖** សូមទោសដែលខ្ញុំត្រូវនិយាយកាត់។ ខ្ញុំដឹងអំពីម៉ោង ប៉ុន្តែសំណួរខ្ញុំចង់សួរថា តើស្រូវដែល -- តើមានអីកើតឡើងចំពោះស្រូវដែលគេបញ្ជូនទៅខាងភូមិភាគហ្នឹង? តើគេយកទៅធ្វើអី?

**ឆ៖** ខ្ញុំសូមបញ្ជាក់ថា ស្រូវអត់មានបញ្ជូនទៅតាមភូមិភាគទេបាទ។

**លោក វ៉ិចទ័រ កូប៉េះ៖**

សូមអរគុណលោកសាក្សី។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទអរគុណលោកមេធាវី។

សវនាការនៅថ្ងៃនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះសាលាដំបូងប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ សវនាការលើកយកទៅបន្តនៅថ្ងៃចន្ទ ទី២៩ ខែមេសា ឆ្នាំ២០១៣ ចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹកទៅ។ ហើយសវនាការនៅថ្ងៃចន្ទ ដើមសប្តាហ៍ក្រោយនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការស្តាប់សក្ខីកម្ម ដើមបណ្តឹងរដ្ឋប្បវេណីមួយរូបដែលមានរហស្សនាម TCCP-186 ដែលនឹងសួរដេញដោលដោយក្រុមសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី មុនភាគីដទៃទៀតនៃរឿងក្តី។ ហើយអង្គជំនុំជម្រះសូមរំឭកផងដែរថា សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី រួមនឹងសហព្រះរាជអាជ្ញាមានរយៈពេលរួមកន្លះថ្ងៃក្នុងការសួរ ហើយសហមេធាវីការពារក្តីទាំងពីរក្រុមដូចគ្នា គឺមានរយៈពេលរួមកន្លះថ្ងៃក្នុងការសួរ។ ហើយអង្គជំនុំជម្រះ សវនាការនៅថ្ងៃចន្ទនេះអង្គជំនុំជម្រះនឹងត្រៀមបម្រុងទុកនូវសាក្សីមួយរូបគឺ TCW-752។ សូមភាគីពាក់ព័ន្ធនៃរឿងក្តី និងសាធារណជនជ្រាប។

[១៦:០៣:៣៨]

លោក រស់ ស៊ុយ ការស្តាប់សក្ខីកម្មរបស់លោករហូតដល់ពេលនេះបានចប់ហើយ។ វត្តមានរបស់លោកនៅ អ.វ.ត.ក នេះលែងមានភាពចាំបាច់ទៀតហើយ។ អង្គជំនុំជម្រះសូមអរគុណចំពោះលោកដែលបានមកផ្តល់សក្ខីកម្មចំពោះមុខអង្គជំនុំជម្រះក្នុងរយៈពេល១ថ្ងៃកន្លងមកនេះ ដោយភាពអំណត់អត់ធ្មត់ខិតខំអស់ពីលទ្ធភាព សមត្ថភាពរបស់ខ្លួន។ សក្ខីកម្មរបស់លោកនឹងអាចរួចវិភាគទាននៅក្នុងការស្វែងរកការពិតនៃរឿងក្តីនេះ។ សូមជូនពរលោក រស់ ស៊ុយ មានសុខភាពល្អ ជួបតែសំណាងល្អបានសេចក្តីសុខសេចក្តីចំរើន ហើយនិងវិលត្រឡប់ទៅវិញប្រកបដោយសុវត្ថិភាព។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងមន្ត្រីនៃអង្គភាពគាំពារសាក្សីនិងអ្នកជំនាញក្នុង

ការជូនលោក រស់ ស៊ុយ ទៅកាន់គោលដៅណាដែលគាត់មានបំណងចង់ទៅ ឬក៏ទៅកាន់លំនៅដ្ឋានគាត់វិញបានហើយ។

អនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូបទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ ហើយនិងឲ្យនាំខ្លួនគាត់ទាំងពីររូបត្រឡប់មកកាន់ -- ចូលរួមនៅក្នុងសវនាការនេះវិញនៅថ្ងៃចន្ទ ទី២៩ ខែមេសា ឆ្នាំ២០១៣ ឲ្យបានមុនម៉ោងប្រាំបួនព្រឹក។ ដោយឡែកលោក នួន ជា ឲ្យនាំខ្លួនគាត់មកនៅត្រឹមបន្ទប់ឃុំខ្លួនខាងក្រោម ដែលមានរៀបចំនូវឧបករណ៍សោតទស្សន៍សម្រាប់គាត់អាចចូលរួមនិងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយតាមមធ្យោបាយសោតទស្សន៍។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៦:០៥នាទី)*